# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៥ លេខ ១២ ខែ ធ្នូ

ព. ស. ២៥០៥ គ. ស. ១៩៦៣

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

- ព្រះពុទ្ធសាសនា នៅសហរដ្ឋអាមេរិក (វិបារណកថា) តែងរៀបរៀង ដោយលោក ឱ. ពាន ១២១២
- អធិបតេយ្យកថា ការសំដែងអំពីអធិបតេយ្យ ៣ យ៉ាង (តចប់) ព្រះសាសនមុនី កឹម-តូ ក្រុមជំនុំព្រះត្រៃបិដក តែងរៀបរៀង . . . . . . . . ១២១៥
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៉ូ តែងរៀបរៀង (ត). . . ១២៣៥
- អំពីអ្នកបរិភោគកាម ១០ ពួក (ឧបាសកវគ្គទី ៥ ទំព័រទី ៤៩ អង្គុត្តរនិកាយ ទសកនិបាត) ១២៤២

*ផ្នែកអក្សរសាស្ត្រ*

- សេរីភាព (វិបារណកថា) ដោយលោក ផេង-ជ្រីវ . . . . . . ១២៥២
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត) . . . ១២៥៧
- រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . ១២៥៩
- ល្បើកឡាហ្វុងតែន លោកផេង-ជ្រីវ ប្រែពីភាសាបារាំង (ត) . . . . ១២៧០
- រឿងព្រេង ចិន (ត) (រឿងក្អែកត្រូវទោស) លោក ភ៊យ-ប៊ុក ប្រែពីភាសាបារាំង . ១២៧៣
- សំបុត្រ ទី ៨ របស់លោកនេរុ លោក ឈន-អៀម ប្រែពីភាសាអង់គ្លេស . . ១២៨២
- ទំនៀមទម្លាប់ខ្មែរៈ វាំស្នែងទន្សោង . . . . . . . . ១២៨៨

*ផ្នែកកំណត់និងប្រវត្តិការណ៍*

- ពិធីសម្ពោធផ្លូងត្រិះស្ពាន ពុទ្ធិកសិក្សា សម្ដេចព្រះនរោត្តម សីហនុ ក្រុងភ្នំពេញ . . ១២៩៣
- សុន្ទរកថា សហជីវិនអនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងព្រះតេជព្រះគុណព្រះពោធិវង្ស ១៣០៣

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០៖០០

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

ប.ត.

### វិចារណកថា

*ដោយលោក ឱ គាម*

# ព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក(១)

នៅថ្ងៃទី ១៤ កក្កដា ឆ្នាំ ១៨៩៨ មានព្រះសង្ឃចំនួន ៣០ អង្គបាន រួមប្រជុំគ្នានៅគេហដ្ឋានរបស់អ្នកប្រាជ្ញជប៉ុនម្នាក់ នៅទីក្រុងសានហ្វ្រាន់ស៊ីស្កូ រដ្ឋកាលីហ្វ័រនីញ៉ា ( SAN FRANCISCO CALIFORNIA )។ ព្រះសង្ឃទាំងនោះ បានរួមជាសមាគមមួយឈ្មោះថា «សមាគមយុវជនពុទ្ធសាសនិក YOUNG MEN'S BUDDHIST ASSOCIATION »។ នេះជាលើកដំបូងបង្អស់ ដែលមានពុទ្ធសន្និបាតនៅសហរដ្ឋអាមេរិក ។

តាំងពីពេលនោះ មកដល់សព្វថ្ងៃនេះ អ្នកកាន់ព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក រាប់ទាំងរដ្ឋហាវ៉ៃផង មានចំនួនជាង ១៥០.០០០ នាក់ ហើយមានព្រះវិហារចំនួន ១២៥ សម្រាប់ធ្វើជាទីសក្ការបូជា ហើយមានមជ្ឈមណ្ឌលអប់រំព្រះពុទ្ធសាសនាដទៃទៀតជាច្រើន ដូចយ៉ាងនៅរដ្ឋកាលី

---

១ - Vorld Buddhism, Vol. IX, n· 11, June 1961, page five.

ហ្វ័រញ៉ា ( CALIFORNIA ) នីវយ៉ក ( NEW-YORK ) ជាដើម ។

បឋមវិហារ

ការទទួលថ្វាយ ព្រះវិហារជាបឋមចំពោះព្រះពុទ្ធសាសនានៅសហរដ្ឋអាមេរិក គឺនៅក្រុងសានហ្វ្រានស៊ីស្កូ ឆ្នាំ ១៩០៥ ។ ព្រះវិហារនេះក៏បានទៅជាមណ្ឌលមួយសម្រាប់ក្រុមបេសកជនពុទ្ធសាសនិក នៅអាមេរិកខាងជើង ដែលបានតាក់តាំងឡើងកាលពីឆ្នាំ ១៩១៤ ។ មិនយូរប៉ុន្មានសហគមន៍ពុទ្ធសាសនិកក៏ផ្សាយទៅរដ្ឋខាងលិច ដូចរដ្ឋអារីហ្សូណា (ARIZONA ) យូថស (UTAH ) វ៉ាស៊ីងតោន (WASHINGTON ) អ៊ីរ៉េគិន ( OREGON ) ។ កាលបើសកម្មភាពព្រះពុទ្ធសាសនា ចេះតែលូតលាស់ហើយ ព្រះវិហារ ក៏ចេះតែស្ថាបនាឡើងរាបមកដែរ ដូចយ៉ាងនៅទីក្រុងដាន់វ័រ រដ្ឋកូឡូរ៉ាដូ ( DENVER COLORADO ) មីណាប៉ូលី ( MINNEAPOLIS ) គ្លីវឡែនដ៍ ( CLEVELAND) ស៊ីកាហ្គោ (CHICAGO ) ហ្វីឡាដេហ្វីយ៉ា ( PHILADEPHIA ) នីវយ៉ក ( NEW-YORK ) នីវហ្ស៊ីកស៊ី ( NEW JERSEY ) ។

ព្រះវិហារដែលសង់ក្រោយគេបង្អស់ នៅសហរដ្ឋអាមេរិក គឺនៅសានហ្វ្រាន់ស៊ីស្កូ ។ ទស្សនាវដ្ដីផ្នែកខាងព្រះពុទ្ធសាសនា ផ្សាយចេញពីមណ្ឌលវប្បធម៌ពុទ្ធសាសនិកនៅក្នុងប្រទេសជប៉ុនជាច្រើន បានធ្វើអំណោយទៅសហរដ្ឋអាមេរិក ។

សហគមន៍ពុទ្ធសាសនិកនៅសានហ្វ្រាន់ស៊ីស្កូ ជាសហគមន៍ធំជាង គេនៅសហរដ្ឋអាមេរិក នៅជាទី ជាន់វ៉ែក្លូទ្យ្រាកដូ ជាមណ្ឌលសម្រាប់ពុទ្ធ សាសនិក នៅរដ្ឋក្លូឡ្រាដូវ៉ាយ៉ូមីញ ( WYOMING ) និងនេប្រាស្កា (NEBRASKA ) ហើយពុទ្ធមណ្ឌលនេះ មានគ្រួសារអាមេរិកាំងជាង ៤០០ គ្រួ ជាសមាជិកពុទ្ធសាសនិក ។

ព្រះវិហារពុទ្ធសាសនិកនៅនិវយ៉ក មានអាយុជាង ៤៤ ឆ្នាំ ។ កាល ពីខែកញ្ញា ឆ្នាំ ១៩៥៤ ប្រជាពុទ្ធសាសនិកជប៉ុន បានធ្វើអំណោយព្រះ ពុទ្ធរូបមួយព្រះអង្គ ធ្វើពីទង់ដែង ដល់សភាពុទ្ធសាសនិកអាមេរិកាំងនៅទី ក្រុងនិវយ៉ក ។ ព្រះពុទ្ធរូបនេះទម្ងន់ពីរតោនកន្លះ ហើយជានិមិត្តរូបនៃ សន្តិភាពនិងសន្តិសុខ ។

ប្រជាពលរដ្ឋអាមេរិកាំង

ការផ្សាយព្រះពុទ្ធវចនៈចូលទៅសហរដ្ឋអាមេរិក គឺដោយសារសេច ក្តីខ្នះខ្នែងរបស់លោករ៉ូបឺរ គ្លីតុន ( ROBERT CLIFTON ) ។ គាត់ជា បុត្រនៃលោកសង្ឃ យេស៊ូម្នាក់ ហើយសព្វថ្ងៃនេះ លោកបួសជាភិក្ខុ មួយព្រះអង្គ មាននាមបញ្ញត្តិថា ព្រះសុមង្គលោ ( Preah Sumangalo ) ។ ព្រះភិក្ខុសុមង្គលោ ជាក់ភារៈចាំងផ្សាយព្រះពុទ្ធសាសនាទៅប្រទេស កាណាដា និងរដ្ឋអាមេរិកខាងត្បូងទៀត ។

# អធិបតេយ្យកថា

ការសំដែងអំពីអធិបតេយ្យ ៣ យ៉ាង

ព្រះសាសនមុនី កិម . ត្វា រៀបរៀង

## អធិបតេយ្យខាងគតិលោក

### អត្តាធិបតេយ្យ

---

ធម្មតាមនុស្សទាំងឡាយដែលកើតមកក្នុងលោក តែងស្រឡាញ់ខ្លួនឯងជាងអ្នកដទៃ ឬជាងវត្ថុ ១ ទាំងអស់ មិនបាច់និយាយថ្វីចំពោះមនុស្សដែលមានរាងកាយល្អមាំមួននោះ ដោយហោចទៅ សូម្បីមនុស្សដែលមានរាងកាយពិកពិការ ក៏តែងតែស្រឡាញ់ខ្លួនឯងជាងអ្នកដទៃដែរ ព្រោះហេតុនោះ មនុស្សម្នាក់ ១ បើស្រឡាញ់ខ្លួនពិតមែន គួរតែយកខ្លួនជាធំក្នុងកិច្ចការគ្រប់យ៉ាងដែលត្រូវធ្វើ ប៉ុន្តែមិនមែនយកខ្លួនជាធំ ហើយប្រព្រឹត្តឲ្យផ្ទុយខុសពីច្បាប់លោកនិងច្បាប់ធម៌ដែលមានមកហើយនោះទេ គឺយកខ្លួនជាធំឬជាប្រធានឲ្យរឹងប៉ឹង ក្នុងមុខការនោះ ១ ហើយអនុលោមទៅតាមច្បាប់លោកនិងច្បាប់ធម៌ឲ្យត្រឹមត្រូវផងដែរ ទើបហៅថា អត្តាធិបតេយ្យ ។

អត្តភាពគឺខ្លួនរបស់យើងនីមួយ ១ ប្រៀបដូចជាភាជនៈ សម្រាប់ទទួលរងទ្រនូវរបស់ទាំងល្អទាំងអាក្រក់ ឬថា ជាទីប្រជុំកើតនៃសេចក្ដីល្អនិងសេចក្ដីអាក្រក់ក៏បាន សមដូចពុទ្ធភាសិតថា «អត្តជំ អត្តសម្ភវំ» ប្រែថា «សេចក្ដីល្អ និង សេចក្ដីអាក្រក់ឬសុខ និងទុក្ខ រមែងកើតអំពីខ្លួន

មានខ្លួនជាដែនកើត ” ។ អត្តៈ ឬ អត្តា ដែលប្រែថាខ្លួនក្នុងទីនេះ សំដៅយកអត្តភាពគឺរូបកាយទាំងមូល ព្រមទាំងចិត្តរួមចូលផង ទើបហៅថាខ្លួន ព្រោះហេតុនោះ បុគ្គលគប្បីសំឡឹងពិនិត្យមើលដំណើរការណ៍ប្រព្រឹត្តទៅរបស់ខ្លួន ទាំងចំណែកខាងល្អ ទាំងចំណែកខាងអាក្រក់ បើដឹងថាខ្លួនប្រព្រឹត្តសេចក្ដីអាក្រក់ហើយ គួរលះបង់ចោលចេញ ហើយគប្បីប្រព្រឹត្តសេចក្ដីល្អតទៅ បើខ្លួនបានប្រព្រឹត្តសេចក្ដីល្អស្រាប់ហើយ ក៏គួរតែប្រព្រឹត្តសេចក្ដីល្អនោះ ឲ្យរឹងរឹតតែក្រៃលែងខ្ជាប់ខ្ជួនតទៅទៀត ៗ មួយយ៉ាងទៀត ធម្មតាធ្វើជាមនុស្សនីមួយ ៗ មិនត្រូវប្រគល់ខ្លួនទាំងស្រុងដល់អ្នកដទៃ ហើយដេកចាំយកសេចក្ដីសុខអំពីគេដោយងាយៗ នោះឡើយ មិនត្រូវបណ្ដោយខ្លួនឲ្យធ្លាក់ចុះក្នុងឋានៈដ៏ថោកទាបទៅជាអាយ៉ង ឬជាទាសភាពនៃជនដទៃឡើយ មិនត្រូវបណ្ដោយខ្លួនឲ្យលង់ធ្លាក់ចុះក្នុងបមាទធម៌គឺសេចក្ដីប្រមាទ ឬ សេចក្ដីធ្វេសប្រហែស ក្នុងគតិលោក ឬក្នុងគតិធម៌ណាមួយឡើយ ព្រោះថា សេចក្ដីប្រមាទ ឬ សេចក្ដីធ្វេសប្រហែសនេះ ជាមូលហេតុនៃសេចក្ដីវិនាស ហិនហោចគ្រប់យ៉ាង ទាំងក្នុងផ្លូវលោក ទាំងក្នុងផ្លូវធម៌ ។ មនុស្សណា មានសេចក្ដីប្រមាទ ឬ ធ្វើខ្លួនឲ្យលុះក្នុងអំណាចនៃសេចក្ដីប្រមាទជានិច្ចហើយ មនុស្សនោះ ទុកដូចជាបើកទ្វារចំហឲ្យឱកាសដល់សត្រូវ ពោលគឺសេចក្ដីអន្តរាយគ្រប់យ៉ាង ហូរចូលជានិច្ចផង ទុកដូចជាស្លាប់បាត់ទៅហើយផង សូម្បីមាន

ជីវិតកំពុងរស់នៅ ក៏ទុកដូចជាស្លាប់ហើយដែរ អ្នកណាមិនប្រមាទ អ្នកនោះទុកដូចជារស់នៅ សូម្បីស្លាប់បាត់ទៅហើយ ក៏ទុកដូចជារស់នៅដែរ ។

សេចក្ដីស្លាប់របស់មនុស្សមានពីរយ៉ាងគឺ ស្លាប់ជីវិត១ ស្លាប់គំនិត១ ។ បណ្ដាសេចក្ដីស្លាប់ទាំងពីរយ៉ាងនេះ ឯសេចក្ដីស្លាប់គឺអស់ខ្យល់ចេញនឹងខ្យល់ចូល ទាំងវិញ្ញាណក៏ប្រាសចេញផុតចាកកាយទៅហើយ ហៅថា ស្លាប់ជីវិត ស្លាប់បែបនេះជាការប្រសើរល្អជាងស្លាប់គំនិត ។ មនុស្សណា ដែលធ្វេសប្រហែសបណ្ដោយតាមគំនិតស្មារតីឲ្យលង់លុះក្នុងកាមគុណ ឬក្នុងអំពើឥតប្រយោជន៍ ឬក៏ក្នុងអំពើអាក្រក់ណាមួយ ដោយកាយ វាចា ចិត្ត ដែលជាអំពើឃ្លាងផុតស្រឡះពីសេចក្ដីល្អ សេចក្ដីចម្រើនខាងផ្លូវលោក នឹងខាងផ្លូវធម៌ ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក មនុស្សនោះឯង ហៅថា មនុស្សស្លាប់គំនិត ។ ធម្មតាមនុស្សស្លាប់មែន ។ ដែលមានវិញ្ញាណនឹងអស្សាសប្បស្សាសៈប្រាសចេញផុតពីកាយទៅហើយ ពុំដែលមានគំនិតគិតថា អាត្មាអញនឹងឲ្យទានរក្សាសីល ឬនឹងធ្វើកិច្ចការណាមួយជាសាធារណៈ ប្រយោជន៍សម្រាប់ជាតិឬសម្រាប់ស្រុកទេសសោះឡើយ យ៉ាងណាមិញ ឯមនុស្សប្រមាទគឺមនុស្សស្លាប់គំនិតក៏គ្មានដូច្នោះដែរ ។ មនុស្សប្រភេទណាក៏ដោយ តោះជាបព្វជិតក្ដី គ្រហស្ថក្ដី ដែលជាអ្នកប្រកបដោយសេចក្ដីប្រមាទ

ហើយ ទុកដូចជាដង្គត់ក្នុងលោក ឬជាមនុស្សបំផ្លែព្រៃលោក ។ វិជ្ជ-សង្ហាររបស់មនុស្សប្រមាទនេះ សូម្បីញាណរបស់ព្រះពុទ្ធក៏ពុំអាចកំណត់បានឡើយ ។ មនុស្សប្រមាទនេះ បើនិយាយឲ្យពក់មក បានដល់មនុស្សណាមួយ សូម្បីនៅក្នុងស្រុក ភូមិ ប្រទេសណា ឥតដែលមានធ្វើសេចក្ដីល្អឲ្យកើតឡើងដល់ខ្លួន ឬដល់អ្នកដទៃឬធ្វើអ្វីទុកជាប្រ-យោជន៍ខាងផ្លូវលោក ឬ ខាងផ្លូវធម៌ក្នុងស្រុកភូមិប្រទេសនោះឡើយ មានតែបង្កហេតុអាក្រក់ គឺទុក្ខទោសអពមង្គល បំផ្លិចបំផ្លាញ កកំផលប្រយោជន៍ និងសេចក្ដីចម្រើនរបស់គេ ឲ្យវិនាសហិនហោច ដោយសារខ្លួនតែម្យ៉ាងប៉ុណ្ណោះ មានតែកេរ្តិ៍ឈ្មោះស្អុយអាក្រក់ និងអំពើអាក្រក់របស់ខ្លួនដែលធ្វើនោះ ទុកជាប្រវត្តិ ឬជាស្នាដៃ ជាកេរ្តិ៍ដំណែលឲ្យអ្នកផងស្អប់ខ្ពើមចាំទុកមិនភ្លេច ។ មនុស្សប្រមាទគឺមនុស្សស្លាប់គំនិតឬស្លាប់ស្មារតីនេះ ជាទោសមួយដ៏ធំក្រៃលែងជាងទោសឯទៀតទាំងអស់ ព្រោះជាហេតុនាំឲ្យវិនាសខូចប្រយោជន៍ច្រើនប្រការណាស់ សូម្បីដើរឈរអង្គុយដេក ក៏ឥតដឹងថាការគួរពុំគួរ ឬធ្វើអ្វីក៏ឥតដឹងខុស-ត្រូវ ឥតដឹងកាលៈទេសៈរបស់លោកនិយមឡើយ ។ សម័យដែលគេត្រូវរៀនចំណេះវិជ្ជាក៏មិនគិតរៀន សម័យដែលគេត្រូវប្រកបការងាររកទ្រព្យសម្បត្តិ ក៏មិនគិតរក បើទុកជាមានគេរៀនសូត្រចេះដឹងច្រើនដល់ថ្នាក់ណា ឬគេរកស៊ីកាត់មុខ ដណ្ដើមយកផលប្រយោជន៍ចំពោះមុខខ្លួន បានកើតកាលពល

គុម្ព ទៅជាអ្នកមានកោតសម្បុរសុតស្តម្ភយ៉ាងណា ក៏មិនកោតសរសើរមិនស្ញើមទឹងគេ បេះតែបំអៀកទម្រន់ គ្រេះគ្រុះអឹកអាក់ ទាល់តែគេទាញយកផលប្រយោជន៍ជុំវិញខ្លួនបានទាំងអស់ ម៉្លោះហើយ ក៏ខ្ចាត់ខ្ចាយចេញទៅនៅព្រៃផ្សៃ ចុងកាត់មាត់ញកឯណាឆ្ងាយទៅ ៗ បើខាងបព្វជិតវិញ សម័យដែលគេត្រូវសិក្សារៀនបរិយត្តិ-ធម៌អាចថ្មុគេត្រូវធ្វើអ្វីឲ្យចម្រើនដល់ព្រះពុទ្ធសាសនា ក៏មិនគិតរៀនមិនគិតធ្វើទឹងគេ ទោះបីមានគេណែនាំដាស់តឿនរំឭកយ៉ាងណា ក៏មិនរវល់ស្ដាប់ មិនយកចិត្តទុកដាក់ធ្វើតាមៗ

កាលបើគេមានវិជ្ជាធម៌បេះតែចម្រើនខ្ពស់ត្រដែតឡើងរាល់ថ្ងៃ មនុស្សស្ទាប់គំនិត ស្បៀតយកក្លែកមើល ស្បៀតយកត្រចៀកស្ដាប់ ពីដើមធ្លាប់ធ្វើយ៉ាងណា ក៏នៅតែចចេសប្រកាន់ធ្វើយ៉ាងនោះដដែល ៗ មិនព្រមលះបោល ខ្លួនឯង បើបានជាល្ងង់ទៅហើយ ក៏ល្ងង់តែម្នាក់ឯងទៅចុះ ថែមទាំងរាំងគេឯទៀត មិនឲ្យគេសិក្សារៀនសូត្រទេ បណ្ដោយឲ្យគេនៅល្ងង់ដូចជាខ្លួនផងដែរ ៗ បើបំព្រួញសេចក្ដីឲ្យខ្លីមកថា មនុស្សស្ទាប់គំនិត ឈ្មោះថាស្ទាប់ទាំងអស់ គឺស្ទាប់ប្រយោជន៍បច្ចុប្បន្នទឹងប្រយោជន៍បរលោក ជាមនុស្សមិនទាន់សម័យនិយម មិនអនុវត្តទៅតាមកាលៈទេសៈ ឈ្មោះថាជាមនុស្សរកាំងប្រយោជន៍ទឹងសេចក្ដីចម្រើនរបស់លោក មានតែខ្យល់ដង្ហើមចេញចូល ដូចជាស្នប់ឥតជីងអ្វី រស់នៅគ្រាន់តែបរិភោគ

អាហារ ឬគ្រាន់តែរាប់ថ្ងៃ យប់ខែ ឆ្នាំមួយៗ ដែលកន្លងទៅហើយប៉ុណ្ណោះ

មនុស្សស្លាប់គំនិតដូចបានពោលមកនេះ ឈ្មោះថាសូន្យចាកប្រយោជន៍គ្រប់យ៉ាង សមដូចសុភាសិតក្នុងលោកនីតិថា ៖

អលសស្ស កុតោ សិប្បំ អសិប្បស្ស កុតោ ធនំ
អធនស្ស កុតោ មិត្តំ អមិត្តស្ស កុតោ សុខំ
អសុខស្ស កុតោ បុញ្ញំ អបុញ្ញស្ស កុតោ សិវំ ។

មនុស្សខ្ជិល នឹងបានបំណេះមកអំពីណា មនុស្សគ្មានបំណេះ នឹងបានទ្រព្យមកអំពីណា មនុស្សគ្មានទ្រព្យ នឹងបានមិត្តមកអំពីណា មនុស្សគ្មានមិត្ត នឹងបានសុខមកអំពីណា មនុស្សគ្មានសុខ នឹងបានបុណ្យមកពីណា មនុស្សគ្មានបុណ្យ នឹងបានសួគ៌និព្វានមកអំពីណា ។

ព្រោះហេតុនោះ មនុស្សខ្ជិលក៏មានឈ្មោះថាជាមនុស្សប្រមាទ ជាមនុស្សស្លាប់គំនិត មនុស្សបែបនេះ ឈ្មោះថាខ្សត់ក្រ កំព្រាសូន្យសព្វទាំងអស់ គឺសូន្យចាកប្រយោជន៍បច្ចុប្បន្នទាំងប្រយោជន៍បរលោក សូម្បីស្លាប់ទៅក៏សូន្យនាមទាំងគោត្រកេរ្តិ៍ឈ្មោះទាំងអស់ផងទៀត ឥតមានគេនឹកនាស្តាយអាឡោះអាល័យឡើយ ព្រោះគ្មានបានធ្វើសេចក្តីល្អ ឬសេចក្តី

សង្គ្រោះដល់អ្នកណាមួយ គ្មានបានសារអ្វីជាប្រយោជន៍សម្រាប់ទំនុកបំរុងខាងផ្លូវលោក ឬខាងផ្លូវធម៌ ទុកជាគ្រឿងណែលជាស្នាដៃ ដើម្បីឲ្យអ្នកផងគេទទួលស្គាល់នឹកនា ចាប់អារម្មណ៍ចំពោះខ្លួនសោះឡើយ ។

ចំណែកខាងមនុស្សដែលមានអាកប្បកិរិយាផ្ទុយពីមនុស្ស ដូចបានពណ៌នាមកហើយ ក្នុងខាងលើនោះ ហៅថាមនុស្សមិនប្រមាទ មនុស្សមិនស្លាប់គំនិត ។ ធម្មតាមនុស្សមិនស្លាប់គំនិត តែងមានគំនិតរស់រវើកដើរជានិច្ច ដូចទ្រនិចនាឡិកា តែងពិចារណាថា ថ្ងៃមួយ យប់មួយ ដែលកន្លងទៅហើយ គេអាត្មាអញ បានធ្វើអ្វីខ្លះ ទុកជាប្រយោជន៍ខ្លួន ឬជាប្រយោជន៍អ្នកដទៃ? កាលបើគិតឃើញហើយ មិននៅដំអក់ទម្រន់ តែងស្ទុះស្ទារ រះរកបំពេញកិច្ចការនោះ ៗ តាមកម្លាំងនឹងសមត្ថភាពរបស់ខ្លួនគ្រាតែបានសម្រេចដល់ទីបំផុត ។ មនុស្សមិនស្លាប់គំនិត សម័យដែលគេត្រូវរៀន ក៏ខំប្រឹងរៀន សម័យដែលគេត្រូវរកទ្រព្យសម្បត្តិ ក៏ខំរក ធ្វើការអ្វី តែងមានសតិសម្បជញ្ញៈក្នុងការនោះ គឺដឹងថាគួរឬមិនគួរ មានប្រយោជន៍ឬឥតប្រយោជន៍ភ្លាម ៗ ។ មនុស្សបែបនេះ បើរៀនចំណេះវិជ្ជាអ្វី ក៏ឆាប់ចេះ ឆាប់យល់ បើស្វែងរកប្រយោជន៍បច្ចុប្បន្ន មានទ្រព្យសម្បត្តិជាដើម ក៏ច្រើនឆាប់ជួបប្រទះនឹងសេចក្តីចម្រើន បើស្វែងរកប្រយោជន៍បរលោក គឺបុណ្យកុសលផ្សេងៗ ក៏តែងបានបុណ្យកុសលច្រើនលើសគេជាដរាប ឈ្មោះថាជាមនុស្សមានការបដិវត្តន៍លឿនទាន់សម័យ

សមដូចពុទ្ធភាសិតថា៖

អប្បមត្តោ បមត្តេសុ
សុត្តេសុ ពហុជាគរោ
អពលស្សំវ សីឃស្សោ
ហិត្វា យាតិ សុមេធសោ ។

មនុស្សអ្នកមានប្រាជ្ញាល្អ កាលបើអ្នកដទៃប្រមាទ ធ្វេសប្រហែស ភ្លេចស្មារតី គេមិនប្រមាទ មិនធ្វេសប្រហែស មិនភ្លេចស្មារតី កាលបើអ្នកដទៃដេកលក់ ស្លាប់គំនិតស្មារតី គេភ្ញាក់រឭកដឹងខ្លួន មានគំនិតស្មារតីរស់រវើក ដើរលឿនទៅមុខឆ្ងាយជាប់ស្រយាល លះបោលមនុស្សកំសោយ គឺមនុស្សប្រមាទដេកលក់ ស្លាប់គំនិតនោះស្រឡះ ដូចសេះមានល្បឿន លឿនដោយបោលសេះកំសោយជើងខ្លក តាមមិនទាន់ ក៏ដូច្នោះឯង ។

*មនុស្សមានប្រាជ្ញារមែងមិនប្រមាទ តែងមានយោបល់ត្រូវជានិច្ច ធ្វើប្រយោជន៍បច្ចុប្បន្ន ធ្វើប្រយោជន៍បរលោក ធ្វើប្រយោជន៍ឲ្យដល់អ្នកដទៃ គឺជួយសង្គ្រោះទំនុកបំរុងតាមមាន តាមបាន ឲ្យគេបានសុខ បានចម្រើន*

ដោយសារខ្លួន ៗ មនុស្សបែបនេះ កាលបើមានជីវិតរស់នៅ អ្នកផងរមែងចូលចិត្តស្រឡាញ់រាប់អាន មានកេរ្តិ៍ឈ្មោះពីរោះក្រអូបផ្សាយខ្ចរទៅសព្វទិសទី សូម្បីរូបកាយស្លាប់បាត់បង់ទៅហើយក៏ដោយ ឯនាមនឹងគោត្រគឺកេរ្តិ៍ឈ្មោះនៅរស់រវើក មិនចេះស្លាប់រលាយបាត់សូន្យទៅផងឡើយ គេតែងកត់ចំណាំចាំទុក អស់កាលជាយូរអង្វែង ព្រោះហេតុនោះបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ៖

មនុស្សប្រមាទ សូម្បីមានជីវិតរស់នៅ
ក៏ទុកដូចជាស្លាប់ទៅហើយ
ឯមនុស្សមិនប្រមាទ សូម្បីស្លាប់បាត់ហើយ
ក៏ទុកដូចជាមានជីវិតរស់នៅដែរ ។

មួយយ៉ាងទៀត ពួករុក្ខជាតិផ្សេងៗ មាន បេង ក្រញូង នាងនួន ជាដើម ដែលគេនិយមរាប់អានថាជាឈើមានសាច់ជាប់ល្អ គេតែងយកមកធ្វើជាសម្ភារៈគ្រឿងឧបករណ៍ប្រើប្រាស់ មានតុ ទូ នឹងគ្រឿងតាំងសំកប់លំអជាដើម ប៉ុន្តែឈើទាំងនោះ ដែលដុះកើតឡើងហើយ មិនមែនដុះកើតចេញលេចទៅជា តុ ជាទូ ជាកៅអី ។ល។ ស្រេចស្រាប់សម្រាប់ឲ្យគេយកទៅប្រើការបានតែម្តងនោះទេ បើតាមធម្មតា ជាតិរបស់ឈើទាំងនោះ រាងរពើគរពើង ប្រឆេងប្រឆាង មើលទៅពុំគួរឲ្យជ្រះថ្លា ពុំគួរឲ្យ

បង់បានសោះ ប៉ុន្តែបើគេយកមករចនាលៃលកធ្វើជារបស់ប្រើប្រាស់មានតុ ទូ កៅអីជាដើម ឈើនោះក៏ក្លាយទៅជារបស់មានប្រយោជន៍ គួរឲ្យគេជ្រះថ្លា ចង់មើល គួរឲ្យគេចូលចិត្តស្រឡាញ់ ចង់បានទៅវិញ យ៉ាងណាមិញ ធម្មតាមនុស្សយើងនីមួយ ៗ ដែលកើតមកហើយ បើខ្វះការសិក្សា ខ្វះការអប់រំ ខ្វះការណែនាំអំពីបុគ្គលដទៃ ហើយបណ្តោយខ្លួនឲ្យទៅតាមធម្មជាតិដើម ពីកំណើតមកនោះ មិនខុសអំពីដើមឈើ ឬអំពីសត្វតិរច្ឆានប៉ុន្មានឡើយ ។ ព្រោះហេតុនោះ ការសិក្សា ការអប់រំ និងការណែនាំអំពីបុគ្គលដទៃនេះឯង ជាគុណសម្បត្តិដ៏វិសេស អាចកែប្តូររចនាធម្មជាតិដើមរបស់មនុស្សនោះ ឲ្យក្លាយទៅជាអរិយមនុស្ស គួរឲ្យគេស្រឡាញ់ គួរឲ្យគេសេពគប់ រាប់រកយកជាគ្នាទៅបាន ក៏ដូច្នោះដែរ ។

សេចក្តីដែលបានពណ៌នាមកហើយអំពីពាក្យថា អត្តាធិបតេយ្យ ដែលប្រែថាយកខ្លួនជាធំនោះ គឺមិនមែនយកខ្លួនលើកតម្កើងឲ្យជាធំ ដោយស័ក្តិយសបរិវារ ឬបន្ទំខ្លួនឯងឲ្យធំ ឲ្យគ្រាន់បើលើសអ្នកដទៃនោះទេ ត្រូវតាំងចិត្តជាធំគឺធ្វើចិត្តឲ្យមោះមុតអង់អាច ឲ្យរឹងប៉ឹង ឲ្យក្លៀវក្លា កស្ទូមិនរួញរាក្នុងមុខការណាមួយដែលខ្លួនត្រូវធ្វើ ត្រូវប្រព្រឹត្ត ហើយអនុលោមគោរពទៅតាមច្បាប់លោកនិងច្បាប់ធម៌ផង ទើបហៅថា អត្តាធិបតេយ្យ ។

## លោកាធិបតេយ្យ

មនុស្សម្នាក់ ៗ ដែលកើតមកក្នុងលោក គួរតែធ្វើលោកគឺមនុស្សផង

គ្នាឲ្យជាធំក្នុងកិច្ចការគ្រប់យ៉ាងដែលខ្លួនត្រូវធ្វើ ប៉ុន្តែមិនមែនលើកយកលោកមកឲ្យជាធំ ហើយប្រព្រឹត្តឲ្យខុសផ្ទុយពីច្បាប់លោកនិងច្បាប់ធម៌នោះទេ គឺគ្រាន់តែធ្វើសេចក្តីគោរព ចំពោះលោកឬយកលោកជាប្រមាណក្នុងមុខការនោះ ៗ ហើយគប្បីអនុលោមគោរពតាមច្បាប់លោកនិងច្បាប់ធម៌ឲ្យបានត្រឹមត្រូវផង ទើបហៅថា លោកាធិបតេយ្យ ៗ មនុស្សនីមួយ ៗ ទោះជាគ្រហស្ថក្តី ជាបព្វជិតក្តី មិនត្រូវបណ្តោយគំនិតឲ្យស្លាប់ស្លុកដូចជាបុគ្គលស្លាប់ដែលអស់ខ្យល់ចេញនិងខ្យល់ចូលនោះទេ ត្រូវតែឲ្យមានសតិសម្បជញ្ញៈជានិច្ច បើកភ្នែកសម្លឹងមើលអ្នកដទៃដែលគេនៅជុំវិញខ្លួនយើងផង តើគេយ៉ាងណា? អាត្មាអញយ៉ាងណា?

បើផ្នែកខាងគ្រហស្ថដែលប្រាថ្នានឹងធ្វើការអ្វីមួយ ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី គួរគិត គួរក្រែងរអែងដល់អ្នកដទៃជាដរាប ព្រោះថាមនុស្សទូទៅក្នុងលោក មិនមែនសុទ្ធតែល្ងង់ខ្លៅដូចគ្នាទាំងអស់ទេ គង់មានអ្នកប្រាជ្ញបណ្ឌិត គេមានប្រាជ្ញាចេះដឹង មានយោបល់យល់ហេតុការណ៍ជក់ជ្រៅ ឃើញកាលវែងឆ្ងាយ ទាំងក្នុងគតិលោក ទាំងក្នុងគតិធម៌ក៏មាន ៗ

បើអាត្មាអញជាមនុស្សប្រព្រឹត្តអំពើលាមកកខ្វក់ មានកាយទុច្ចរិតជាដើមយ៉ាងនេះ បើគេបានដឹងឃើញហើយ គេនឹងមើលងាយ ត្មះតិះដៀល

ដល់អាត្មាអញដែរឬទេ ? បើអាត្មាអញជាមនុស្សមានទកងកាយមាំមួន ហើយត្រឡប់ធ្វើជាមនុស្សខ្ជិលច្រអូស មិនប្រកបការងារកេរស៊ី បណ្តោយឲ្យជីវភាពចុះដុនដាបក្រហេមរហាមយ៉ាងនេះ តើគេនឹងមើលងាយតុះតិះដៀលដល់អាត្មាអញដែរឬទេ? បើអាត្មាអញជាមនុស្សល្មោភលោភលន់ អត់ទ្រាំពុំបាន ហើយទៅលួចប្លន់បោកប្រាស់ឆក់ដណ្តើមយកទ្រព្យសម្បត្តិរបស់អ្នកដទៃ បើដូចជាអ្នកផងគេចាប់បានយកទៅធ្វើទណ្ឌកម្ម ដាក់ទោសតាមកំហុសដូច្នេះឬដូច្នោះទៅ តើអ្នកផងគេនឹងមើលងាយតុះតិះដៀលដល់អាត្មាអញដែរឬទេ ? បើអាត្មាអញមិនគិតសិក្សារៀនសូត្រចំណេះវិជ្ជាខាងផ្លូវលោកឬខាងផ្លូវធម៌ទេ បណ្តោយខ្លួនឲ្យទៅជាមនុស្សល្ងង់ខ្លៅយ៉ាងនេះ តើគេនឹងមើលងាយតុះតិះដៀលអាត្មាអញដែរឬទេ ? បើអាត្មាអញជាមនុស្សគ្មានហិរិឱត្តប្បៈ គឺគ្មានសេចក្តីខ្មាសបាប គ្មានសេចក្តីតក់ស្លុតខ្លាចបាប ជាមនុស្សមានបរិយាបូកពារថោកទាប តាំងពីប្រើឥរិយាបថគឺដើរឈរគង្គុយ ដេកជាដើមទៅ គ្មាន អបចាយនធម៌ គោរពកោតក្រែងដល់ចាស់ទុំព្រឹទ្ធាចារ្យ មានមាតាបិតាជាដើមទេ តើគេនឹងមើលងាយ តុះតិះដៀលដល់អាត្មាអញដែរឬទេ ? ។ល។

ពុំនោះសោត អាត្មាអញត្រូវតែលើកភ្នែកក្រឡេកមើលទៅជុំវិញខ្លួនអាត្មាអញ ដូចអ្នកដែលមានទ្រព្យសម្បត្តិច្រើន តាំងកេរ្តិ៍ឈ្មោះគេក៏ល្អ ឬ

អ្នកដែលមានចំណេះចេះដឹងច្រើនទាំងផ្លូវលោកទាំងផ្លូវធម៌ តើមូលហេតុដែលនាំឲ្យគេកសាងខ្លួនបានឡើងកាន់ជីវភាពនឹងឋានៈដ៏ខ្ពង់ខ្ពស់ ដែលគួរឲ្យអ្នកផងគេស្ងើចសរសើរដូច្នោះនោះ ដោយសមុដ្ឋានបែបណា? លុះត្រិះរិះគិតឃើញផ្លូវ ឃើញទំនងសមហេតុសមផលហើយ ក៏ត្រូវតែព្យាយាមលៃលកដំណើរការណ៍នោះឲ្យអនុវត្តទៅតាមគំនិត ដែលបានគិតឃើញនោះដរាប តាល់តែបានសម្រេច ពុំត្រូវទំលាក់គំនិតនោះបោះបង់ចោលឡើយ ត្រូវតែតស៊ូឲ្យដល់ទីបំផុត សមនឹងពុទ្ធភាសិតថា "វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា" កើតមកជាកូនប្រុស ត្រូវតែព្យាយាមតស៊ូកុងការងារ ដរាបតាល់តែបានសម្រេចប្រយោជន៍សឹមឈប់ មួយយ៉ាងទៀត ត្រូវអធិដ្ឋានចិត្តឲ្យរឹងប៉ឹងថា គេម៉េច អញម៉េច កើតមកជាមនុស្សដូចគ្នា គេម៉េចក៏រៀនចេះ អញម៉េចក៏រៀនមិនចេះ គេម៉េចក៏ប្រកបការរកស៊ីធ្វើជាអ្នកមានកើត អញម៉េចក៏ប្រកបការរកស៊ីធ្វើជាអ្នកមានមិនកើត ព្រោះហេតុអ្វី? បើគេរៀនចេះ អញក៏រៀនចេះ បើគេរកស៊ីធ្វើជាអ្នកមានកើត អញក៏រកស៊ីធ្វើជាអ្នកមានដូចគេកើតដែរ បើមិនបានដូចគេ ក៏គង់គ្រប់គ្រាន់ដែរ មិនត្រូវដេកស្មៀមបណ្តោយទៅតាមយថាកម្មទេ ប្រៀបដូចសត្វខ្លា ជាសត្វមានឥទ្ធានុភាពខ្លាំងពូកែ ឯពួកសត្វទ្វេបាទ ចតុប្បាទ ឯទៀត គ្រាន់តែគ្រឡេកឃើញខ្លា ក៏គិតភ័យតក់ស្លុតស្ទើរតែក្ស័យជីវិត ប៉ុន្តែ បើខ្លា ដោយអាងថា អញជាអ្នកខ្លាំងពូកែ

ហើយដេកសម្ងំស្ងៀម ហាមាត់ចង្រ្គិនដើម្បីឲ្យសត្វឯទៀតបោលមកចូលក្នុងមាត់ឲ្យជាអាហាររបស់ខ្លួននោះ ប្រាកដជាគ្មានសត្វណាមួយព្រមសុខចិត្តតែទៅចូលក្នុងមាត់ខ្លាឲ្យស្លាប់ខ្លួនទទេ ៗ នោះឡើយ ខ្លានោះ លុះតែមានកាយវិការប្រកបដោយព្យាយាមខំស្វែងរកផង ទើបបានសត្វនោះ ៗ មកជាអាហាររបស់ខ្លួន យ៉ាងណាមិញ ឯចំណេះវិជ្ជាក្តី ភោគទ្រព្យក្តី ក៏ដូច្នោះដែរ លុះតែយើងខំរៀន ខំស្វែងរកផង ទើបអាចសម្រេចប្រយោជន៍គ្រប់យ៉ាងដូចគេទៅបាន ។

បើខាងបព្វជិតវិញ ដែលបួសហើយត្រូវគិតថា ក្នុងពុទ្ធសាសនាមានធុរៈ ២ គឺ គន្ថធុរៈ ១ វិបស្សនាធុរៈ ១ ធុរៈទាំង ២ នេះ បព្វជិតត្រូវតែបំពេញទីងខានពុំបាន ។ គន្ថធុរៈ បានខាងបរិយត្តិដែលហៅថាព្រះត្រៃបិដកហ្នឹងឯង វិបស្សនាធុរៈ បានខាងសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ។ អាត្មាអញបានលះបង់ភេទឃរាវាស ហើយចូលមកធ្វើជាភេទបព្វជិត (អ្នកបួស) យ៉ាងនេះ តើអាត្មាអញ បានរៀនគន្ថធុរៈហើយឬទេ ទាំងវិបស្សនាធុរៈសោតទៀត បានបំពេញហើយឬនៅទេ ៗ បើអាត្មាអញមិនបានបំពេញធុរៈទាំង ២ នោះ ធុរៈណាមួយសោះទេ បណ្តោយខ្លួនឲ្យនៅទំនេរ ជាមនុស្សល្ងង់ខ្លៅដូច្នេះ ហើយក្រាញនៅធ្វើជាអ្នកបួសល្ងង់បែបនេះតទៅទៀត ក្រែងមានលោកអ្នករៀនសូត្រចេះដឹងច្រើនទាំងបព្វជិតទាំងគ្រហស្ថ គេមើលមកឃើញ ដឹងថាអាត្មាអញជាមនុស្សល្ងង់មិនដឹង

ការខុសត្រូវ តើអាត្មាអញគួរអៀនខ្មាសគេដែរឬទេ ? សីលទាំង ៤ មានបាតិមោក្ខសំវរសីលជាដើម សិក្ខាបទក្នុងបាតិមោក្ខ ២២៧ សិក្ខាបទ មានបារាជិកសិក្ខាបទ ៤ ជាដើម ព្រមទាំងសិក្ខាបទក្រៅពីបាតិមោក្ខខ្លះទៀត ជាទីរបស់បព្វជិត ។ ត្រូវតែចេះចាំ ត្រូវតែកាន់ប្រព្រឹត្តតាម បើអាត្មាអញមិនបានរៀនសូត្រឲ្យចេះចាំទេ មិនស្គាល់សីល មិនស្គាល់សិក្ខាបទរបស់ខ្លួននោះថាដូចម្តេចខ្លះទេ តើអាត្មាអញគួរអៀនខ្មាសគេដែរឬទេ បណ្តាបច្ច័យទាំង ៤ មានចីវរបច្ច័យជាដើម បច្ច័យណាមួយដែលបព្វជិតបានមកអំពីបាបធម៌ ៥ យ៉ាង មានកុហនាជាដើមក្តី បានមកអំពីអនេសនៈ ២១ យ៉ាង មានវេជ្ជកម្ម (ធ្វើពេទ្យមើលជម្ងឺ ទាយទស់) ជាដើមក្តី បច្ច័យនោះឈ្មោះថាជារបស់មិនបរិសុទ្ធ ព្រោះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តហាមជាដាច់ខាត មិនឲ្យបព្វជិតប្រព្រឹត្តធ្វើសោះឡើយ បើអាត្មាអញនៅតែប្រព្រឹត្តធ្វើឲ្យកន្លងពុទ្ធបញ្ញត្តដូច្នោះ តើអាត្មាអញគួរអៀនខ្មាសគេអ្នកចេះដឹងដែរឬទេ បព្វជិត ទោះជាភិក្ខុសាមណេរប្រើប្រាស់ចីវរគឺស្បៀតដណ្តប់ ឲ្យជាបរិមណ្ឌល វេលានៅក្នុងវត្តត្រូវគ្រង វេលាចេញពីវត្តចូលទៅកាន់ភូមិគ្រហស្ថ ត្រូវតែឃុំឲ្យជាបរិមណ្ឌល ព្រមទាំងត្រូវពាក់ក្ខុំធង ខឹងខានពុំបាន បើអាត្មាអញមិនបានអើពើ យកចិត្តទុកដាក់ប្រព្រឹត្តតាមពុទ្ធបញ្ញត្តិនោះទេ តើអាត្មាអញគួរអៀនខ្មាសចំពោះគេអ្នកចេះដឹងដែរឬទេ ? ។

ការសិក្សារៀនសូត្រធម្មវិន័យឲ្យចេះដឹងដើម្បីប្រតិបត្តិតាមផ្ទាល់ខ្លួន ទាំងជួយដឹកនាំអ្នកដទៃមានឧបាសក-ឧបាសិកា ទាយក-ទាយិកាដើនវត្ត ជាដើមឲ្យគេចេះដឹង ដើម្បីប្រតិបត្តិតាមផង នេះជាករណីយកិច្ចរបស់បព្វជិតៗត្រូវតែធ្វើឲ្យមានខានពុំបាន បើអាត្មាអញមិនបានសិក្សារៀនសូត្រដោយខ្លួនឯងទាំងមិនបានដឹកនាំអ្នកដទៃឲ្យរៀនចេះដឹងផងទេ នាំគ្នាស្ងប់ហើយប្រកាន់តាមទំនៀមទម្លាប់ដែលតាំងៗ មកទាំងខុសទាំងត្រូវ តើអាត្មាអញដែលធ្វើជាមេបាគេក្នុងទីវត្តអារាមនីមួយៗ គួរអៀនខ្មាស់ចំពោះលោកអ្នកចេះដឹងទាំងឡាយដែរឬទេ ? នៅទីវត្តអារាមគេឯទៀត ខ្លះមានសាលារៀនធម្មវិន័យ ខ្លះមានសាលារៀនបាលីព្រះត្រៃបិដក ខ្លះមានទាំងសាលារៀនធម្មវិន័យ មានទាំងសាលារៀនបាលីព្រះត្រៃបិដកផង ឯទីវត្តអារាមរបស់អាត្មា គ្មានសាលារៀនណាមួយនឹងគេសោះ តើអាត្មាអញ គួរអៀនខ្មាសចំពោះជនដទៃដែលគេមើលមកឃើញដែរឬទេ ?

អគោចរ គឺទីដែលបព្វជិតមិនគួរចូលទៅរក មានវេសិយាគោចរជាដើម នឹងទីផ្សារ ព្រោះផ្សារជាទីប្រជុំសាធារណជនបរទេសជាដើម ឯជនបរទេសច្រើនជាអ្នកមិនជ្រះថ្លា មិនជឿមិនគោរពពុទ្ធសាសនាទេ បើនជាបព្វជិតកាន់ពុទ្ធសាសនា ត្រូវតែមានសំវរៈការសង្រួមប្រុងប្រយ័ត្នឲ្យដឹងថា ទីនេះគួរទៅ ទីនោះពុំគួរទៅ ទីកន្លែងណាដែលមានគេមើលងាយ គេមិនគោរព គេមិនជ្រះថ្លាចំពោះខ្លួនផងទេ ទីកន្លែងនោះពុំគួរបព្វជិតចូល

ទៅរកឡើយ បើអាត្មាអញបេះតែដើរទៅកាន់ទីពុំគួរមានទីផ្សារជាដើម គឺដើរជ្រៀតជ្រែកក្នុងហ្វូងជនប្រុសស្រី អើតងើតផ្ទៀងផ្ទង់សំឡឹងមើលរបស់នេះឬរបស់នោះ ជួនកាលក៏មានទិញដូររបស់នេះនោះខ្លះ មាននំបុ័ងជាដើម យួរយុងយោងដោយខ្លួនឯងតាំងពីថ្ងៃរសៀល បើមានជនសប្បុរសតាំងឡាយបេះធម៌វិន័យដឹងការគួរពុំគួរ គេឃើញអាត្មាអញប្រព្រឹត្តធ្វើដូច្នេះ តើអាត្មាអញគួរអៀនខ្មាសគេខ្លះដែរឬទេ ! ។ល។

សេចក្ដីដែលបានអធិប្បាយមកតាំងផ្នែកគ្រហស្ថតាំងផ្នែកបព្វជិតអំពីបទលោកាធិបតេយ្យដែលថាយកលោកជាធំ ឬ ជាប្រធានក្នុងមុខការប្រព្រឹត្តរបស់ខ្លួនដូចខាងលើនោះ ជាសេចក្ដីបរិយាយជាសង្ខេប គួរឲ្យបរិស័ទតាំងគ្រហស្ថតាំងបព្វជិត ពិចារណាក្នុងវេលាដែលរៀបនឹងធ្វើអ្វី ឬកំពុងធ្វើអ្វីមួយ ត្រូវនឹកគិតទៅដល់អ្នកដទៃជាមុនថា អំពើរបស់អាត្មាអញនេះ គេតិះដៀលឬគេសរសើរ សេចក្ដីនេះសមនឹងភាសិតបុរាណថា «បេះឯងឲ្យក្រែងបេះគេផង» ទើបកិច្ចការនោះៗ អាចឈានទៅរកសេចក្ដីត្រូវ សេចក្ដីចម្រើនរុងរឿង ។

## ធម្មាធិបតេយ្យ

ធម្មាធិបតេយ្យ ប្រែថា ភាពនៃបុគ្គលយកធម៌ជាអធិបតី ជាធំ ។ ពាក្យថាធម៌ក្នុងទីនេះ សំដៅយកច្បាប់គឺច្បាប់ខាងផ្លូវលោក និងច្បាប់

ខាងផ្លូវធម៌ ៗ ច្បាប់ខាងផ្លូវលោក បានដល់ច្បាប់ដែលរាជរដ្ឋាភិបាល មានព្រះមហាក្សត្រិយ៍ជាប្រមុខ បានតែងតាំងបញ្ញត្តឡើងសម្រាប់ប្រទេសដើម្បីឲ្យប្រជាពលរដ្ឋគោរពប្រតិបត្តិតាម ឲ្យមានសណ្តាប់ធ្នាប់រៀបរយ ៗ ច្បាប់ខាងផ្លូវធម៌ បានដល់ពុទ្ធោវាទ គឺធម៌និងវិន័យ ដែលព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ហើយទ្រង់បានបញ្ញត្ត បានសម្តែងតែងតាំងទុកមក ដើម្បីឲ្យសត្វលោកទូទៅគោរពប្រតិបត្តិតាម និងបានទទួលនូវប្រយោជន៍ និងសេចក្តីសុខ ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក ។

សូមអធិប្បាយសេចក្តីក្នុងបទធម្មាធិប្បតេយ្យដោយសេចក្តីរួបរួមដូចតទៅនេះ ៖

បុគ្គលជាគ្រហស្ថក្តី ជាបព្វជិតក្តី កាលបើប្រាថ្នាធ្វើកិច្ចការអ្វីមួយ ត្រូវគោរពដល់ធម៌ គឺច្បាប់ ឲ្យដឹងថា ការនេះគួរឬមិនគួរ ត្រូវឬខុសជាមុនសិន ដើម្បីរក្សាទុកនូវសេចក្តីល្អរបស់ខ្លួនកុំឲ្យសាបរលាបវិនាសបាត់ទៅ ប្រៀបដូចជាអំបិល ធម្មតាអំបិល ជាធម្មជាតិមានរសប្រៃតែម៉្យាង បើទុកជាគេយកទៅលាយឲ្យប្រឡូកប្រឡល់ជាមួយនឹងវត្ថុផ្សេង ៗ មានរសផ្អែម ល្វីង ជូរ ចត់ ជាដើម អំបិលក៏មិនព្រមប្រែក្លាយទៅតាមវត្ថុទាំងនោះឡើយ គឺនៅតែរក្សារសប្រៃរបស់ខ្លួនទុកដដែល យ៉ាងណាមិញ បុគ្គលណាមួយ ទោះធ្វើកិច្ចការអ្វីដែលជាប្រយោជន៍សាធារណៈក្តី ជា

ប្រយោជន៍ចំពោះខ្លួនក្ដី ត្រូវបេះពិនិត្យពិច័យផ្ចិតផ្ចង់តម្រង់ទៅតាមច្បាប់ មិនឲ្យយឿងឃ្លាត ទាំងមិនអើពើដល់ពាក្យនិន្ទា និងពាក្យសរសើររបស់អ្នកដទៃផងទេ បុគ្គលនោះ ទើបហៅថាជាអ្នករក្សាសេចក្ដីល្អរបស់ខ្លួនទុកមិនឲ្យសាបរលាបបាត់ទៅ ក៏ដូច្នោះដែរ ។ មួយយ៉ាងទៀត បុគ្គលអ្នកប្រាថ្នាតែសេចក្ដីល្អ ដើម្បីខ្លួន និងអ្នកដទៃ ត្រូវតែញ៉ាំងកាយ វាចា ចិត្ត ឲ្យប្រព្រឹត្តទៅតាមច្បាប់ ហើយពុំញញើត កុំតក់ស្លុតខ្លាចចំពោះឧបសគ្គផ្សេង ៗ ដែលកំពុងកើតឡើង ឬដែលប្រុងនឹងកើតឡើងក្នុងកាលខាងមុខក៏ដោយ ត្រូវតែអត់ទ្រាំតស៊ូជាដរាប ទើបរកសេចក្ដីល្អនោះឃើញ ព្រោះថា ធម្មតា ការធ្វើសេចក្ដីល្អឬការស្វែងរកសេចក្ដីល្អ ចួនកាលក៏ប្រព្រឹត្តទៅបានដោយស្រួល ចួនកាលក៏ពុំបានដោយស្រួល គឺរមែងជួបប្រទះនឹងឧបសគ្គអ្វីមួយពុំខាន នេះជាធម្មតារបស់អ្នកធ្វើសេចក្ដីល្អ ត្រូវតែអធិដ្ឋានតាំងចិត្តទុកជាមុនថា អាត្មាអញបើទុកណាជាគេយកទ្រព្យ ឬយកយស័ក្ដិជាដើមមកប្រលោមប្រគល់ឲ្យក្ដី ពុំនោះសោត គេយកអំណាចមកប្រើគម្រាមផ្ដាញ់ផ្ដាលក្ដី ដើម្បីបំបែរឲ្យងាកចេញពីសេចក្ដីល្អរបស់ខ្លួននោះក៏ដោយ បុគ្គលអ្នករក្សាសេចក្ដីល្អ កុំគប្បីវិបល្លាសក័ន្ទត់ទិត ទៅត្រេកអរនឹងរបស់ទាំងនេះ ឬតក់ស្លុតខ្លាចអំណាចនោះឡើយ ត្រូវតែជំនះឈ្នះគន្លងឧបសគ្គផ្សេង ៗ នោះឲ្យបានដរាប ទើបបានឈ្មោះថាជាអ្នករក្សាសេចក្ដីល្អរបស់ខ្លួនទុកបាន បើមិនដូច្នោះទេ និងរក្សាសេចក្ដីល្អ

របស់ខ្លួនទុកឲ្យបានគ្រប់គ្រាន់តាមកាលកំណត់ពុំបានឡើយ ប្រៀបដូចផ្កាឈូក ធម្មតាផ្កាឈូក ទុកជាដុះចេញមកពីភក់ជ្រាំគ្រឿងសំអុយស្មោកគ្រោកយ៉ាងណាក៏ដោយ ផ្កាឈូកនៅតែរក្សាលំអនិងខ្លួនក្រអូបរបស់ខ្លួនទុកដដែល មិនព្រមប្រែក្លាយទៅតាមគ្រឿងសំអុយនោះឡើយ យ៉ាងណាមិញ បុគ្គលដែលមានឧត្តមគតិយល់ច្បាស់នូវសេចក្ដីល្អ និងសេចក្ដីអាក្រក់ហើយ បើទុកជាទៅនៅក្នុងចំណោមមនុស្សទុច្ចរិតប្រព្រឹត្តអាក្រក់យ៉ាងណា ក៏មិនព្រមលះបង់សុចរិត (ការប្រព្រឹត្តល្អ) របស់ខ្លួនចោលហើយក្លាយទៅតាមមនុស្សទុច្ចរិតនោះឡើយ គឺនៅតែរក្សាឧត្តមគតិរបស់ខ្លួន ទុកឲ្យគង់វង់នៅដដែលក៏ដូច្នោះដែរ ។

សេចក្ដីអធិប្បាយអំពីអធិបតេយ្យ ៣ យ៉ាង

ទាំងខាងគតិធម៌ ទាំងខាងគតិលោក ចប់ដោយសង្ខេប ។

# ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៊ូ រៀបរៀង

តមក

## កដត្តាកម្ម

ឯតេហិ បន តីហិ វិមុត្តំ អញ្ញាណាវសេន កតំ កដត្តា វា បន កតំ នាម តំ យថា នាម ឧម្មត្តកេន ខិត្តំ ទណ្ឌំ យត្ថ វា តត្ថ វា គច្ឆតិ ឯវមេវ តេសំ គរុកាទីនំ អភាវេន យត្ថកត្ថចិ វិបាកំ ទេតិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងកម្មប្បច្ច័យ អធិប្បាយនូវកដត្តាកម្ម តទៅ ដំណើរសេចក្តីថា ឯតេហិ បន តីហិ វិមុត្តំ កម្មដែលឈ្មោះថា «កដត្តាកម្ម» នោះ សំដៅយកទាំងពីរខាង គឺ ទាំងខាងកុសល ទាំងខាងអកុសល ដែលផុតអំពីកម្ម ៣ ប្រការ គឺ គរុកម្ម ១ ពហុលកម្ម ១ យថាសន្នកម្ម ១ ។

កដត្តាកម្មនោះ សំដៅយកតែត្រង់ការធ្វើ មិនបានដឹងថាជាកម្មខាងកុសល ឬ ខាងអកុសលទេ ប្រៀបដូចកំណាត់ឈើដែលមនុស្សឆ្កួតគ្រវែងចោលទៅ ធម្មតាកំណាត់ឈើដែលមនុស្សឆ្កួតគ្រវែងចោលទៅ

នោះ រមែងធ្លាក់ចុះទីណាមួយមិនខាន ប៉ុន្តែ គប្បីដឹងថានឹងធ្លាក់ចុះលើប្រថពី គ្រាន់តែមិនអាចកំណត់បានថានឹងធ្លាក់ចុះក្នុងទីនោះឬទីនេះប៉ុណ្ណោះ សេចក្តីនេះមានឧបមាដូចម្តេច កតត្តាកម្មនោះ ក៏កំណត់កាលដែលនឹងឲ្យផលមិនបាន គប្បីកំណត់បាន តែថានឹងឲ្យផលក្នុងភពណាមួយប៉ុណ្ណោះ ដូចជាកំណាត់ឈើដែលមនុស្សក្ដួតគ្រវែងចោលទៅដូច្នោះ ៗ បុគ្គលអ្នកធ្វើកតត្តាកម្មនោះ មិនដឹងថាជាកុសលឬជាអកុសលទេ ដូចទារកមិនទាន់ដឹងក្តី មាតារបស់ខ្លួនប្រាប់ឲ្យសំពះសង្ឃ ឬចាប់ដៃឲ្យដាក់បាត្រ ប្រាប់ឲ្យភាវនាធម៌ ទារកនោះក៏ធ្វើតាមមាតា ៗ បើមិនធ្វើដូច្នោះទេ ឧបមាដូចសុវបោតកៈកូនសេកឬកូនសារិកាម្ចាស់វាបង្ហាត់ឲ្យវាភាវនា វាក៏ថាទៅតាមម្ចាស់ វាមិនដឹងថាជាបាបឬជាបុណ្យសោះឡើយ ៗ បើនិយាយពីខាងអកុសលវិញ ដូចកូនក្មេងតូចដែលម្តាយពនៅចង្កេះ ជួនកាលវាក្តិចខ្ញាំវាយម្តាយវា ៗ មិនដឹងថាជាបាបឬជាបុណ្យទេ ប៉ុន្តែ អកុសលកម្មដែលវាធ្វើរួចហើយនោះ រមែងឲ្យផលដែលជាបាបធ្វើរួចហើយ គ្មានឲ្យផលនោះពុំមែនទេ គឺឲ្យផលជាមិនខាន គ្រាន់តែកំណត់កាលដែលនឹងឲ្យផលនោះ មិនបានប៉ុណ្ណោះ ព្រោះថាកម្មនោះមិនសូវខ្លាំងក្លា មិនសូវធ្ងន់ពេក ៗ

មានពាក្យបុច្ឆាថា កឹ ឋានច្ឆេទ កាតំ ៣ កុសលនិងអកុសលទាំងពីរប្រការនេះ បើអ្នកដឹងហើយធ្វើ និងអ្នកមិនដឹងធ្វើនោះ

តើខាងណាទីងមានផលច្រើនជាងខាងណា ខាងអ្នកដឹងហើយធ្វើ មានផលច្រើន ឬក៏ខាងអ្នកមិនដឹង ធ្វើ មានផលច្រើន ?

មានពាក្យវិសជ្ជនាថា ចំណែកខាងបុណ្យកុសលនោះ អ្នកដឹងហើយធ្វើ បានផលានិសង្សច្រើន បើអ្នកមិនដឹងធ្វើ បានផលានិសង្សតិចៗ ចំណែកខាងបាបអកុសលវិញ អ្នកមិនដឹង ធ្វើបាប បានបាបច្រើន បើអ្នកដឹង ធ្វើបាប បានបាបតិច ៗ

មានពាក្យបុច្ឆាថា ចំណែកខាងបុណ្យកុសល ហេតុអ្វីបានជាអ្នកដឹងថាបុណ្យកុសល ហើយធ្វើ បានផលានិសង្សច្រើន ព្រោះហេតុដូចម្តេច បើអ្នកមិនដឹង ធ្វើ បានផលានិសង្សតិច ព្រោះហេតុដូចម្តេច ?

មានពាក្យវិសជ្ជនាថា អ្នកដឹងថាជាបុណ្យកុសលហើយធ្វើ បានផលានិសង្សច្រើននោះ ព្រោះហេតុថា មនុស្សចូលចិត្តទីងឲ្យទានរបស់អ្វី ក៏ឲ្យជាសប្បុរិសទាន ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងកាលទាំងបី បើទីងឲ្យភោជនាហារ ក៏ឲ្យតែវត្ថុដែលល្អថ្លៃថ្លា ឲ្យតែវត្ថុដែលខ្លួនពេញចិត្ត ហើយធ្វើឲ្យជាសាមីទាន ប្រសើរ ជាងរបស់ដែលខ្លួនបរិភោគៗ

ពាក្យដែលថា ឲ្យជាសប្បុរិសទាននោះ គឺឲ្យដោយដៃនៃខ្លួន មិនបានបោះឲ្យ ឲ្យសមគួរដល់សមណៈៗ ឆាន់គ្មានអាបត្តិ ទីងឲ្យដោយសទ្ធាជឿកម្មជឿផល កាលទីងធ្វើកុសល តែងយកព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណជាអារម្មណ៍ កាលទីងបំពេញទាន មិនបាន

សង្កត់សង្កិនប្រមាថមើលងាយ អ្នកទទួលរម្ងាប់ចិត្តឲ្យផុតចាកលោភៈ ទោសៈ និងមោហៈ តែងគោរពទានរបស់ខ្លួន និងគោរពអ្នកទទួលទាន ។

ពាក្យដែលថាឲ្យទាន ដោយចិត្តជ្រះថ្លាក្នុងកាលទាំងបីនោះគឺ បុព្វចេតនា មុនពីពេលមិនទាន់ឲ្យ ចេះតែគិតនឹងឲ្យ ក៏មានចិត្តជ្រះថ្លា ១ មុញ្ចនចេតនា កាលកំពុងឲ្យ ក៏មានចិត្តជ្រះថ្លា ១ អបរាបរចេតនា ឲ្យរួចហើយ នឹករលឹកឃើញ ក៏មានចិត្តជ្រះថ្លា ១ ។

បុគ្គលធ្វើការកុសលគឺឲ្យជាសប្បុរិសទាន ក៏មានផលានិសង្សច្រើន នឹងបំពេញទាន ការកុសល ដោយអំណាចនៃចេតនាទាំងបីនោះ គឺរមែងមានផលជាអស្ចារ្យ ។ ឯបុគ្គលអ្នកមានបញ្ញា ដោយហោចទៅ សូម្បីគ្រាន់តែស្តាប់ព្រះធម៌ទេសនា ក៏ប្រកបដោយចេតនាទាំងបីដែរ គឺគិតនឹងស្តាប់ក៏មានចិត្តជ្រះថ្លា ១ កំពុងស្តាប់ក៏មានចិត្តជ្រះថ្លា ១ ស្តាប់រួចហើយ នឹករឭកឃើញវេលាណា ក៏មានចិត្តជ្រះថ្លា ១ ។ ហេតុនោះ បានជាឆ្លើយថា បុគ្គលអ្នកស្គាល់បុណ្យស្គាល់បាប ធ្វើបុណ្យ បានបុណ្យច្រើន ធ្វើបាប បានបាបតិច ។

បុគ្គលអ្នកស្គាល់បាប ធ្វើបាប ហើយបានបាបតិចនោះគឺថា មនុស្សទាំងឡាយបបួលគ្នាទៅធ្វើបាប មានសួចត្រីជាដើម អ្នកចេះដឹង ស្គាល់បាបជួនកាល មិនព្រមទៅជាមួយនឹងគេទេ ប៉ុន្តែសូមឲ្យបានចំណែកខ្លះ មិនសម្លាប់នឹងដៃខ្លួនឯង គ្រាន់តែពោលវាចា បើទុកណាជាសម្លាប់ ក៏សម្លាប់

តែសត្វតូច ៗ បាបតិច ប្រៀបដូចអ្នកដឹងថាភ្លើងក្តៅ បើទឹងចាប់ក៏ថ្នម ចៀចចាប់មិនប្រមាទ ។ ហេតុនោះ អ្នកដឹងថាបាប ហើយធ្វើបាបទើបបាបតិច ព្រោះមានបញ្ញា ។

មនុស្សមិនស្គាល់បុណ្យនឹងបាប ធ្វើបុណ្យបានបុណ្យតិចនោះព្រោះហេតុថាទឹងធ្វើបុណ្យឲ្យទាន ក៏ជាអសប្បុរសទានគឺបោះឲ្យ គ្រវែងចោលទៅឲ្យ ប្រើឲ្យអ្នកបម្រើធ្វើ មិនជឿកម្ម មិនជឿផល មិនគោរពអ្នកទទួលទាន មិនគោរពចំពោះវត្ថុទានរបស់ខ្លួន បើទឹងរក្សាសីល ក៏រក្សាសីលរបស់បុគ្គលជាពួកតិរិយ៍មិត្រ បើទឹងស្តាប់ព្រះធម៌ទេសនាក៏ឥតគោរព គឺអ្នកខ្លះសណ្តូកជើងស្តាប់ ទឹងចិត្តមិនតាំងមាំ អង្គុយនិយាយគ្នាបណ្តើរស្តាប់បណ្តើរ អ្នកខ្លះយកខាទនីយភោជនីយាហារទៅបរិភោគ នៅពេលកំពុងស្តាប់ធម៌ទេសនា ។ ការស្តាប់ដោយកិរិយាដូច្នេះឈ្មោះថាពាំងព្រះសទ្ធម្មឲ្យអន្តរធាន ព្រោះគ្មានបញ្ញា មិនដឹងការបុណ្យនឹងការបាប ។ ហេតុនោះ បានជាឆ្លើយថា បុគ្គលមិនដឹងថាបុណ្យនឹងបាបនោះ ធ្វើបុណ្យបានបុណ្យតិច ព្រោះប្រព្រឹត្តកិរិយាដូចពោលខាងដើម ។

បុគ្គលមិនស្គាល់បាប ធ្វើបាបបានបាបច្រើននោះ ព្រោះហេតុមិនដឹងជាបាប មិនដឹងអំពើណាថាជាកម្មធ្ងន់ ក៏ទឹងធ្វើនូវកម្មដ៏ធ្ងន់នោះ ប្រៀបដូចសត្វមមាច មិនដឹងថាភ្លើងហើយ ហើរចូលគំនរភ្លើង ក៏ស្លាប់ទៅ ។

ម្យ៉ាងទៀត បុគ្គលមិនដឹងថាបាបនោះ ប្រៀបដូចជាមនុស្សមិនដឹងថាគំនរភ្លើងនៅកណ្តាលផ្លូវ ខ្លួនដើរទៅជាន់លើគំនរភ្លើងនោះពេញ

ដើម ៗ ក៏រលាករលួយ ពុះពន់ទៅជាដំបៅឲ្យបានរងទុក្ខវេទនា ។ ហេតុនោះ បានជាឆ្លើយថា បុគ្គលមិនដឹងបាប ធ្វើបាបបានបាបច្រើន ។ ឯអកុសលនោះរមែងឲ្យផល គឺញុំាងសត្វឲ្យបានសោយទុក្ខក្នុងអបាយទាំងបួន មាននរកជាដើម ។ កុសលកម្មរមែងឲ្យផលប្រកបដោយសេចក្តីសុខ គឺសេចក្តីសុខក្នុងមនុស្ស សេចក្តីសុខក្នុងស្ថានសួគ៌ និងសេចក្តីសុខក្នុងព្រះនិព្វាន ។

មានពាក្យបុច្ឆាថា បើបុគ្គលកំពុងតែសោយផលនៃកុសលកម្ម ចុះផលនៃអកុសលកម្ម ទៅនៅចាំក្នុងទីណា ទើបថាបុគ្គលបានធ្វើកុសលនិងអកុសលរួចហើយ មិនដែលខានសោយផលនៃកុសលនិងអកុសលកម្មនោះទេ ។ ម្យ៉ាងទៀត កាលបុគ្គលកំពុងសោយផលនៃអកុសលកម្ម ចុះផលនៃកុសលនោះ តើទៅនៅចាំក្នុងទីណា ?

មានពាក្យវិសជ្ជនាថា ប្រៀបដូចដើមឈើមានមែក មានស្លឹកល្អបរិបូណ៌ហើយត្រូវតែមានផ្លែ បុគ្គលមិនអាចចង្អុលប្រាប់ថាផ្លែនៅត្រង់មែកនេះឬមែកនោះបានទេ មានឧបមាដូចម្តេច ឯផលនៃកុសលនិងអកុសលកម្មនោះ បើបុគ្គលបានធ្វើរួចហើយ ក៏ត្រូវតែមាន មិនដែលគ្មានផលទេ មានឧបមេយ្យដូច្នោះ ។

កតត្តាកម្មនោះ សំដៅយកត្រង់បុគ្គលធ្វើ គឺធ្វើកុសលកម្មនិងអកុសលកម្មទាំងពីរចំណែក ប៉ុន្តែ ក្នុងពេលធ្វើនោះ មិនដឹងថាខ្លួនធ្វើកុសលកម្មឬអកុសលកម្មទេ ផលក៏មាន ប៉ុន្តែ កំណត់កាលមិនបាន លុះតែ

កាលណាគ្មានគរុកកម្ម គ្មានពហុលកម្ម និងគ្មានយថាសន្នកម្ម ទាំងបីប្រការនេះទេ កតត្តាកម្មទើបឲ្យបដិសន្ធិសម្រេចផល ។ ហេតុនោះកម្មនោះ សម្តេចព្រះបរមទសពល ទើបត្រាស់ទេសនាថាជាបច្ច័យក្នុងបច្ច័យ ២៤ ប្រការ ។

## កតត្តាកម្ម សង្ខេបប៉ុណ្ណោះ ។

## ៨ – ជនកកម្ម

លំដាប់នេះ សូមវិសជ្ជនាក្នុងកម្មបច្ច័យ អធិប្បាយនូវជនកកម្មតទៅ មានសេចក្តីថា កម្មឯណាញុំាងបដិសន្ធិឲ្យកើត គឺញុំាងលំដាប់នៃបញ្ចក្ខន្ធឲ្យកើតតែម្យ៉ាងប៉ុណ្ណោះ ជាភ្នាក់ងារតែខាងញុំាងបដិសន្ធិឲ្យកើតម្យ៉ាង កម្មនោះឈ្មោះថា ជនកកម្ម ។

បវត្តេ អញ្ញំ កម្មដទៃក៏ឲ្យផលក្នុងបវត្តិកាលតទៅ យថា មាតា ជនកកម្មនោះប្រៀបដូចមាតា ។ តែងញុំាងបុត្រធីតាឲ្យកើតតែម្យ៉ាងប៉ុណ្ណោះ លុះបុត្រធីតាកើតរួចហើយ ស្រីបម្រើក៏យកទៅចិញ្ចឹមទុកៗ ស្រីបម្រើយកចិត្តទុកដាក់ទំនុកបម្រុងថែរក្សា សេចក្តីនេះមានឧមាដូចម្តេច ។ ជនកកម្ម ជាភ្នាក់ងារឲ្យកើតតែម្យ៉ាង មិនមែនជាភ្នាក់ងារចិញ្ចឹមថែរក្សាទេ មានឧបមេយ្យដូច្នោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានយ៉ាងនេះចុះ ។

## ជនកកម្ម សង្ខេបប៉ុណ្ណោះ

# អំពីអ្នកបរិភោគកាម ១០ ពួក

ឧបាសកវគ្គទី ៥ ទំព័រ ៤៥ អង្គុត្តរនិកាយ

ទសកនិបាត

---

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក៏អង្គុយ ក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី បានអង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី អ្នកបរិភោគកាមនេះ មាន ១០ពួក ក្នុងលោក ។ ១០ពួក តើដូចម្ដេចខ្លះ ? ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកនូវភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគទាំងឡាយនោះបានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកនូវភោគទាំងឡាយ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែមិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគទាំងឡាយ

មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគ
ទាំងឡាយ មិនត្រូវតាមគន្លងធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខឲ្យឆ្អែត
ទាំងចែករំលែក ធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ
មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ
មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេ ក៏មាន មិនកំហែងសង្កត់
សង្កិនគេក៏មាន លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ
មិនត្រូវត្រូវតាមគន្លងធម៌ខ្លះ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យ
ឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ១ ។ ម្នាលគហបតីក្នុងលោក
នេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លង
ធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែង
សង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លង
ធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត
តែទាស់មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី
ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគទាំងឡាយ ត្រូវ
តាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន
មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាម
គន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ បានមកហើយ ធ្វើខ្លួនឲ្យបាន
សុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី

ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ១ ៗ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែទាស់ មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ១ ៗ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ តែនៅ ជក់ ជ្រប់ ឈ្លក់ចិត្តនឹងភោគទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយបេះតែបរិភោគៗ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវគន្លងធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគទាំងនោះទេ ឃើញទោស មានបញ្ញា

ជាគ្រឿងរើខ្លួន ហើយបរិភោគ ១ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ បានមកហើយ មិនធ្វើខ្លួន ឲ្យបានសុខ ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ៣ ប្រការ គឺគេតិះដៀល ដោយហេតុទី ១ ថាស្វះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ ថា មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គួរគេតិះដៀល ដោយហេតុទី ៣ ថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែតតែទាស់ មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ២ ប្រការ គេសរសើរដោយហេតុ ១ ប្រការ គឺគេតិះដៀល ដោយហេតុទី ១ ថា ស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុ ១ ប្រការថា ចេះធ្វើខ្លួន ឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀល

ដោយហេតុទី ២ ថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ១ ប្រការ គេសរសើរដោយហេតុ ២ ប្រការ គឺគេតិះដៀល ដោយហេតុ ១ ប្រការថា ស្វះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុទី ១ ថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេសរសើរ ដោយហេតុទី ២ ថា ចេះចែករំលែក ធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ១ ប្រការ គេតិះដៀល ដោយហេតុ ៣ ប្រការ គឺគេសរសើរដោយហេតុ ១ ប្រការ

ថា ស្ទះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ១ ថា ស្ទះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ ថា មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀលដោយហេតុទី ៣ ថា មិនចេះចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណាស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្ទះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែតាស់មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុ ២ ប្រការ គេតិះដៀលដោយហេតុ ២ ប្រការ គឺគេសរសើរដោយហេតុទី ១ ថា ស្ទះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ១ ថា ស្ទះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ ថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀល ដោយហេតុទី ២ ថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគ

កាមណា ស្វះស្វែករកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែកធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ៣ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ គឺគេសរសើរ ដោយហេតុទី ១ ថា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី១ ថា ស្វះស្វែងរកភោគទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ ថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេសរសើរដោយហេតុទី ៣ ថា ចេះចែករំលែក ធ្វើបុណ្យទាំងឡាយ ៗ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែមិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ២ ប្រការ គេតិះដៀល ដោយហេតុ ១ ប្រការ គឺគេសរសើរដោយហេតុទី ១ ថា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរ

សើរដោយហេតុទី ២ ថា ចេះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀល ដោយហេតុ ១ ប្រការថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ តែនៅជក់ជ្រប់ ល្មក់ចិត្តនឹងភោគទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ៣ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការ គឺគេសរសើរ ដោយហេតុទី ១ ថា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុទី ២ ថា ចេះធ្វើខ្លួន ឲ្យបានសុខ ឲ្យឆ្អែត គេសរសើរ ដោយហេតុទី ៣ នេះថា ចេះចែករំលែក ធ្វើបុណ្យទាំងឡាយ គេតិះដៀល ដោយហេតុ ១ ប្រការថា ជក់ជ្រប់ ល្មក់ចិត្តនឹងភោគទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែង សង្កត់សង្កិនគេ បានមក

ហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែកធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ៤ ប្រការ គឺគេសរសើរ ដោយហេតុទី ១ ថា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុទី ២ ថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេសរសើរដោយហេតុទី ៣ ថា ចែករំលែក ធ្វើបុណ្យទាំងឡាយ គេសរសើរ ដោយហេតុទី ៤ ថា មិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ⑦ ម្នាលគហបតី អ្នកបរិភោគកាមទាំង ១០ ពួកនេះ មានក្នុងលោក ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគទាំងឡាយ ត្រូវតាមគន្លងធម៌ បានមកហើយ ធ្វើខ្លួនឲ្យសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្លក់ចិត្ត នឹងភោគទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមនេះ ឈ្មោះថាជាកំពូលផង ប្រសើរផង បម្យងផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង ។ ម្នាលគហបតី

ដូចជាទឹកដោះស្រស់ កើតពីមេគោ ទឹកដោះជូរ ក្លាយពីទឹកដោះស្រស់ ទឹកដោះខាប់ ក្លាយពីទឹកដោះជូរ ទឹកដោះភាវ ក្លាយពីទឹកដោះខាប់ ទឹកដោះថ្លា ក្លាយពីទឹកដោះភាវ ទឹកដោះថ្លា ប្រាកដ ប្រសើរជាងទឹកដោះទាំងនោះ យ៉ាងណាមិញ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគទាំងឡាយត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ តែមិនជក់មិនជ្រប់ មិនល្មក់ចិត្តនឹងភោគទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ឈ្មោះថាជាកំពូលផង ប្រសើរផង ចម្បងផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង យ៉ាងនោះឯង ។

---

> នរជនដែលធ្លាក់ខ្លួន ទៅក្នុងគ្រោះកាច តែងតែបន្ទោស ព្រេងវាសនា មនុស្សល្ងង់ មិនព្រមទទួលកំហុស ដែលខ្លួនធ្វើទេ
>
> — ហិតោបទេស

# សេរីភាព (វិចារណកថា)

ដោយលោក ដេង-ជ្រីវ

សេរីភាព គឺភាពដែលមានសេរី ដែលអាចធ្វើអ្វីបានតាមបំណង តាមសេចក្តីត្រូវការរបស់ខ្លួន ៗ អ្វីក៏ដោយ ដែលមានជីវិត សុទ្ធសឹង មានសេរីភាព : មនុស្សមានសេរីភាព តិរច្ឆានមានសេរីភាព រុក្ខជាតិ ក៏មានសេរីភាពដែរ ៗ ប៉ុន្តែ សេរីភាពមានធំ មានតូច មានក្បៀប អាស្រ័យទៅតាមសមត្ថភាពនៃបុគ្គលម្នាក់ ៗ នៃគ្រួសារ នៃសង្គម នៃប្រទេសនីមួយ ៗ ៗ នេះឯងហើយ ជាសេរីភាពធម្មជាតិ ៗ

ដើម្បីការពារកុំឲ្យសេរីភាពមួយរីកខ្លាំងពេក ទៅជាន់លើសេរីភាពមួយ ទើបបង្កើតច្បាប់មួយហៅរដ្ឋធម្មនុញ្ញ សម្រាប់ប្រទេស ៗ មានមាត្រាមួយក្នុងរដ្ឋធម្មនុញ្ញចែងថា គ្រប់មនុស្សត្រូវមានសេរីភាព គឺថា មនុស្សអាចធ្វើអ្វីបានតាមបំណង តែសូមកុំឲ្យតែ អំពើនេះផ្ទុយនឹងច្បាប់សាធារណៈ ហើយធ្វើឲ្យប៉ះពាល់ដល់សេរីភាពនៃជនដទៃ ៗ ដូច្នេះហើយ ទើបមនុស្សសម័យឥឡូវ មានសភាពផ្សេងពីមនុស្សសម័យមុន ៗ វិឌ្ឍភាពនិងចិត្តគំនិតនៃមនុស្សជំនាន់មុនដោយយ៉ាង វិឌ្ឍភាពនិងចិត្តគំនិតនៃមនុស្សជំនាន់នេះដោយយ៉ាង ៗ ឯការថ្កុក ទៅត្រង់មនុស្សសម័យមុន មិនសូវមានបរិយាកាសដ៏ទូលំទូលាយ ដូចមនុស្សបច្ចុប្បន្ន ៗ ដូចការសិក្សា កាលពីដើម មនុស្សភាគច្រើនណាស់

ដែលមិនចេះអានទឹងសរសេរអក្សរ ។ ឯការមិនចេះនេះ បណ្ដាលមកពីការ ខ្ជិលឬដូចម្ដេច ? តាមការសង្កេត ចំពោះសំនួរនេះ ទឹងជាមកពីការខ្ជិល ក៏បាន ជាមកពីមិនសូវមានសេរីភាពក៏បាន ជាមកពីខ្វះសាលារៀនក៏ បាន បើពោលដោយសរុប ជាមកពីការខ្មាក់ចិត្ត បានសេចក្ដីថា មនុស្សភាគច្រើន និយមចូលចិត្តថា បើរៀនចេះទៅ មិនដឹងបានទៅជាអ្វីៗ អំពីមុខការពេជការវិញ ប្រសិនបើខ្វះបន់ធ្វើ ក៏មិនងាយនឹងអាចធ្វើបាន លុះតែជាប់សែស្រឡាយខាងនាម៉ឺន ឬទៅផ្គាប់គុណនាម៉ឺននោះ ទើប មានផ្លូវសង្ឃឹមខ្លះ ។ ម៉្លោះហើយ ត្រូវដាក់ធុរៈថា ធ្វើការរកទទួលមាន តែម្ដងទៅ ជាការស្រេច ។

ចំណែក សម័យបច្ចុប្បន្ន ទិដ្ឋភាពផ្ទុយស្រឡះពីសម័យមុន : សាលារៀនមានបរិបូណ៌ មនុស្សមានសេរីភាពពេញទំហឹង បើចង់ ចូលធ្វើអ្វី ក្នុងវិស័យណា គឺចូលបានតាមចិត្ត ឲ្យតែខ្លួនមានសមត្ថភាពគ្រប់ គ្រាន់ ហើយគេត្រូវការផង ។ ដូច្នេះហើយ ទើបទេសភាពទឹងទិដ្ឋ ភាពឥឡូវ ជាទីចាប់អារម្មណ៍ពន់ពេក ។

សួរថា ទិដ្ឋភាពដ៏ជាទីចាប់អារម្មណ៍នេះ មានបហូរហែគ្រប់មជ្ឈដ្ឋាន ទាំងអស់ ឬដូចម្ដេច ?

ឆ្លើយថា បើតាមការសង្កេត មិនមែនមានគ្រប់មជ្ឈដ្ឋានទាំងអស់ ឡើយ ទោះបីមានរដ្ឋធម្មនុញ្ញក៏ដោយ ផ្សិតសេរីភាពលេបសេរីភាព ។

ដែលថា «សេរីភាពលេចសេរីភាព» សំដៅយកត្រង់ចំណុចសេរីភាពម្នាក់ មានអានុភាពខ្លាំង រីកគ្របប្អៀតបាត់ខ្លួសេរីភាពម្នាក់ គួយាំងដូចដើមឈើតូច ដុះក្បែរដើមឈើធំ ដើមឈើតូចនេះ ត្រូវតែនៅរេញតទៅ ។

គេអាចប្រៀតមកទៀតថា ហេតុដូចម្តេចក៏ខ្លួនមិនប្រឹងប៉ុប៉ុនឲ្យរីកធំដូចគេ? ឆ្លើយថា ទំប្រឹងណាស់ដែរ តែរីកទៅមិនរួច មកពីខ្វះជំនួយៗ សេរីភាពមានហើយ តែបើខ្វះជំនួយ នឹងអាចរីកទៅមិនបានឡើយ ។ អាស្រ័យហេតុនេះ ជំនួយនេះទៀត បើមានចំណាន កំមិនអាចញ៉ាំងឲ្យអ្នកតូចរីកធំបានឡើយ ។ ទើបមានសេរីភាពថ្លោស សេរីភាពតក្លៀប សេរីភាពស្អិត ។ កាលបើមានយ៉ាងនេះ ដំណើរជីវភាពនៃប្រទេសរមែងមានការរេកាក់រអួល ឮដទាងកង្វះជាមិនខាន ។

តាមការសង្កេត ចំពោះរឿងនេះ មានតែសង្គមពុទ្ធសាសនាមួយទេ ដែលបានរិះរកញែករកផ្លូវចេញបានស្រួល ។ ដែលថាសង្គមពុទ្ធសាសនានេះ សំដៅយកសង្គមបព្វជិតពុទ្ធសាសនា ។ ព្រះសាក្យមុនីបានរៀបចំច្បាប់ទម្លាប់ ចំពោះរឿងនេះដ៏ហ្មត់ចត់ពន់ពេកណាស់ ។

សួរថាគួរធ្វើយ៉ាងណា ដើម្បីចៀសវាងកុំឲ្យមានការរកាក់រអួលក្នុងដំណើរជីវភាពនៃមនុស្ស?

ឆ្លើយថា: បើតាមលទ្ធផលនៃការត្រិះរិះ ការពារក គួរតែប្បីចែក-

សេរីភាពជាតិ: សេរីភាពខាងបញ្ញា សេរីភាពខាងសម្ភារ: ។

បណ្ដាសេរីភាពទាំងពីរនេះ ត្រូវជ្រើសរើស ហើយពិនិត្យឲ្យដិតដល់ បើមួយណាមិនសូវល្អ ត្រូវពិចារណាមួយអន្លើ រួចយកមួយដទៃមកអនុវត្តល្បងមើល !

សេរីភាពខាងបញ្ញានោះដូចម្ដេច ? គឺបណ្ដាយឲ្យប្រាជ្ញា បើកឲ្យប្រាជ្ញា ត្រូវការពង្រីកខ្លួនឲ្យធំប៉ុណ្ណា តាមចំណង់ ចង់បេះវិជ្ជាមែកណាងខាងណា ត្រូវផ្ដល់មធ្យោបាយឲ្យទៅបានទាំងអស់ មិនត្រូវទាញបង្ហៀរទុកឡើយ ។ ដូចយ៉ាងកងសង្ឃបព្វជិតខាងពុទ្ធសាសនា អង្គណាត្រូវការឲ្យប្រាជ្ញាលោកជំនាញខាងព្រះត្រៃបិដកក្ដី ខាងព្រះកម្មដ្ឋានក្ដី ច្បាប់ព្រះពុទ្ធបើកឲ្យធ្វើតាមចិត្តចង់ អង្គណាខ្ជិល បេះតែធម៌និងវិន័យបន្តិចបន្តួច ទុកជាការស្រេច ចំណែកសេរីភាពខាងសម្ភារៈវិញ ព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យតែត្រៃចីវរប៉ុណ្ណោះ ។ យ៉ាងនេះ ហៅថាសេរីភាពខាងបញ្ញា ។

សេរីភាពខាងសម្ភារ:ដូចម្ដេច ? គឺបណ្ដាយឲ្យសម្ភារ:នៃបុគ្គលរីកចម្រើនគ្មានព្រំដែន តាមសត្តភាពដែលខ្លួនមាន ។ ដូចឃើញស្រាប់ អ្នកខ្លះមានផ្ទះបួនដប់ល្វែងតែម្នាក់ឯង រហូតដល់ ១ រយផង អ្នកខ្លះមានដីកប់រយហិកតាតែម្នាក់ឯង អ្នកខ្លះទទួលទានកន្លួយពេលតែម្នាក់ឯង អស់ប្រាក់កប់រយ ......ស្លៀកពាក់ខោអាវមួយប្រដាប់តែម្នាក់ឯង មានតម្លៃកប់ពាន់....។ ល ។ ផ្ទុយទៅវិញ អ្នកខ្លះមាន

តែមួយសម្រាប់នៅ ហើយយ៉ាងដុនដាប មានតែស្រអម្ពកមួយ ម្ហូបទទួលទានក្នុងមួយពេល បើគិតជាតម្លៃ មិនដល់ទាំងតម្លៃបារី ១ កញ្ចប់របស់គេ សំលៀកបំពាក់ មិនដល់ទាំងសំពត់សម្រាប់ជូតរថយន្តរបស់គេ ៗលៗ យ៉ាងនេះហៅសេរីភាពខាងសម្ភារៈ ៗ

តាមការត្រិះរិះនឹងពិចារណាឲ្យជ្រៅទៅ ឃើញថា ទំហំបញ្ហា នោះបីកប៉ុណ្ណា ក៏មិនជាឧបសគ្គដ៏ធ្ងន់ធ្ង ដល់ចិត្តដទៃដែលមានអានុភាពឡើយ ព្រោះបញ្ហាជាអរូបធម៌ ដូចជាឃើញគេមានសញ្ញាប័ត្រជាន់ខ្ពស់ មិនដែលឃើញឬឮអ្នកណាក្តៅក្រហាយ បើសរសើរនឹងគោត នោះឃើញមានប្រាកដ ៗ ផ្ទុយទៅវិញ បើទំហំខាងសម្ភារៈ គឺពិតជាមានធ្វើឲ្យក្តៅក្រហាយ ដូច្នេះហើយ បានជាមានតោរកម្មនឹងឃាដកម្មជាហូរហែ ស្ទើរតែគ្រប់តំបន់ ៗ

ចំពោះសេរីភាពទាំងពីរបែប ដូចពណ៌នាមកខាងលើ សូមមិត្តអ្នកអានទាំងឡាយ ដោះស្រាយហើយវិនិច្ឆ័យ ថាតើគួរយកណា គួរលះបង់ណា ព្រោះបើតាមការយល់ឃើញ ផ្នែកលោកមានតែពីរប៉ុណ្ណោះ ៗ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង - ខាត់ រៀបរៀង

(តមក)

---

អធិរោបណ ន ប៉ុ. កិរិយាឡើងក្រៃលែង កិរិយាតាំងនៅ ។

អធិរោហ គុ. ដែលឡើងក្រៃលែង ដែលជិះសេះ ។ ប៉ុ. ហ្មាដំរី ។

អធិរោហណ ន ប៉ុ. កិរិយាឡើងក្រៃលែង ការឡើង ។

អធិរោហិន៑ គុ. (ផ្លូវ) ដែលឡើងទៅកាន់ ។ រោហិណី ស្ត្រី ជណ្តើរ ។

អធិលង្កម៑ ក្រិ វិ ឰដ៏ខាងលើនៃក្រុងលង្កា ។

អធិលវង្គម៑ ក្រិ. វិ. ឰដ៏ខាងចុងនៃផ្កាខាន់ភ្លូ ឬ ផ្កាច័ន្ទន៍ ។

អធិលោក ប៉ុ. អធិលោក លោកក្រៃលែង ។

អធិវក្សស៑ ក្រិ. វិ. ឰដ៏ទ្រូង ។

អធិវាស៑ នៅក្រៃលែង តាំងទីលំនៅ ទីពឹង ។

អធិវាហ៑ ក្រិ. នាំ ដឹកនាំ ។

អធិវាស ប៉ុ. អ្នកនៅ អ្នកជិតខាង ទីស្នាក់ការ លំនៅ ។

អធិវាស នុំ. ខ្ជិនក្រអូប ខ្ជិន ។ -សតា ឬ -សិតា ស្រ្តី. ការនៃកិរិយា អប់ខ្ជិន ។

អធិវាសន ន បុំ. កិរិយាអប់ខ្ជិន ។

អធិវិជ្ញាន ន បុំ. វិទ្យាក្រៃលែង ។

អធិវិទ ក្រិ. បានក្រៃលែង យកគ្នា បានគ្នា ។ អធិវិន្នា ស្រ្តី. ប្រពន្ធដែលប្តីយកប្រពន្ធទៀត ប្រពន្ធមិនជាទីប្រោសប្រាណ ។

អធិវិទ្យម ក្រិ. វិ ធំហើយដោយវិជ្ជាក្រៃលែង ។

អធិវាវិជា ក្រិ. ចែក រំលែក ។

អធិវិស ក្រិ. ចូលក្រៃលែង តាំងនៅ ។

អធិវិមុត្ត គុ. ដែលជាប់ក្រៃលែង ដែលតាំងនៅ ។

អធិវ្បតិ ក្រិ. ប្រព្រឹត្តទៅក្រៃលែង កម្រើក ។

អធិវេត្តវ្យា ស្រ្តី. ប្រពន្ធប្តីលែង ។ -វេទ្យា ស្រ្តី ប្រពន្ធដែលប្តីលែង ។

អធិវេលម ក្រិ. វិ. តាមគ្រើយ លើគ្រើយ ។

អធិវេស្ម ក្រិ. វិ. ក្នុងផ្ទះ ។

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកភិងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។
យូរ-អ៊ុន

ខណៈកាលឡេវពីភ័យឃ្លោះហៅទៀវហ៊ុយឲ្យថយទៅនោះ ម៉ាឈៀវក៏ត្រឡប់ចូលមកបន្ទាយ គិតខឹងក្តៅនឹងទៀវហ៊ុយជាខ្លាំងណាស់ ក៏ពាក់ក្រោះឡើងសេះថ្មី នាំទាហានទៅដល់មុខបន្ទាយ ហើយស្រែកដោយទោសោថា ពេលយប់នេះ ទៀវហ៊ុយត្រូវចេញមកច្បាំងនឹងអញទៀត ទៀវហ៊ុយឮដូច្នោះក៏ខឹងណាស់ ប្តូរយកសេះឡេវពីមកជិះ ហើយនាំទាហានចេញទៅស្រែកថា ពេលយប់នេះបើអញមិនចាប់ខ្លួនម៉ាឈៀវឯងឲ្យបានទេ អញក៏មិនវិលត្រឡប់ចូលបន្ទាយវិញឡើយ ម៉ាឈៀវស្រែកតបថា ក្នុងពេលយប់នេះ បើអញមិនមានជ័យជំនះលើឯងទេ អញក៏មិនវិលចូលបន្ទាយ ។

ក្នុងខណៈនោះ ទាហានទាំងសងខាងអុជគប់ភ្លើងឡើងភ្លឺស្វាងថ

ដូចថ្ងៃ ម៉ាឈៀវនឹងទៀវហ៊ុយច្បាំងគ្នាបាន ២០ ក្បួន ម៉ាឈៀវធ្វើជាថយរត់ ទៀវហ៊ុយក៏ញាក់សេះដេញតាមទៅភ្លាម គិតថា ម៉ាឈៀវមិនទាន់ភ្លាត់ភ្លាំងក្នុងក្បួនអាវុធត្រង់ណា ហើយទាញសេះវេះរត់ទៅដូច្នោះ មុខជាធ្វើកលឧបាយអ្វីជាប្រាកដ ទៀវហ៊ុយក៏គិតរារាំងខ្លួន មិនចូលទៅឲ្យជ្រុលការ ៗ ម៉ាឈៀវឃើញទៀវហ៊ុយដេញចូលមកជិត ក៏លើកដំបងដែកវាយទៀវហ៊ុយ ៗ យកលំពែងរងខ្ទាតចេញ ហើយទាញញាក់សេះរត់ ម៉ាឈៀវក៏ដេញតាមពីក្រោយទៅ ទៀវហ៊ុយក៏ត្រឡប់បែរមុខមកវិញ យឹតធ្នូបាញ់ម៉ាឈៀវ ៗ ក៏យកលំពែងរងទាន់ព្រួញខ្ទាតចេញ ទទួលដល់ពេលយាម ២ បាយ ម៉ាឈៀវក៏ត្រឡប់ចូលទៅកាន់ប្រជុំទាហាន ទៀវហ៊ុយក៏ត្រឡប់ទៅរកឡៅពីឯបន្ទាយ ៗ

ឡៅពីក៏បរសេះចេញទៅមុខទាហាន ហើយស្រែកប្រកាស ប្រាថ្នានឹងយកចិត្តម៉ាឈៀវថា វេលាក៏យប់ងងឹតណាស់ទៅហើយ ចូរអ្នកត្រឡប់ទៅឈប់សម្រាកក្នុងបន្ទាយសិនចុះ ព្រឹកស្អែក សឹមចេញមកច្បាំងគ្នានឹងម៉ាឈៀវទៀត ម៉ាឈៀវឮដូច្នោះ ក៏នាំទាហានត្រឡប់ចូលបន្ទាយ ឡៅពីនឹងទៀវហ៊ុយក៏វិលចូលមកបន្ទាយវិញ ៗ លុះព្រឹកឡើងទៀវហ៊ុយក៏ចាត់ចែងទាហាននឹងចេញទៅច្បាំងនឹងម៉ាឈៀវម្តងទៀត ៗ ទទួលបំរើសេះមកប្រាប់ឡៅពីថា ឥឡូវខុងបេងតាមមកដល់ហើយ ៗ ឡៅពីឮដូច្នោះ ក៏មានអំណរណាស់ ទើបចេញទៅទទួលខុងបេងចូលមក ៗ ខុង

បេងថា ម៉ាឈៀវនោះមានថ្វីដៃខ្លាំងពូកែណាស់ បើច្បាំងនឹងទៀវហ៊ុយនេះ ក៏បីដូចខ្លា ២ គន្លា គង់តែនឹងក្ខាត់មួយ ៗ មិនខាន ខ្ញុំនឹងសុំធ្វើកលឧបាយឲ្យម៉ាឈៀវចូលមកនៅនឹងលោកដោយស្រួល ៗ ទៀវពីថា ខ្ញុំបានឃើញថ្វីដៃម៉ាឈៀវហើយ ខ្ញុំក៏គិតណាស់ដែរ គឺចង់បានមកធ្វើការជាមួយ ដែលលោកថានេះ ខ្ញុំពេញចិត្តណាស់ តែលោកនឹងគិតឧបាយដោយប្រការម្តេច នឹងឲ្យបានខ្លួនម៉ាឈៀវដោយស្រួល ៗ

ខុងបេងថា ទៀវឡូនោះ មានចិត្តកំរើបនឹងចង់តាំងខ្លួនឡើង ជាស្តេចក្នុងស្រុកហ៊ានតុង មានទីប្រឹក្សាម្នាក់ឈ្មោះអៀវស៊ុង ឯអៀវស៊ុងនោះជាមនុស្សលោភ ប្រាថ្នាចង់បានតែរបស់ផ្សេង ៗ ទុកជាប្រយោជន៍របស់ខ្លួន បើដូច្នោះ សុំឲ្យលោកចាត់របស់ដែលមានតម្លៃត្រកាលនឹងសំបុត្រឲ្យបំរើលបចូលទៅឲ្យអៀវស៊ុង ឲ្យអៀវស៊ុងនាំយកសំបុត្រនោះទៅឲ្យទៀវឡូជាសេចក្តីថា ខ្លួនលោកលើ-កទ័ពមកនេះនឹងវាយយកស្រុកសែឈួនប្រាថ្នានឹងជួយសងសឹកដែលឡៅជៀងសម្លាប់មាតាទៀវឡូនោះ បើឡៅជៀងទៅហ្វាយស្រុកសែឈួន នឹងឲ្យមកនិយាយសម្រួលពីការអ្វីដល់ទៀវឡូ ក៏កុំយកជាធុរៈឡើយ បើលោកវាយបានស្រុកសែឈួនហើយនឹងតាំងចិត្តបំរុងឲ្យទៀវឡូឡើងជាស្តេចក្នុងស្រុកហ៊ានតុងឲ្យបាន ហើយឲ្យទៀវឡូមានសំបុត្រទៅហៅខ្លួនម៉ាឈៀវឲ្យវិលចូលទៅវិញ កាលបើម៉ាឈៀវនឹងលើកទ័ពត្រឡប់ទៅវិញនោះ ខ្ញុំនឹងចាត់មនុស្សឲ្យទៅស្កាត់

បញ្ចុះបញ្ចូលម៉ាឈៀវឲ្យមកនៅធ្វើការជាមួយនឹងលោកឲ្យបាន ។

ឡៅពីបានស្ដាប់មានអំណរណាស់ ទើបតែងសំបុត្រតាមពាក្យខុងបេងនិយាយ ហើយចាត់មាសប្រាក់នឹងព្រៃយ៉ាងល្អ ដែលជាជំនូនអៀវសុងនោះ ឲ្យស៊ុនខៀនជាបំរើនាំចូលទៅតាមផ្លូវកាត់ ទៅឲ្យអៀវសុងឯស្រុកហ៊ានតុង ។ លុះស៊ុនខៀនបានទៅដល់ ក៏ចូលទៅគំនាប់អៀវសុងហើយជំរាបថា របស់មាសប្រាក់ទាំងនេះឡៅពីឲ្យខ្ញុំបាទនាំមកជូនលោក លោកចូរឃើញដោយផ្លូវមេត្រីជួយឈឺឆ្អាលយកសំបុត្រនេះ ចូលទៅឲ្យទៀវឡូផង អៀវសុងឃើញរបស់ទាំងពួងមានតម្លៃក៏ត្រេកអរណាស់ ព្រោះជាមនុស្សលោភ ទទួលយកហើយក៏នាំខ្លួនស៊ុនខៀននឹងសំបុត្រ ចូលទៅគំនាប់ទៀវឡូហើយជំរាបថា ឥឡូវឡៅពីឲ្យមានសំបុត្រជាផ្លូវមេត្រីមកដល់លោក ។ ទៀវឡូទទួលយកសំបុត្រនោះមកមើល លុះដឹងក្ដីសេចក្ដីហើយក៏ថា ខ្លួនឡៅពីគ្រាន់តែជានាយទាហានខាងក្រៅ ហេតុម្ដេចមកបង្អាចគន្លងថា នឹងជួយទំនុកបំរុងយើងឲ្យធ្វើស្ដេចបាន លើសកម្លាំងនឹងគំនិតគិតទូវ៉ាយសសក្ដិណាស់ ។

អៀវសុងថា ឡៅពីនោះជានាយទាហានក៏មែន តែជាពូជព្រះកជវង្ស ព្រះចៅហៀនតេ ៗ ទ្រង់រាប់អានហៅជាមា ហើយឡៅពីនឹងពិតទូលអំពីរឿងអ្វី ៗ ព្រះចៅហៀនតេក៏ត្រូវព្រះកជអធ្យាស្រ័យ ខ្ញុំបាទឃើញថា ឡៅពីបានចេញពាក្យថាប៉ុណ្ណោះ ហើយក៏គង់នឹងជួយទំនុកបំរុងលោក

ឲ្យទៀនជាស្តេចបាន ទៀវឡូឮដូច្នោះក៏មានអំណរណាស់ ព្រោះចិត្តកំរើប ទើបឲ្យតែងសំបុត្រទៅហៅខ្លួនម៉ាឈៀវឲ្យចូលមកវិញ ។ ស៊ុនខៀនក៏លាទៀវឡូចេញទៅកាស្រ័យទៅផ្ទះអៀវស៊ុង ប្រាថ្នានឹងចាំស្តាប់សេចក្តីដែលម៉ាឈៀវនឹងត្រឡប់មកវិញឬទេ ។

បំរើសេះដែលទៅហៅម៉ាឈៀវនោះ ត្រឡប់មកប្តឹងទៀវឡូវិញថា ម៉ាឈៀវឲ្យជំរាបលោកថា នឹងសុំធ្វើការសង្គ្រាមឲ្យបានសេចក្តីគាប់ប្រសើរសិន ទើបនឹងលើកកងទ័ពត្រឡប់វិលវិញ ។ ទៀវឡូក៏ប្រើបំរើសេះ ឲ្យទៅហៅម៉ាឈៀវម្តងទៀត ដល់ ២ គ្រា ៣ គ្រា ម៉ាឈៀវក៏នៅតែនិយាយដដែល ។ អៀវស៊ុងដឹងសេចក្តីដូច្នោះ ក៏ចូលទៅជំរាបទៀវឡូថា ឯចិត្តម៉ាឈៀវនោះជាមនុស្សអកតញ្ញូអាក្រក់ណាស់ ដែលលោកឲ្យទៅហៅខ្លួនមិនព្រមចូលមកតាមប្រសាសន៍នោះ ខ្ញុំបាទឃើញថា ម៉ាឈៀវនឹងប្រែចិត្តចេញពីលោកជាប្រាកដហើយ គួរឲ្យលោកប្រុងប្រយ័ត្នខ្លួនឲ្យមួនមាំ ហើយអៀវស៊ុងក៏លាត្រឡប់មកវិញ ទើបប្រើមនុស្សទំនុកទុកចិត្តឲ្យចេញទៅលបស្តាប់ដំណឹង ហើយឲ្យនិយាយប្រាប់អ្នកស្រុកទាំងពួងថា ម៉ាឈៀវនោះប្រែចិត្តចេញពីទៀវឡូហើយ ៗ កំពុងគិតនឹងទៅវាយយកស្រុកហ៊ូគោ ប្រាថ្នានឹងសងសឹកចូចូដែលសម្លាប់ម៉ាថេងជាបិតា នោះកិត្តិសព្ទនេះ ក៏រន្ទឺឮទៅដល់ទៀវឡូ ៗ ក៏មិនដឹងកល់ ។ បាយអៀវស៊ុង ប្រុងតែគិតថា ម៉ាឈៀវវាយបានស្រុកសែឈួនហើយ ក៏នឹង

លើកមកវាយយកស្រុកហានតុងម្ដងទៀត ទៀវឡុក៏ឲ្យហៅខ្ញុនអៀវស៊ុង ចូលទៅនិយាយថា ដែលយើងឲ្យហៅខ្ញុនម៉ាឈៀវមិនព្រមត្រឡប់នោះ អាណាប្រជានុរាស្ត្រក៏ល្បីព្រួទ្រូអស់ហើយ អ្នកទឹងគិតយល់ប្រការម្ដេច ។

អៀវស៊ុងថា ម៉ាឈៀវមិនព្រមមកនេះ ត្រូវលោកឲ្យមានសំបុត្រ ទៅកាត់ទោសម៉ាឈៀវទុកជាសេចក្ដីនឹងទទឹង ត្រូវធ្វើការបាន ៣ ខ: ខមួយឲ្យម៉ាឈៀវចាំធ្វើការបាំងឲ្យកងទ័ពឡៅពីបែកឲ្យខាងតែបាន ខពីរ ឲ្យម៉ាឈៀវចាំលើកទៅវាយស្រុកសែឈួនឲ្យខាងតែបាន ខបី ទោះបីថា ឡៅជៀងរត់ចេញពីស្រុក ក៏ឲ្យម៉ាឈៀវចាំដេញតាមចាប់សម្លាប់ចេញ ហើយកាត់ក្បាលបញ្ជូនមកឲ្យយើង ។ សេចក្ដីទាំង ៣ ខនេះ បើម៉ាឈៀវធ្វើបានក៏ទឹងឲ្យបំណាច់រង្វាន់ឲ្យដល់ខ្នាត បើខ្វះតែខឯណាទីមួយ ត្រូវយកទោសប្រហារជីវិត ហើយឲ្យទៀវអ៊ួយជាប្អូនលោកទឹងទាហាន ទៅតាំងស្កាត់ទ័ពឲ្យគ្រប់កន្ទ្រងគយទាំង ៤ អន្ទ្រី ខ្មាចក្រែងម៉ាឈៀវនឹងមានចិត្តទទឹង លើកទ័ពត្រឡប់មកវាយយកស្រុកយើងវិញ កងទ័ពទាំងអស់នេះ ក៏ទឹងបានជួយគ្នាការពារពីខាងក្រៅ ។ ទៀវឡុយល់ឃើញត្រូវផង ក៏ចាត់ចែងទាហានលើកទៅតាំងនៅទីគយទាំង ៤ ដំបន់ ហើយសំបុត្រកាត់ទោសឲ្យបំរើសេះកាន់យកទៅឲ្យម៉ាឈៀវ សេចក្ដីដូចអៀវស៊ុងនិយាយនោះ ។

ឯម៉ាឈៀវ លុះឃើញសំបុត្រដូច្នោះហើយ ក៏ប្រឹក្សានឹងម៉ាតាយថា

ប្អូនថា ទៀវឡុងខឹងនឹងយើងមិនលើកកងទ័ពត្រឡប់ទៅវិញតាមសេចក្តីដើម បានជាកាត់ទោស ទុកឲ្យយើងធ្វើការឲ្យបានគ្រប់តាំង ៣ ខែនេះឲ្យរហូត បើមិនសម្រេចនឹងយកទោសយើងដល់ស្លាប់ ឯការតាំង ៣ ខែនេះយើងនឹងធ្វើទៅរហូតឬ ១ ត្រូវតែគិតលើកទ័ពត្រឡប់ទៅស្រុកហាន់តុងវិញតាមពាក្យទៀវឡុងទើបនឹងរួចខ្លួន ម៉ាំតាយយល់ឃើញត្រូវផង ម៉ាំ-ឈៀវនឹងលើកទ័ពត្រឡប់វិលវិញ ។

អៀវសុង លុះដឹងថា ម៉ាឈៀវនឹងលើកទ័ពត្រឡប់វិលដូច្នោះ ក៏ចាត់មនុស្សឲ្យដើរទៅបរិហារនិយាយប្រាប់អ្នកស្រុកតាំងពួនថា ឥឡូវម៉ាឈៀវគិតនឹងលើកទៅវាយយកស្រុកហាន់តុងហើយ ឥឡូវទៀវឡុងឲ្យកេណ្ឌទាហានទៅតាំងស្ទាក់ទ័ពថែមទៀត តាំងពាសតាំងពី ៨ អន្លើ ហើយបង្គាប់កំជាប់ទាហានថា កុំឲ្យទាហានម៉ាឈៀវប្លុកប្លបបន្លំចូលបាន ។ ឯម៉ាឈៀវនោះ លុះលើកទ័ពត្រឡប់មកវិញ ឃើញទាហានទៀវឡុងលើកទៅស្ទាក់គ្រប់គយតាមផ្លូវ នឹងចូលទៅក្នុងស្រុកក៏មិនបាន នឹងថយត្រឡប់មកក្រោយក៏ក្រែងទៀវឡុង រិតតែមានសេចក្តីសង្ស័យខ្លាំងទៅទៀត ម៉ាឈៀវមិនដឹងគិតប្រការម្តេច ក៏មានសេចក្តីបរិវិតក្កកើតទុក្ខខ្លាំងណាស់ ។

ខុងបេងដឹងថា ម៉ាឈៀវជាទុក្ខទោមនស្សដូច្នោះ ក៏មានចិត្តត្រេកអរណាស់ ទើបនិយាយនឹងទៀវពីថា ឥឡូវម៉ាឈៀវនឹងចូលទៅរកទៀវឡុងក៏មិនបាន នឹងថយត្រឡប់មកវិញក៏បារម្ភ ខ្លាចក្រែងទៀវឡុងសង្ស័យ

ម៉ាឈៀវគឺអស់សេចក្ដីគិតទៅហើយ ខ្ញុំនឹងសុំអាសាទៅនិយាយបញ្ចុះបញ្ចូលម៉ាឈៀវ ឲ្យចូលនៅជាមួយនឹងលោកឲ្យទាល់តែបាន ។ ឡៅពីគបថា ខ្លួនលោកឧបមាបីដូចដួងចិត្តរបស់ខ្ញុំ ដែលលោកទឹងទៅបញ្ចុះបញ្ចូលម៉ាឈៀវនោះ ខ្លាចនឹងមានសេចក្ដីអន្តរាយអ្វីក៏មិនដឹងឡើយ ឯខ្ញុំនឹងមានសេចក្ដីព្រួយណាស់ ។ ខណៈកាលឡៅពីនឹងខុងបេននិយាយគ្នានោះ ទទួលមានបំរើសេះកាន់សំបុត្រដូឡងបួងមកថា លីអ៊ុនពួកស្រុកសៃឈួនស្គាល់រាប់អានគ្នាពីដើម ឥឡូវមានចិត្តស្មគ្រចូលមកនៅធ្វើការជាមួយនឹងលោក ខ្ញុំបាទក៏ទទួលខ្លួនឲ្យនៅជាមួយនឹងខ្ញុំបាទទៅហើយ ឡៅពីឃើញសេចក្ដីសំបុត្រដូច្នោះក៏មានអំណរណាស់ ទើបឲ្យទៅហៅយកខ្លួនលីអ៊ុនឲ្យចូលមក ហើយសួរថា កាលឡៅជៀងនឹងឲ្យទទួលយើងចូលទៅច្រកក្រាការសង្គ្រាមផងនោះ ខ្លួនអ្នកបានហាមឃាត់ឡៅជៀង មិនឲ្យទទួលយើងចូលទៅ ឥឡូវបែកចិត្តចេញពីឡៅជៀង ស្មគ្រមកនៅនឹងយើងវិញនោះ ដោយឃើញហេតុប្រការអ្វី? ។

លីអ៊ុនឆ្លើយថា ពាក្យបុរាណពោលទុកថា ធម្មតាសត្វបក្សបក្សាបើនឹងធ្វើសំបុកអាស្រ័យនៅលើដើមឈើណា ក៏ត្រូវឲ្យមើលមែកសន្ទឹកដែលមានម្លប់ដិតម៉ាល្អ សឹមឲ្យសំណាក់នៅ ទើបបានសុខនិរទុក្ខចាកភយន្តរាយទាំងពួង ឥឡូវកើតមកជាមនុស្សប្រុស ក៏ត្រូវពិព្រោះមើលនាយចៅហ្វាយដែលមានចិត្តអធ្យាស្រ័យល្អសុចរិតប្រាកដ ទើបលោកឲ្យចូល

នៅផង ដើម្បីនឹងជួយឲ្យបានសេចក្ដីសុខតទៅ ដូចខ្លួនខ្ញុំបាទជាបាវទូលមានបាយក្រហមរបស់នាយទៅហ្វាយហើយ ដូចជាឡេវដៀងគេក៏មានគុណូបការៈលើខ្លួនខ្ញុំបាទ ខ្ញុំបាទក៏ត្រូវជួយរំលឹកឃាត់ហាមតាមសតិបញ្ញាដោយសេចក្ដីកតញ្ញូ លុះឡេវដៀងមិនព្រមស្ដាប់តាមពាក្យខ្ញុំបាទហើយ ខ្ញុំបាទក៏បានសេចក្ដីតូចចិត្តគិតអៀនខ្មាសទៅដែរ បើនឹងមិនប្រែចិត្តគិតសារជាថ្មី ចាំតែទៅទៅក៏គង់នឹងមានទុក្ខភ័យដល់ខ្លួន បានជាខ្ញុំបាទចូលមកជ្រកកោននៅនឹងលោកវិញដូច្នេះ ព្រោះបានឮកេរ្តិ៍ឈ្មោះពីកេះពិសាថា លោកមានចិត្តមេត្តាករុណាដោយសត្យពិតត្រង់ល្អណាស់ សូម្បីមនុស្សទាំងក្មេងចាស់ក្នុងស្រុកសែឈួន ក៏គង់ស្រឡាញ់លោកជាច្រើនការទាំងពួងដែលលោកបំណងនឹងធ្វើក៏គង់បានចំរើនដូចប្រាថ្នាជាប្រាកដៗ

ឡេវពីសួរថា ដែលអ្នកតាំងចិត្តមកនៅធ្វើការរាជការនឹងយើងនេះ អ្នកនឹងជួយរិះគិតធ្វើការប្រការម្ដេចខ្លះ ឲ្យ ដើម្បីឲ្យបានជាប្រយោជន៍ដូចប្រាថ្នានោះ ។ លីអ៊ុនថា ឥឡូវឮកិត្តិសព្ទថា ម៉ាឈៀវនឹងចង់ចូលទៅរកឡេវឡេវិញក៏ពុំបាន នឹងថយត្រឡប់មកក្រោយក៏ឲ្យបារម្ភខ្លាច ទើបមិនអាចនឹងរិះគិតយ៉ាងណា ដូចជាពាល់ប្រាជ្ញាទៅហើយ ឯម៉ាឈៀវនោះនឹងខ្ញុំបាទ ក៏ធ្លាប់រាប់អាន បានស្គាល់ចិត្តគ្នាមកយូរហើយ ខ្ញុំបាទនឹងចង់សុំយកអាសាទៅបញ្ចុះបញ្ចូលម៉ាឈៀវឲ្យប្រែចិត្ត គិតមកនៅធ្វើរាជការនឹងលោកឲ្យទាល់តែបាន ។ ខុងបេងថា យើងក៏ចាំរកតែអ្នក

ឯណា ដែលមានសតិបញ្ញា នឹងឲ្យទៅនិយាយបញ្ចុះបញ្ចូលម៉ាឈៀវជាយូរ ថ្ងៃមកហើយ មិនទាន់បាន បើអ្នកអាចហ៊ានទទួលធុរៈដូច្នេះ ក៏ជាការប្រពៃណាស់ ចូរខំប្រឹងរួតរះទៅនិយាយឲ្យបានការចុះ ទើបនឹងបានសេចក្ដីគាប់ប្រសើរតទៅ ។

លីអ៊ុនទទួលពាក្យនឹងខុងបេងឡើងហើយ ក៏ស្រួតចេញទៅ ដល់កងទ័ពម៉ាឈៀវ ក៏ប្រាប់ពួកទាហានយាមថា ខ្ញុំឈ្មោះលីអ៊ុននឹងសុំចូលទៅរកម៉ាឈៀវ ។ ទាហានក៏ចូលទៅជំរាបការតាមដំណើរនេះ ។ ម៉ាឈៀវដឹងដូច្នោះទើបថា ឯលីអ៊ុននោះ ជាមនុស្សពូកែខាងសំដីណាស់ ការដែលមកនេះ មានប្រាថ្នានឹងមកបញ្ចុះបញ្ចូលយើងហើយ ទើបរៀបទាហានឲ្យមានកាន់សាស្ត្រាវុធគ្រប់ដៃចំនួន ២០ នាក់ ហើយក៏បង្គាប់ថា បើលីអ៊ុនចូលមកនិយាយការនឹងយើង បើឮយើងថាឲ្យចុះដៃវេលាណា ឲ្យអ្នកកល់គ្នាចូលព្រួតចាប់លីអ៊ុនសម្លាប់ចេញទៅចុះ ហើយកាប់ចំញ៉ាំសាច់ឲ្យល្អិត លុះបង្គាប់ការរួចហើយ ក៏ប្រើទាហានឲ្យចេញទៅហៅលីអ៊ុនចូលមក ។

ម៉ាឈៀវក៏សួរលីអ៊ុនដោយសម្លេងគំហកយ៉ាងខ្លាំងថា ខ្លួនមករកយើងវេលានេះ ដោយត្រូវការអ្វី ? ។ លីអ៊ុនឆ្លើយថា យើងមកនេះដើម្បីមកបញ្ចុះបញ្ចូល ម៉ាឈៀវ ។ អ្នកនឹងបញ្ចុះបញ្ចូលប្រការម្ដេច ត្រូវថាទៅឲ្យល្អចុះ ព្រោះក្រប៊ីដែលយើងកាន់នេះ ទើបនឹងសំលៀនថ្មី បើថា

មិនត្រូវចិត្តយើង ៗ នឹងយកក្របីនេះល្បងក្បាលអ្នកមើល ៗ

លីអ៊ុនឮដូច្នោះ ក៏អស់សំណើចហើយថា វេលានេះយើងដឹងប្រាកដថាភ័យនឹងមកដល់អ្នកហើយ បានជាយើងមកការពារឲ្យផុតអំពីភ័យនោះ ម្តេចអ្នកត្រឡប់ជាយកក្របីល្បងក្បាលយើងវិញដូច្នេះ ឯក្របីរបស់អ្នកនោះ បើទុកជាទើបនឹងសំលៀងថ្មី ក៏មិនគប្បីនឹងសម្រាប់កាប់ក្បាលយើងបានទេ ចប់តែអ្នកដទៃនឹងតែកាប់ក្បាលអ្នកវិញទេដឹង ៗ ម៉ាឈៀវសួរថា អ្នកឯងដឹងថា នរណានឹងប្រាថ្នាកាប់ក្បាលយើងនោះ ៗ លីអ៊ុនតបថា ធម្មតាស្រីរូបល្អ ទោះបីនឹងយកគ្រឿងអំពរដែលទុល្លភាពមកបំពាក់ ក៏មិនមែនធ្វើឲ្យរូបនោះអបលក្សណ៍ទៅវិញបាន បើស្ត្រីនោះមានរូបកាយអាក្រក់សាមាន្យ សូម្បីនឹងយកគ្រឿងប្រដាប់ដ៏ល្អកំផានមកបំពាក់យ៉ាងណា រូបកាយដែលអាក្រក់ក៏នៅជាអាក្រក់តាមធម្មតាទាំងអស់ ពុំនោះដូចដួងព្រះអាទិត្យ បើដល់កំណត់ដេរត្រង់ណា រស្មីក៏ក្តៅបរិឡាខ្លាំងណាស់ ឬដូចដួងព្រះចន្ទ ដែលរឿងរះស្រឡះពពកក្នុងវេលាថ្ងៃពេញបូណ៌មី ក៏មានរស្មីស្វាងរុងរឿងជ្រះថ្លា បើដល់ទៅរនោចកាលណា ក៏តែងអាប់អន់ពន្លឺអស់ទៅតាមធម្មតាលោកដូច្នោះ ដូចយ៉ាងខ្លួនអ្នកនៅកំពុងពេញពាល ដូចព្រះចន្ទពេញបូណ៌មី ឬដូចព្រះអាទិត្យកំពុងថ្ងៃត្រង់ ព្រមទាំងរូបអង្គទ្រង់ទ្រាយពណ៌ភាយល្អ សមគួរជាទាហានឯកក្នុងផែនដី គប្បីនឹងរិះគិតធ្វើសឹកសង្គ្រាមតាមដែលមានមកពីអតីត ៗ

( នៅមានត )

# រឿងល្បើកទ្បាហ្វុងតែន

លោក ដេង-ដ្រីវ ប្រែរៀបរៀង

(១)

## ៨៣– មាន់ព្រៃយកស្លាបក្ងោកមកពាក់

មានក្ងោកមួយជម្រុះស្លាប មាន់ព្រៃរើសយកស្លាបនោះមកបំពាក់អាត្មា រួចដើរកាច់កង់យ៉ាងសង្ហា ទៅបណ្ដាពួកក្ងោកដទៃ ដោយនឹកស្មានថាខ្លួនជាតួមួយដ៏ប្រពៃដែរ ។

(ជាអកុសល) ស្រាប់តែមានក្ងោកមួយស្គាល់ច្បាស់ៈ ម៉្លោះហើយមាន់ព្រៃបានត្រូវទទួលការស្ដីបន្ទោស ទឹងការពេបជ្រាយរិះគន់គ្រប់បែបយ៉ាង ហើយត្រូវពួកក្ងោកចាប់បោចគ្រនាក់យកស្លាបចេញយ៉ាងខ្លាំង ។ មាន់ព្រៃត្រូវគេបណ្ដេញចេញ ហើយសូម្បីមាន់ព្រៃដូចគ្នា ក៏ឈប់លែងឲ្យចូលដៃជាមួយ ។

(សព្វថ្ងៃ)មានមាន់ព្រៃរបៀបដូចមាន់ព្រៃខាងលើច្រើនអនេក ដែលនិយមយកជាញឹកញយនូវកំអែលអ្នកដទៃ មកតាក់តែងលំអអាត្មា ហើយដែលគេឲ្យឈ្មោះថា ចោរនិពន្ធ

ចំពោះរឿងនេះ ខ្ញុំនៅស្ងៀម ខ្ញុំមិនប្រាថ្នាធ្វើឲ្យខានដល់អ្នកតាំងនោះឡើយ ព្រោះរឿងនោះមិនមែនជាកិច្ចការរបស់ខ្ញុំ ។

---

១–ពាក្យបារាំងថា (geai) ជាសត្វសន្តានចាប ខ្ញុំយល់ឃើញថា ចាបនិងក្ងោកមានទំហំខុសគ្នាឆ្ងាយ បានជាខ្ញុំយកមាន់ព្រៃមកដាក់ជំនួស ដើម្បីឲ្យមានទំហំស្រដៀងគ្នាបន្តិច ។

## ៨៤- សត្វកញ្ជ្រោងនឹងរូបបដិមា

អ្នកធំភាគច្រើន សុទ្ធសឹងជាមុខពាក់របស់ល្ខោន អាការខាងក្រៅរបស់អ្នកធំ តែងធ្វើឲ្យមនុស្សសាមញ្ញជាអ្នកគោរពកោតខ្លាចខ្លួន ។

សត្វលាចេះវិនិច្ឆ័យមនុស្សតែតាមអាការ ដែលវាឃើញនឹងភ្នែក ផ្ទុយទៅវិញ សត្វកញ្ជ្រោងពិនិត្យមើលមនុស្សដល់ខាងក្នុង គឺថាពិនិត្យចុះឡើងគ្រប់សព្វ ហើយកាលណាវាយល់ច្បាស់ថា រូបអ្នកធំនោះ គ្រាន់តែជាអាការខាងក្រៅ វាតែងប្រើពាក្យមួយ ចំពោះរូបនោះ ដូចជារូបបដិមាអ្នកហាវហានម្នាក់ ធ្វើឲ្យវានិយាយដូចតទៅ ៖

គឺជារូបបដិមាមួយប្រហោងក្នុង តែទំហំធំជាងធម្មតា ។

សត្វកញ្ជ្រោង លុះសរសើរការខំព្យាយាម ក្នុងការចម្លាក់រូបហើយ ទើបពោលថា : «ក្បាលនេះល្អពិត តែឥតមានខួរសោះ» ។

ចំពោះចំណុចនេះមានស្ដេចត្រាញ់ធំៗជាច្រើនដែលសុទ្ធសឹងជារូបបដិមា ។

## ៨៥- ចចក ម្ដាយនឹងកូន

គ្រួសារមួយសង់ផ្ទះដាច់ឆ្ងាយពីគេ ។ ចចកមួយឃើញស្រួល ទើបមកចាំនៅក្បែរទ្វារ វាសង្ឃឹមថា មុខជានឹងបានជួបសត្វជាចំណីគ្រប់យ៉ាងមិនខាន ដូចកូនគោនៅបៅដោះ កូនចៀម ពពែ ហ្វូងមាន់ដាំងដុង (១) រួមសេចក្ដី គឺអាហារគ្រប់មុខ ៗ ក៏ប៉ុន្តែ (ដោយរង់ចាំយូរ) អាចោរខូចកើត

១- ខ្មែរនិយមហៅដាំងដុង (Dindon) ថា មាន់បារាំង ។

អផ្សុកធុញទ្រាន់ ពេញក្មេងឃុំ : ម្ដាយស្រែកស្ដីបន្ទោសទាំងគម្រាមឲ្យថា បើមិនបាត់យំទាំងឲ្យវាទៅចចកស៊ី ។ ចចកក៏ប្រុងខ្លួនចាំទទួល ដោយអរគុណដល់ទេព្ដា អំពីពសនានេះ ។ លុះម្ដាយដែលចង់លួងកូនខ្លួនឲ្យស្ងៀម ទើបនិយាយនឹងកូនថា : កូនឯងកុំស្រែកឲ្យសោះ ប្រសិនបើវាមក យើងនឹងសម្លាប់វាឥឡូវ ។

ចចកស្រែកថា ចុះហេតុម្ដេចក៏អ៊ីចឹង ? ម្ដងថាឯណេះ ម្ដងថាឯណុះ ! តើគេតែងតែនិយាយមើលងាយពួកអញដូច្នេះឬ ? គេទុកអញជាឆ្កួត ឬ ? ចាំមើលថ្ងៃណាមួយ ឲ្យតែអាតូចប្រម៉ក់ហ្នឹងទៅក្នុងព្រៃគេបេះផ្លែណ្វា ហ្សែត (Noisette) !

បានឮសំដីដូច្នោះ គេស្ទុះចេញមកពីក្នុងផ្ទះភ្លាម : ក្ដៅរត់ស្ទាក់ ដំបងនិងច្បូកពួយរឹងញាំងទៅលើចចក ។

គេសួរចចកថា ឯងមករកអ្វីក្នុងនេះ ?

ចចកក៏និយាយរឿងប្រាប់សព្វគ្រប់ ។ នាងម្ដាយពោលថា: ឱ ព្រះអើយ តើអញមានបំណងបំពេញក្រពះឯងដោយកូនអញក្នុងថ្ងៃណាមួយឬ ? ។

រួចគេសម្លាប់ចចកនោះទៅ ។ អ្នកស្រុកម្នាក់កាប់ជើងស្ដាំនិងក្បាលចចក ហើយទាញអូសបោះចោលទៅ ទើបគេចារឹកជាពាក្យស្លោកទុកនៅក្បែរភូមិថា « លោកចចកអើយ ចូរកុំស្ដាប់ម្ដាយដេរកូនយំ ។

(នៅមានត)

# ១១ – រឿងក្អែកត្រូវទោស

## 11e - le Corbeau puni

### រឿងព្រេងចិន

ដោយលោក ភ៊យ-ឡុំតា

---

ក្រោយដែលផែនដីស្ថាបនារួចហើយ ទើបគេបង្កើតឲ្យមានរដូវទាំងបួន គឺៈ និទាឃរដូវ វស្សានរដូវ សរទរដូវ និង សិសិររដូវ ក្រោយដែលស្ថាបនា រដូវទាំងបួនរួចហើយ មានបុប្ផាគ្រប់យ៉ាង ធញ្ញជាតិផុះ ផលានុផលមានគ្រប់មុខ ៗ គឺជីវភាពសត្វ មនុស្សលោក ក៏បានប្រព្រឹត្តទៅដោយស្រួល ៗ តែគេចង់បានសុខស្រួលជាងនេះទៅទៀត ៗ ព្រោះហេតុដូចនេះ បានជាគេធ្វើនំមួយ ដោយប្រមូលផ្សំគោមេតម័យ (Buerre) ទឹកដោះគោ ទឹកឃ្មុំ ម្សៅ ហើយគេបានយកនំនោះ ទៅឲ្យក្អែក សូមឲ្យក្អែកយកទៅបូជាព្រះអាទិទេពមហាមេឃ សូមឲ្យព្រះអង្គទ្រង់ព្រះរាជទាន នូវសំណូមពរប្រាំប្រការគឺ :

ពរទី ១ សុំព្រះអង្គមេត្តារចនា រដូវទាំងបួន ទៅជារដូវមួយ គឺនិទាឃរដូវ ព្រោះរដូវនេះអាចធ្វើឲ្យសត្វលោកមានវឌ្ឍនភាព សម្បូណ៌ភាព ព្រមទាំងរចនាមនុស្ស មិនសូវឲ្យមានរោគ ដូចរដូវក្តៅណាស់ ត្រជាក់ណាស់នោះឡើយ ៗ

ពរទីពីរ សុំឲ្យធញ្ញជាតិទាំងឡាយ ព្រោះសាបតែម្តងជាការស្រប

ហើយផ្លែ ផ្កា រលំធ្លាក់ មកប្រគកាត់រៀនកល់ផ្គាតទៅ ដើម្បីចៀសវាងកុំឲ្យមនុស្សជឿយលំបាក ទីងក្ដួរកសាតទៅទៀត ។

ពរទីបី: សុំកុំឲ្យមានគង្គាភ័យ កយោព្យុះសង្ឃរា ឬ ព្រិលធ្លាក់នាំឲ្យមនុស្សវិនាសទ្រព្យសម្បត្តិ ផ្ទះសំបែង ។ល។

ពរទីបួន: សុំឲ្យមនុស្សទាំងឡាយនៅលើផែនដី ឲ្យមានសមភាពកុំបីមានយោបល់ផ្សេងគ្នា រវាងអ្នកមានអ្នកក្រ អ្នកក្រមិនអាចឲ្យអ្នកមានជិះជាន់បានឥតត្រាប្រណី ។

ពរទីប្រាំ: នៅក្នុងពិភពលោក កុំឲ្យមានការបែកបាក់គ្នារវាងមនុស្ស កុំឲ្យមានមន្ត្រី មានរាស្ត្រ ជាហេតុ កុំឲ្យមន្ត្រីធ្វើបាបរាស្ត្របាន។

ក្រោយដែលបានស្ដាប់សេចក្ដីសព្គ្រប់ហើយ ក្អែកក៏ហើរទៅលើនភាពល័យ យកនំនោះ ទៅថ្វាយព្រះឥទ្ធិទេព ហើយសូមពរប្រាំប្រការខាងលើ ។ ព្រះឥទ្ធិទេពទ្រង់ព្រះតម្រិះថា សំណូមពរនេះមានសភាពបរិសុទ្ធល្អ ក៏ទ្រង់ព្រមអនុញ្ញាតសំណូមពរនេះ បានសម្រេចទៅតាមសេចក្ដីបំណងនៃសត្វលោក តែព្រះឥទ្ធិទេពទ្រង់បានដាក់កំហិតដល់ក្អែកថា:

ឱអ្នកក្អែក អ្នកយកពរ ប្រាំប្រការ
ទៅឲ្យសត្វ ជាតិសង្សារ មនុស្សលោក
ឯងត្រូវហើរ តម្រង់ចំ គបជ័យជោគ

ឯងទៅដល់ ផុតភ័យកេត យកសុខសាន្ត ។
រូបឯងថា តាមួយម្ពង់ គបសម្រេច
ថាប្រាំដង ទើបផុតកិច្ច ឲ្យចាំបាន
តែកុំអួត ឈប់ទីណា រំហើយប្រាណ
រូបកុំពោល ពាក្យរឹងបាន ខកខានអើយ ។

ក្អែកទទួលព្រះរាជទង្វាព្រះអាទិទេព ក៏ហើរវិលត្រឡប់មកវិញ តែគង់ចិត្តគិតមថែថា «អញជាបក្សាវិសេសវិសាលជាងបក្សាទាំងឡាយ អញបានបំពេញបេសកកម្ម ដ៏ប្រសើរថ្លៃថ្លាឲ្យមនុស្សជាតិ នេះជាបេសកកម្មប្លែកអស្ចារ្យ គ្មានអ្នកណាធ្វើបានដូចអញ! អញជាបក្សាគួរឲ្យស្ញប់ស្ញែងពន់ពេក!» ។

ក្អែកនោះ ក៏ទៅទំលើផ្កាំងថ្មខ្ពស់មួយ ដែលខ្លួនធ្លាប់ទំសម្រាកពីដើមរៀងរាបដរាបមក ។ ក្អែកងើយក្បាលហើយទទះស្លាប ដើម្បីបង្ហាញនូវអាកប្បកិរិយាទៀយហាត់គង់បេសកកម្មនោះ ។

ផ្កាំងថ្មខ្ពស់នោះ ក៏សំដែងការកោតចំពោះក្អែក ហើយពោលពាក្យថា : «នុសំឡាញ់ក្អែកអើយ ក្អែកឯងបានបរិភោគអាហារដែលលាបខ្លាញ់ប៊ឺរ (Beurre) ដែលជាអាហារទិព្វ ដែលជាព្រះអំណោយដ៏ថ្លៃថ្លានៃព្រះដ៏រស់ (Boudha Vivant) ឬ? បើមិនដូច្នោះ ម្តេចក៏បងក្អែកឯងមានសាទរភាពអ្វីខ្លាំងម្ល៉េះ! ។

ក្អែកមិនតបទៅនឹងផ្ទាំងថ្មខ្ពស់ឡើយ ព្រោះបាននឹកឃើញព្រះបណ្តាំនៃព្រះអាទិទេព ថាកុំឲ្យពោលពាក្យអ្វីឲ្យសោះ!

ហើយផ្ទាំងថ្មខ្ពស់ក៏ថ្ងូរធំ ៗ ថា:

ឱសំឡាញ់! ឯងដូចជាមានសាទរភាពខ្លាំងក្លាស្វាហាប់ណាស់! អ្នកឯងមិនចង់ស្តី និយាយ នឹង ខ្ញុំផង! អ្នកឯងយល់ថាខ្ញុំជាបុគ្គលថោកទាប មិនសមនឹងអ្នកជាធំ មកមានការប្រាស្រ័យគ្នា ឬ! អ្នកឯងមើលមកខ្ញុំគ្មានសំលៀកបំពាក់ គ្មានគេហដ្ឋានជ្រក បានជាអ្នកឯងហ៊ានប្រមាថមើលងាយខ្ញុំ!

ក្អែកទប់មាត់មិនបាន ឈឺចិត្តខ្លាំងណាស់ ហើយពោលថា:

«ឱសំឡាញ់ផ្ទាំងសិលាខ្ពស់អើយ! អ្នកឯងប្រហែលជារងាហើយ ដោយអ្នកនៅអាក្រាតកណ្តាលព្រះពាយព្រះពិរុណដូច្នេះ ។ តើអ្នកឯងស្ថិតនៅក្នុងរដូវរងាយ៉ាងណាបាន!» ក្អែកក៏ងក់ក្បាល គិតបន្តិចក៏ពោលថា:

«ខ្ញុំបានយកសំណូមពរនៃព្រះអាទិទេពជាប់មកជាមួយនឹងខ្ញុំ ។ បងផ្ទាំងសិលាខ្ពស់នេះឯងដែលត្រូវបានជាលើកដំបូងនូវសំណូមពរនេះ តាំងពីថ្ងៃនេះតទៅ កុំឲ្យមានរដូវប្លែក ៗ គ្នា ។ អ្នកឯងលែងស្គាល់រងា លែងជួបប្រទះនឹងក្តៅក្រជាក់ ហើយអ្នកឯង លែងមានរោគាព្យាធិមកបៀតបៀនសោះឡើយ ដូចជាគ្រុនផ្តាសាយ ក្អកជាដើម ។

ក្រោយដែលក្អែកពោលដូច្នេះ ស្រាប់តែសំណូមពរនៃព្រះអាទិទេព

ជាលើកដំបូង ក៏បានសម្រេចជាសមិទ្ធិពេញបរិបូណ៌ គឺ: នៅលើផ្ទាំងសិលាខ្ពស់ទាំងឡាយ មានផ្ទះស្មៅមានពណ៌គ្រប់បែបយ៉ាង ពណ៌ក្រហម ស្វាយ ប្រផេះ ហើយស្មៅនោះស្ថិតនៅស្រស់បំព្រងជានិរន្តរ ។ តាំងពីថ្ងៃនោះមក ផ្ទាំងសិលាខ្ពស់ទាំងនោះ លែងមានក្តៅរងាអ្វីសោះឡើយ គ្មានរោគាព្យាធិទេ៖ ។

អ្នកដល់បានសម្រេច នូវសំណូមពរទីមួយហើយ ក៏មានចិត្តត្រេកអរខ្លាំងគ្មាពន់ពេក ទើបបន្តដំណើរទៅទៀត ។ អ្នកហើរទៅទំលើមែករុក្ខជាតិមួយដើម ដែលខ្លួនធ្លាប់ទំសម្រាកពីអតីតកាលមក ។ អ្នកងើយក្បាលហើយទទះស្លាបតិច ៗ បញ្ចេញអាកប្បកិរិយាប្លែកគួរឆ្ងល់ ។

រុក្ខជាតិសំដែងនូវគារវភាព ចំពោះអ្នក ហើយសួរថា:

«បងអ្នក ! បងឯងមានបានបរិភោគនូវអាហារ ដ៏ប្រសើរដែលគេហៅជាសម្បា (Samba) (អាហារនេះមិនដឹងជាធ្វើបែបណា គ្មានន័យនៅទីណាសោះឡើយ ប្រហែលជាពាក្យទិបេតាំង . . . » ឬ ?)

អ្នកឥតតបតទៅនឹងរុក្ខជាតិសោះឡើយ ។ អ្នកគ្រាន់តែងក់ក្បាលហើយទទះស្លាបតទៅទៀត ។

ហើយរុក្ខជាតិក៏ថ្លែងថា: «បងអ្នក យើងទាំងពីរនាក់ជាមិត្តភក្តិនឹងគ្នា អ្នកឯងប្រហែលជាមានប្រាថ្នានូវរឿងពិសេសណាមួយមិនខាន បានជាមិនពោលមកសោះ ។ អ្នកឯងមើលងាយមិត្តភក្តិដូចខ្ញុំដែលជាអ្នករស់

ទៅដោយលំបាកគោកយ៉ាក

ក្អែកអត់ទ្រាំពុំបាននឹងរាំពារុក្ខជាតិផ្ដោះផ្ដងឲ្យ ក៏តបថា :

„ឱមិត្តសំឡាញ់អើយ! ខ្ញុំនៅតែមានចិត្តស្មោះស្ម័គ្រ ដោយមិត្តភាពចំពោះអ្នក! អ្នកមានជីវិតតិចតួចស្ដួចស្ដើងណាស់ បានជាខ្ញុំមិនដែលជួបសោះក្នុងមួយឆ្នាំ ៗ ក្រោយដែលបានពោលដូច្នេះ ក្អែកក៏ឱនក្បាលហើយគិតក្នុងចិត្ត រួចក៏សម្រេចថា :

„ឱបងរុក្ខជាតិ! ខ្ញុំបាននាំបណ្ដាំព្រះអាទិទេពមកជូនអ្នក ដោយអ្នកមានចិត្តស្មោះស្ម័គ្រនឹងខ្ញុំ ។ តាំងពីបច្ចុប្បន្នកាលនេះទៅ ខ្ញុំសូមឲ្យរុក្ខជាតិទាំងឡាយដុះ ហើយមានផ្កាផ្លែរាល់ឆ្នាំកុំឲ្យដាច់ ហើយសូមឲ្យមួយឆ្នាំធំបន្តិច ៗ រួចយូរ ៗ ទៅ អ្នកឯងនឹងមានអាយុវែង គ្រួសារអ្នកឯងនឹងប្រកបដោយសម្បូណ៌ភាព „ ។

ក្រោយដែលក្អែកពោលមិនទាន់ផុតពីមាត់ផង បណ្ដាំនៃព្រះអាទិទេព ក៏សម្រេចដូចបំណង ។ តាំងពីនោះមក រុក្ខជាតិទាំងឡាយ មានជីវិតរស់នៅក្នុងមួយឆ្នាំ ៗ មានផ្កាផ្លែជានិរន្តរ៍ ។ រុក្ខជាតិទាំងឡាយ ក៏ដុះពាសពេញជ្រោះបព្វតា បែកមែកគ្រសុំសាខា ក្លាយទៅជាព្រៃក្រាស់ ។

ក្អែកក្រឡេកទៅឃើញទេសភាពបែបនេះ ក៏មានទះនោះសោមនស្សជាយ៉ាងក្រៃពេក ហើយក្អែកក៏ហើរទៅកាន់មនុស្សជាតិ ដែលរង់ចាំ ខ្ទមគ្រៀបគ្រា ។

កាលណាក្អែកទៅដល់ពួកមនុស្សជាតិ ហើយបានក្រឡេកទៅឃើញក្អែកគ្រប់ ៗ គ្នា មានសេចក្ដីសង្ស័យយ៉ាងម៉ាំ ក្អែកក៏មានមនោរំញោកដោយយល់ឃើញថា បណ្ដាំអាទិទេពដែលខ្លួនបានបែកទៅសិលានិងរុក្ខា ជាបណ្ដាំមានសារៈសំខាន់ពន់ពេក តែពរព័រខានចុង មិនសូវមានប្រយោជន៍ ហើយពរដែលមនុស្សជាតិសុំ មិនបានសម្រេចដូចបំណង ៗ ហេតុនេះ ក្អែកក៏គិតក្លួកកពួកមនុស្សជាតិថា:

«ព្រះអាទិទេព មិនព្រមប្រទានពរមកលោកអ្នកទេ ព្រះអង្គទ្រង់មានព្រះបន្ទូលថា នៅពិភពលោកនេះ មានសេចក្ដីសុខស្រួលសប្បាយហើយ» ។

ក្រោយដែលក្អែកពោលដូច្នេះ ពួកមនុស្សជាតិ ក៏មានចិត្តតប់ប្រម៉ល់ជាយ៉ាងខ្លាំង ហើយក៏សំដែងអាកប្បកិរិយាអស់សង្ឃឹម ហើយស្រែកថា: «បើដូច្នេះហើយ យើងត្រូវតែរស់នៅដោយទុក្ខទោសភ័យលំបាកគោកយ៉ាកជានិរន្ដរ៍» ។

បន្ទាប់ទៀត ព្រះអាទិទេពបាននឹកទៅដល់ទំដែលពួកមនុស្សជាតិបានយកមកថ្វាយព្រះអង្គ ៗ ពួកមនុស្សជាតិនោះ បានប្រាប់ក្អែកថាឲ្យពន្យល់ព្រះអាទិទេពថា មុននឹងសោយទំនេះ សូមព្រះអង្គទ្រង់យកទំនោះទៅចំអិននិងចំហាយក្ដៅសិន តែក្អែកនោះភ្លេចសូន្យឈឹង ឥតបានជំរាបព្រះអាទិទេព ៗ ព្រះអាទិទេព ព្រះអង្គទ្រង់បានយកទំនោះទៅចំអិន

ទឹងអណ្តាតភ្លើង នំនោះក៏រលាយបាត់ ៗ ព្រះអាទិទេពទ្រង់ព្រះក្រោធ ខ្លាំង ហើយមានទេវវាចាថា :

..មនុស្សដែលស្ថិតនៅក្នុងជម្ពូទ្វីបជាមនុស្សទុច្ចរិត ៗ ខ្ញុំបានឲ្យពរ សព្វសាធុការ ចំពោះមនុស្សជាតិ ហើយមនុស្សនេះ វាយកនំដែល បរិភោគមិនកើតមកឲ្យអញ ៗ នឹងផ្តន្ទាទោសមនុស្សលោក កុំឲ្យវាមើល ងាយអញដល់ថ្នាក់នេះ ៗ មានព្រះឧក្ការជូបេះ ទ្រង់ក៏ត្រាស់បង្គាប់ឲ្យ ទេវតាកួរស្រូវប្រាំ (dieu de cinq Epis) ឲ្យចុះមកជម្ពូទ្វីបយកគ្រាប់ ធញ្ញជាតិទាំងអស់ ដែលស្ថិតនៅលើផែនដី ៗ

ក្នុងពេលនោះ គ្រាន់តែស្រូវសាឡី ប្តៅ ស្រងែ សណ្តែកវែង សណ្តែកបារាំង ស្ថិតនៅតាំងពីឫសរហូតដល់ចុង ៗ រួចទេវតា ងាកទៅ បេះគ្រាប់ស្រូវ ដែលស្ថិតនៅខាងចុង ស្រាប់តែបក្សាទាំងឡាយចូលទៅ ក្រាបថ្វាយបង្គំអង្វរទេវតាថា :

បពិត្រទេវតាអើយ ! ម្តេចក៏ព្រះអង្គមិនទុកគ្រាប់ធញ្ញជាតិខ្លះឲ្យ យើងខ្ញុំទាំងឡាយបានបរិភោគផង ហើយខ្ញុំទាំងឡាយនឹងស្លាប់ដោយ សារអត់អាហារ ! ៗ ទេវតាក៏មានព្រះហឫទ័យសោមនស្សពន់ពេក ក៏ទុក គ្រាប់ស្រូវសាឡីខ្លះនៅខាងចុងដើម ៗ រួចបក្សាបក្សីទាំងឡាយ ក៏ថ្វាយ ភាគមានអំពីក្អែកទុច្ចរិត ៗ

ព្រះអាទិទេពមហាមេឃ ក៏កោះហៅក្អែកទៅបណ្តាសាថា :

សូម្បីតែមច្ចុរាជមកផ្តាច់ជីវិតអាឯង ក៏មិនសមនឹងកំហុសរបស់អាឯងដែរ ។ កំហុសរបស់អាឯងធំណាស់ ។ អញឲ្យអាឯងរស់នៅលើដើមប៉ុប្លីយេ (peuplier) គ្មានស្លឹក ផ្លែ ផ្កា សោះឡើយ ។ នៅទិវាយរដូវទន់វស្សានរដូវ ទើបឯងនឹងរកអាហារបានតែនៅសិសិររដូវ ឯងនឹងគ្មានសំបុកជ្រក ។ កល់យប់ សេចក្ដីរងា ដោយការយោនឹងបោកបក់ឯងធ្លាក់មកដីជានិរន្តរ៍ៗ នៅមុនបច្ចុសសម័យ ឯងនឹងរងាញ័ររំប្រប់នៅលើចុងឈើ ៩ ជង់ ។ ស្លាបឯងនឹងជ្រុសអស់ ហើយមនុស្សជាតិគេនឹងទុកឯងជាបក្សាលំបាកគោកយ៉ោក

ម្ល៉ោះហើយ តាំងពីនោះមក មនុស្សជាតិរស់នៅដោយខ្លួន ៗ ឯងបានចំណែកគ្រាប់ស្រូវធញ្ញជាតិ ដែលទេវតាក្ពួរស្រូវប្រាំ លោកបានទុកឲ្យ ។

តាំងពីថ្ងៃនោះមក គ្រាប់ធញ្ញជាតិទាំងឡាយក៏ដុះនៅតែខាងចុង លើដើមប៉ុណ្ណោះ ក្អែកគ្មានសំបុកនៅសិសិររដូវ រស់នៅតែលើដើមប៉ុប្លីយេគ្មានស្លឹក ផ្កា ផ្លែហើយធ្លាក់មកពីលើចុងឈើ ៩ ជង់ នៅព្រះអរុណរះបេះតែជ្រុសស្លាប ។

# សំបុត្រទីប្រាំបី

## ប្រភេទមនុស្សផ្សេង ៗ បានកកើតឡើងដូចម្តេច ?

លោក ឈន អៀម ប្រែពីភាសាអង់គ្លេស

---

យើងបាននិយាយដដែលៗនៅក្នុងសំបុត្ររបស់យើងមុន អំពីមនុស្សនៃយុគថ្មី ដែលធ្លាប់រស់អាស្រ័យនៅយ៉ាងច្រើនក្នុងលំនៅបឹង ៗ យើងបានឃើញថាគេមានសេចក្តីចំរើនយ៉ាងខ្លាំងក្នុងផ្លូវជាច្រើន ៗ គេបានរកឃើញកសិកម្ម ហើយបានចេះស្លរដាំ ផ្សាំងសត្វសម្រាប់ប្រើប្រាស យ៉ាងដូចម្តេចផង ៗ រឿងទាំងអស់នេះ បានកន្លងទៅច្រើនពាន់ឆ្នាំហើយ ហើយយើងក៏ពុំបានដឹងអ្វីច្រើនអំពីរឿងទាំងនោះដែរ ៗ ប៉ុន្តែ តាមស្នាម ភាគច្រើននៃអម្បូររបស់មនុស្ស ដែលមាននៅក្នុងពិភពលោកសព្វថ្ងៃ បានជាបន្តពូជមកអំពីប្រជាជននៃយុគថ្មី ៗ ដូចកូនដឹងស្រាប់ សព្វថ្ងៃនេះ យើងឃើញមានមនុស្សស្បែកស មនុស្សស្បែកលឿង ស្បែកទង់ដែង និងស្បែកខ្មៅ ៗ ប៉ុន្តែតាមពិត ពិបាកនឹងចែកពូជទាំងឡាយរបស់មនុស្សជាបួនផ្នែកយ៉ាងនេះ ៗ ពូជអម្បូរទាំងឡាយបានប្រឡូកប្រឡំគ្នា ហើយពិបាកនឹងនិយាយឲ្យច្បាស់លាស់ថាពូជទាំងនេះជារបស់ផ្នែកណា ៗ អ្នកវិទ្យាសាស្ត្រវាស់ក្បាលមនុស្សទាំងឡាយ ហើយដោយសារវាស់នេះ ជួនកាលលោកអាចរកឃើញពូជអម្បូរបាន ៗ មានមធ្យោបាយដទៃទៀតដែរ សម្រាប់រកឲ្យឃើញពូជអម្បូរនេះ ៗ

តើពូជអម្បូរផ្សេងៗ ទាំងនេះ បានកកើតឡើង យ៉ាងម្ដេច? បើជាពូជអម្បូរទាំងអស់មានតំណមកពីប្រជាជនតែមួយពួក តើព្រោះហេតុអ្វីក៏មនុស្សទាំងនោះ ប្លែកគ្នាពីមួយទៅមួយខ្លាំងម្ល៉េះ? កូនដឹងថាជនជាតិអាល្លឺម៉ង់ ប្លែកអំពីជនស្បែកខ្មៅណាស់ៗ ម្នាក់មានសម្បុរចន់ថែង ឯម្នាក់ទៀតសម្បុរខ្មៅៗ សក់របស់ជនជាតិអាល្លឺម៉ង់ មានពណ៌ថ្លា ហើយវែង សក់របស់ជនស្បែកខ្មៅខ្លី ហើយក្រញាញ់ៗ ជនជាតិចិនក៏ប្លែកអំពីជនទាំងពីរនេះដែរៗ នេះពិបាកនិយាយថា តើការប្លែកគ្នានេះបានជ្រៀតចូលមកយ៉ាងដូចម្ដេច តែថាយើងដឹងខ្លះ នូវបុព្វហេតុនៃការប្លែកគ្នានេះៗ ឪពុកបាននិយាយប្រាប់កូនហើយថា សត្វទាំងឡាយបានផ្លាស់ប្រែបន្តិចម្ដងៗ យ៉ាងដូចម្ដេចខ្លះ នៅពេលដែលវាអនុលោមខ្លួនវាឲ្យស្របទៅនឹងសភាពទាំងឡាយនៅជុំវិញខ្លួនវាៗ ឥឡូវនេះ គឺគេអាចស្មានបានថាជនជាតិអាល្លឺម៉ង់ នឹងជនស្បែកខ្មៅមានតំណចុះមកពីបែបទាំងឡាយ (Types) ផ្សេងគ្នានៃមនុស្ស ប៉ុន្តែពេលមុន ជនទាំងនោះច្បាស់ជាមានបុព្វបុរសតែមួយៗ តែថាការផ្សេងគ្នា ត្រូវបានចូលមកតាមបែបនៃការអនុលោមឲ្យស្របទៅនឹងសភាពទាំងឡាយនៅជុំវិញ ឬ ក៏អាចនិយាយថា មនុស្សពួកខ្លះ ដូចជាសត្វពួកខ្លះដែរ អាចសម្រេចខ្លួនគេបានស្រួលជាងមនុស្សពួកដទៃទៀតៗ

ដូច្នេះ មនុស្សធ្លាប់រស់នៅក្នុងភូមិភាគទឹកកក ដែលត្រជាក់ខ្លាំង

នៃតំបន់ឆ្ងាយទៅខាងជើង អាចបង្កើននូវកំឡាំងសម្រាប់ទ្រាំទ្រនឹងត្រជាក់បាន ។ ជនជាតិអេស្គីម៉ូ (Eskimos) ស៊ូម្បីតែសព្វថ្ងៃនេះ គឺរស់នៅបានក្នុងភូមិភាគទឹកកកនៃតំបន់ខាងជើង ហើយគេអាចទ្រាំទ្រនឹងត្រជាក់យ៉ាងខ្លាំងបាន ។ ប្រហែលជាគេត្រូវស្លាប់ទៅវិញ បើសិនជាកូននាំគេមកនៅក្នុងប្រទេសក្ដៅដូចជាប្រទេសយើង (ឥណ្ឌៀ) ។ ហើយដោយគេនៅឆ្ងាយដាច់ពីផ្នែកឯទៀតនៃពិភពលោក ទឹងត្រូវរស់នៅក្នុងជីវភាពយ៉ាងតឹងតែង ទើបគេមិនបានចេះដឹងអ្វីច្រើនដូចជាប្រជាជននៅក្នុងផ្នែកឯទៀតនៃពិភពលោកឡើយ ។ ប្រជាជននៅទ្វីបអាហ្វ្រិក ឬ ប្រជាជនដែលរស់នៅក្នុងទីជិតសូរិយបថ (Equator) ដែលជាភូមិភាគក្ដៅណាស់ រមែងធ្លាប់នឹងកំដៅនេះបាន ។ ហើយកំដៅយ៉ាងខ្លាំងរបស់ព្រះអាទិត្យ ធ្វើឲ្យគេមានសម្បុរស្បែកខ្មៅ ។ កូនដឹងថា បើកូនទៅហាលថ្ងៃអស់ពេលយ៉ាងយូរ នៅឆ្នេរខ្សាច់មាត់សមុទ្រ ឬ កន្លែងណាមួយ កូននឹងត្រឡប់ជាមានសម្បុរក្រហមលឿងឬលឿងក្រមៅជាងសម្បុរកូនពីមុន ។ បើប្រសិនជាកន្លងទៅពីរបីអាទិត្យ ក្រោយពីការហាលថ្ងៃមក កូនត្រឡប់ជាមានសម្បុរក្រមៅ តើមនុស្សដែលរស់នៅជានិច្ចជាកាលក្រោមកំដៅថ្ងៃនឹងមានសម្បុរក្រមៅយ៉ាងណាទៅ ? ហើយប្រសិនបើប្រជាជនរស់នៅក្នុងប្រទេសយ៉ាងក្ដៅកប់រយឆ្នាំ ទាំងឪពុកទាំងកូនទាំងចៅទួតលួតតគ្នាទៅ គេមុខជាក្លាយទៅជាមានសម្បុរក្រមៅឡើង ។ រហូតដល់គេមាន

សម្បុរស្បែកស្ទើរខ្មៅស្ទុះ ។ ខ្ញុំបានឃើញអ្នកស្រុកស្រែចំការជាតិឥណ្ឌា ដែលធ្វើការនៅក្នុងស្រែចំការ ក្រោមកំដៅព្រះអាទិត្យ កណ្តាលថ្ងៃត្រង់ ។ គេជាមនុស្សក្រីក្រពេកណាស់ គ្មានសំលៀកបំពាក់ច្រើនទេ មានតែបន្តិចបន្តួចគ្របខ្លួន ។ រាងកាយទាំងមូលត្រូវនៅហាលថ្ងៃ ហើយមួយជីវិតរបស់គេ ៗ រស់នៅរបៀបនេះ ។ គេក៏មានសម្បុរក្រមៅឡើង ។

ដូច្នេះ យើងឃើញថាសម្បុរស្បែករបស់មនុស្សគឺជាលទ្ធផលនៃអាកាសធាតុដែលគេរស់នៅ ។ សម្បុរស្បែកពុំមានទាក់ទងអ្វីទៅនឹងគុណសម្បត្តិ ឬសប្បុរសធម៌ ឬក៏សោភណភាពនៃបុគ្គលឡើយ ។ មនុស្សស្បែកស រស់នៅយូរក្នុងប្រទេសក្តៅណាមួយ គង់នឹងទៅជាមានសម្បុរក្រមៅមិនខាន ប្រសិនជាគេមិនលាក់បំពួនអង្គាអំពីកំដៅថ្ងៃ នៅក្នុងម្លប់នឹងក្រោមគម្ហារទេ ។ ខ្ញុំដឹងថា យើងជាអ្នកស្រុកកស្មីរ ហើយជាង ២០០ ឆ្នាំមកហើយ ជីដូនជីតារបស់យើង បានរស់នៅក្នុងស្រុកកស្មីរ ។ នៅស្រុកកស្មីរ ខ្ញុំឃើញមនុស្សគ្រប់គ្នា មានសម្បុរស្បែកពណ៌សល្អក ហាយ ទាំងអ្នកស្រុកស្រែចំការទាំងកសិករ ។ នេះក៏ព្រោះតែអាកាសធាតុនៅស្រុកកស្មីរត្រជាក់ ។ តែថា អ្នកស្រុកកស្មីរនេះឯង ប្រសិនជាចុះទៅកាន់តំបន់ឯទៀតនៃប្រទេសឥណ្ឌា ដែលជាប្រទេសក្តៅជាង មុខជាក្លាយទៅជាមានសម្បុរក្រមៅឡើង ក្រោយពីរបីតំណមក ។ មិត្រ

គត្តិនៅស្រុកកស្មីររបស់យើងជាច្រើន មានសម្បុរស្បែកពណ៌សណ្តែក ចុយសុទ្ធសាធ ខ្លះទៀតមានសម្បុរក្រមៅ ។ គ្រួសារអ្នកស្រុកកស្មីរ ណា បានរស់នៅភូមិភាគនេះ នៃប្រទេសឥណ្ឌៀយូរទៅ គ្រួសារ នោះ ហាក់ដូចជាមានសម្បុរស្បែករឹតតែក្រមៅឡើង ៗ

យ៉ាងដូច្នេះ អាកាសធាតុ គឺជាបុព្វហេតុសំខាន់នៃពណ៌នឹងសម្បុរ ស្បែក ។ ពិតមែន គឺអាចមានមនុស្សខ្លះ សូម្បីតែរស់នៅក្នុងប្រទេស ក្តៅណាមួយក៏ដោយ គង់មិនធ្វើការនៅកណ្តាលថ្ងៃ ហើយជាមនុស្ស មានទ្រព្យគ្រប់គ្រាន់ រស់នៅតែក្នុងផ្ទះយ៉ាងធំ ហើយថែទាំតែខ្លួនប្រាណ នឹងសម្បុរស្បែករបស់គេ ៗ គ្រួសារអ្នកមាន អាចរស់នៅយ៉ាងនេះ រាប់តំណ ក៏អាកាសធាតុពុំមានអានុភាពប៉ុន្មានទៅលើគេឡើយ ។ តែថា មិនធ្វើការងារដោយខ្លួនឯង ហើយចាំតែរស់នៅដោយសារការងារអ្នក ដទៃ ក៏ពុំមានអ្វីគួរឡើងចាងឡើយ ។

នៅប្រទេសឥណ្ឌៀ កូនឃើញថា ក្នុងភាគខាងជើង ក្នុងស្រុក កស្មីរ នឹងពន្ជាប ប្រជាជន តាមធម្មតា មានសម្បុរពណ៌សណ្តែកចុយ ៗ ប៉ុន្តែ ដល់កូនទៅភាគខាងត្បូងវិញ ប្រជាជនទៅជាមានសម្បុរក្រមៅ នៅម៉ាដ្រាស និង សីឡង់ ដូចកូនឃើញស្រាប់ គេរឹតតែមានសម្បុរ ក្រមៅមែនទែន ។ ពិតមែន កូនមុខជានិយាយថា នេះបណ្តាលមក ពីអាកាសធាតុ ព្រោះថានៅពេលដែលកូនទៅកាន់ភាគខាងត្បូង កូន

រិតតែទៅជិតសុរិយបថឡើង ហើយអាកាសធាតុរិតតែក្តៅឡើងដែរ ។ នេះ ពិតជាដូច្នោះមែនហើយ ហើយជាវិចារណញ្ញាណសំខាន់សម្រាប់ការប្លែកគ្នានៃពណ៌ក្នុងភូមិភាគខុសគ្នា នៃប្រទេសឥណ្ឌា ។ ម្យ៉ាងទៀត យើងនឹងឃើញនៅពេលក្រោយថា ការផ្សេងគ្នានេះ បណ្តាលមកពីការខុសគ្នាខ្លះ នៃពូជដើមដែលបានមកកាន់ប្រទេសឥណ្ឌា មួយចំណែកដែរ ។ មានពូជអម្បូរជាច្រើន បានមកកាន់ប្រទេសឥណ្ឌាក្នុងសតវត្សរ៍ទាំងឡាយ ដែលកន្លងទៅហើយ ហើយទោះបីជាគេរិតខំរស់នៅដោយឡែកពីគេអស់ពេលយ៉ាងយូរក៏ដោយ គេក៏ពុំអាចគេចឲ្យផុតពីការលាយឡំគ្នាបានដែរ ។ សព្វថ្ងៃនេះ ពិបាកនឹងនិយាយថាជនជាតិឥណ្ឌាណាម្នាក់ មានដើមកំណើតទាំងស្រុង មកពីពូជអម្បូរដើមមួយ ។

---

> បុគ្គលឥតការសិក្សា មិនត្រូវធ្វើការប្រញាប់ប្រញាល់ទេ ព្រោះការខ្វះខាតការពិចារណាត្រឹមត្រូវ ជាប្រភពនៃសេចក្តីវិនាស ។ ការពិចារណាត្រឹមត្រូវហើយសឹមធ្វើ គឺបុគ្គលត្រូវការចង់បាន ព្រោះសម្បត្តិគឺសេចក្តីចំរើន បុគ្គលដែលមានគុណសម្បត្តិល្អ ត្រូវបានដោយខ្លួនឯង ។
>
> ហិតោបទេស

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

> ទំនៀមទម្លាប់ នៃខេមរៈជាតិ
> ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
> ព្រោះខេមរៈជាតិ ជាជាតិសោភី
> ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។
>
> — ប. ក. —

## របាំស្នែងទន្សោង

នៅតាមស្រុកភូមិ ក្នុងព្រះរាជអាណាចក្រ ជាពិសេសភូមិភាគ ដែលស្ថិតនៅត្រើយខាងត្បូងបឹងទន្លេសាប គេឃើញមានសេសសល់ របាំប្រជាប្រិយមួយបែប ដែលអ្នកស្រុកសន្មតហៅតមកថា « របាំស្នែងទន្សោង » ។ សព្វថ្ងៃឃើញមាននៅតាមខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងពោធិ៍សាត់ ។ បានជាឈ្មោះថា « របាំស្នែងទន្សោង » ព្រោះរបៀបរាំនេះអាស្រ័យដោយស្នែងទន្សោង និងមានក្បាច់ត្រាប់តាមកាយវិការរបស់សត្វទន្សោង ។

ដើម្បីនឹងជូនអ្នកអានឲ្យបានយល់ច្បាស់ អំពីរបាំប្រជាប្រិយនេះ យើងសូមធ្វើជាសេចក្ដីរៀបរាប់លំអិតបន្តិចដូចតទៅ ៖

### ១ – អំពីប្រដាប់ប្រដា

ក – គ្រឿងភ្លេង. – ប្រដាប់ដន្ត្រីសំរាប់ប្រគំរបាំនេះ មានតិចណាស់ គឺមានតែស្គរ ២ កញ្ចា ១ និងក្លុយ ១ ។

ស្គរ.- ស្គរនេះធ្វើពីឈើធ្នង់ គឺលុងឈើមួយកង់ឲ្យនៅសល់តែសាច់ខាងក្រៅស្តើងល្មម គេពាសស្បែកគោដែលហាលស្ងួតស្អាប់ សាច់ទាំងសងខាង ។ អន្ទង់វាយស្គរនេះ គេយកគល់ព្រេចស្ងួត មកកាត់ល្មម ឲ្យស្រួលកាន់វាយ ។

កញ្ចា.- ដូចកញ្ចាត្រដៃដែរ គឺយកដងឫស្សីប្រវែង ២ ម៉ែត្រមកធ្វើ ហើយខាងចុងមានពត់បន្ទះឫស្សីដែលបិតស្តើងជាដងធ្នូនឹងគ្នា ទីងព្យួរគ្រាប់អង្គញ់នៅកណ្តាល សំរាប់ចុកឲ្យឮសូរ ។

ក្លុយ.- ដែលហៅថាក្លុយនេះ គឺជាប្រដាប់ផ្លុំជាសូរសំនៀងពិរោះដូចខ្លុយដែរ តែក្លុយធំជាង ។ គេធ្វើក្លុយពីសំបកឃ្លោកមូលដោយបន្ទាំភ្ជាប់ឫស្សីពកប្រាំកង់ទីងឃ្លោកនោះ សំរាប់ដាក់អណ្តាតបញ្ចេញខ្យល់ ហើយគេផ្លុំសំបកឃ្លោក តាមចុងឫស្សីពកបន្តឲ្យចេញខ្យល់តាមរន្ធទាំង ៤ ដោយយកម្រាមដៃចុចបិទបើករន្ធទាំងនោះ ធ្វើឲ្យមានសព្ទសូរប្លែក ៗ ជាបទបែបឡើង មានសណ្តានប្រហែលនៃនៅស្រុកលាវ ។

១ - គ្រឿងតែង.- ចំពោះគ្រឿងតែងកាយនៃអ្នករប៉ាំនេះវិញ ពុំមានអ្វីជាពិបាកទេ ព្រោះពីដើមគេពុំបាច់តែងខ្លួន គេស្លៀកពាក់តែតាមទំលាប់ខ្មែរអ្នកស្រុកសាមញ្ញនៅតាមជនបទ គឺស្លៀកសំពត់ចងក្បិនពាក់អាវបំពង់កមូលដៃខ្លី បើជាមនុស្សស្រី មានក្រមាបង់កជាបុរស មានក្រមាក្រវាត់ចង្កេះ ។ ឯប្រដាប់ប្លែកនោះ មានតែស្នង-

ទន្សោងពីរ គឺយកស្នែងទន្សោងមែនទែន មកចងភ្ជាប់នឹងផ្តៅដែលពត់ជាវង់មូលល្មមពាក់ជាប់នឹងក្បាលមនុស្សកើត ។ ជួនកាលបើគ្មានស្នែងមែនទែនទេ គេយកផ្តៅពត់ឲ្យមានសណ្ឋានជាស្នែងទន្សោងក៏បាន ។ កន្ទុយក្ងោកវែង ៗ ចងក្រងតម្រៀបគ្នា ហើយមានខ្សែក្របួចទៅភ្ជាប់នឹងក្បាលមនុស្ស អ្នកពាក់ស្នែងមានពីរនាក់ ។ ក្បាលសេះពីរទៀតគេធ្វើពីក្រដាសខ្ចុកសំរាប់សិកពីលើក្បាលមនុស្សឲ្យល្មមជាប់បាន ។

## ២ – អំពីរបៀបលេង

សមាជិកនៃវង់បាំនេះ មានតែ ៧ នាក់ប៉ុណ្ណោះ គឺប្រុសបីនាក់កាន់គ្រឿងភ្លេង ស្រ្តីពីរនាក់ពាក់ស្នែងទន្សោង ស្រ្តីពីរនាក់ទៀតជាអ្នកច្រៀងបើកបរ នឹងជាអ្នកបន្ទរ (១) ។

ឯរបៀបរាំបាំនេះ មានដូចតទៅ ៖

អ្នកវាយស្គរចាប់វាយស្គរឡើងជាបឋមមុខគេ សំរាប់ឲ្យអ្នករាំទាំងអស់គ្នា បង្អោនកាយលើកដៃប្រណម្យថ្វាយបង្គំគ្រូ ។ រួចហើយខ្លុយក៏ចាប់ផ្លុំឡើងស្របជាមួយ ស្គរក៏ប្តូរសំឡេងជាចង្វាក់រង្គើល ៗ ឡើងវិញ ៗ រីឯអ្នកផ្លុំខ្លុយ ផ្លុំផងរាំផង គឺរាំដំបូងគ្រាន់តែយោលខ្លួនបន្តិច ៗ រួចបង្កើត

១ - ត្រង់ថាមានស្រ្តីរាំនេះ តាមឯកសាររបស់ទីចាត់ការសិល្បៈ ដែលបានទៅមើលឃើញនៅភូមិអញ្ចាញរូង (កំពង់ឆ្នាំង) ឯឯកសារលោក រ.បាដាភាត់ក្នុង BEFEO វិញ ថាប្រុសរាំទាំងអស់ សុទ្ធតែជាមនុស្សពេញវ័យ ហើយមានចំនួនមនុស្សច្រើន ដូចជាមានថែមអ្នកពាក់កន្ទុយក្ងោកនឹងក្បាលសេះជាដើម ។

ដាចផ្ទាក់កាន់តែញាប់ឡើង ៗ រហូតបានទៅជាកាយវិការព្រានព្រៃម្នាក់ យ៉ាងស្វាហាប់ ដោយមានបំបះចុងក្លុយផ្ទៀងផ្ទង ទំនងជាព្រានរុករក មើលអម្រឹត ទឹងមានទឹកមុខម៉ាំហាក់ដូចកាចសាហាវណាស់ ។

បន្ទាប់មកអ្នកពាក់ស្នែងខ្ទេព្វងចាប់ចេញរាំ ធ្វើកាយវិការគ្រាប់ដំណើរសត្វខ្ទេព្វង ប្រកបដោយក្បាច់ទន់ភ្លន់កែក្រោយ ហើយប្រកៀងគ្នាបុះបោះឡើង ។

ឯអ្នកច្រៀងបើកបទ កាន់ធូបមួយសរសៃចាប់ចេញរាំតាក់ក្បាច់ រំពើតរំពើងតាមចង្វាក់ភ្លេង ហើយច្រៀងបើកបទព្យុក្រត រាប់រៀបពីចលនា នៃសត្វខ្ទេព្វង ព្រមទាំងម្នាក់ទៀតរាំពីក្រោយជួយស្រែកបន្ទរតាមផង ។

ដូច្នេះឃើញថាអ្នកលេងរបាំនេះទាំងអស់គ្នា សុទ្ធតែជានាដករទាំងអស់ ទោះជាអ្នកវាយស្គរក៏រាំដែរ ។ ឯរបៀបធ្វើជាឈុតនោះគឺ:

ដំបូងឡើងចេញព្រានព្រៃ ( អ្នកកាន់ក្លុយ ) ដើរបែបស្ទាច ៗ ជើង ភ្នែកក្រឡេកក្រឡាប់ឆ្វេងស្ដាំ ដើរវង់ជុំវិញក្នុងវាលដែលលេងរបាំ ។ បន្ទាប់មកចេញខ្ទេព្វងមួយគូមកដើរបែបផ្អើល ៗ អង្គុញជើង តន្ទក ក្បាលជង្គង់ ហើយឈានបែបធីងធាង ៗ ។ ដៃទាំងពីរជូនសំយុងទៅមុខធ្វើបែបជាជើងមុខ ជួនប្រត់ចង្កេះទាំងសងខាង ហើយយូរ ៗ ម្ដង ធ្វើជាជល់ក្បាលគ្នាលេង ។ ចុងបំផុតមានខ្លាចេញមកបែបលប ៗ ដើរ ឈប់ ៗ នៅក្បែរវង់លេងរបាំ ហើយអើតកសំឡក់ទៅខ្ទេព្វងទាំងពីរ

ចះដើរក្រវែលពីក្រោយទន្សោង ពីក្រោយព្រានទោះទៅទៀត ។

បើមានអ្នកធ្វើជាក្ងោកជាសេះបន្ថែមក្នុងវង់នេះទៀត អ្នកនោះត្រូវចេញមកបន្ទាប់ពីទន្សោង ហើយធ្វើកាយវិការប្រហែលទន្សោងដែរ ។ ឯអ្នកច្រៀងនេះពិតមែនតែមិនដើរធ្វើឡា តែក៏ជួយរាំរេខ្ញូនដែរ ។

## ៣– អំពីទំនុកច្រៀង

ទំនងមើលទៅ បទច្រៀងពិតជាមានច្រើនបែបច្រើនយ៉ាង តាមការតាក់តែងនៃអ្នកស្រុកផ្សេងៗគ្នា ប៉ុន្តែ ក្នុងទីនេះយើងលើកយកតែទំនុកណាដែលគេស្គាល់ច្រើន មកធ្វើជាឧទាហរណ៍ ។

« … ទន្សោងស្នែងទប់ រកស៊ីតែយប់
ទន្សោងស្នែងទប់ ថ្ងៃឡើងពួនព្រៃ ។
ទន្សោងស្នែងកែក ស៊ីបែកពីហ្វូង
ទន្សោងស្នែងប្រួង វ័ធហ្វូងបែកខ្លាយ ។
ទន្សោងគោបា ស៊ីបន្លាផ្តិ
ទន្សោងព្រៃភ្នំ លេបក្រមុំតាំងមូល ។

តាមឯកសារលោក រ-បារ៉ាដាត់ (១)

---

1— R. BARADAT, Les Samrê ou Pèar, BEFEO Tome XLI, 1941 P. 97 .

# ពិធីសម្ពោធឆ្លងគ្រឹះស្ថានពុទ្ធិកសិក្សា

## សម្តេចព្រះនរោត្តម សីហនុ

ក្រុងភ្នំពេញ

ដើម្បីធ្វើឲ្យព្រះពុទ្ធសាសនាបានរីកចំរើន សម្តេចព្រះប្រមុខរដ្ឋជាព្រះបិតាឯករាជ្យជាតិ ក្នុងឋានៈព្រះអង្គជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក ព្រះអង្គបានស្តេចយាងទៅជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធឆ្លងគ្រឹះស្ថានពុទ្ធិកសិក្សាមួយខ្នងនៅក្នុងបរិវេណ ក្រសួងធម្មការ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ព្រះរាជទាននាមហៅថា « គ្រឹះស្ថានសម្តេចព្រះនរោត្តម សីហនុ » ។ ពិធីសម្ពោធនេះ គឺធ្វើឡើងតាមផែនការ និងតាមរបៀបព្រះពុទ្ធសាសនា ដែលបានចាត់ចែងធ្វើឡើង ដើម្បីថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះប្រមុខរដ្ឋ កំណត់ទុកជាបុណ្យចំរើនព្រះជន្មវស្សានៃសម្តេចព្រះប្រមុខរដ្ឋ គំរប់ ៤១ យាងចូល ៤២ ព្រះវស្សា ដោយព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា និងបុគ្គលិកនៅអគ្គាធិការដ្ឋាន នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងព្រះសង្ឃ គ្រហស្ថសាស្ត្រាចារ្យ និងសមណនិស្សិតទាំងអស់ ក្នុងការឧបត្ថម្ភ នៃក្រសួងធម្មការ អស់ថេរវេលាចំនួន ២ ថ្ងៃ ១ យប់ គឺចាប់តាំងពីថ្ងៃសុក្រ ១៤ កើត ដល់ថ្ងៃសៅរ៍ ១៥ កើត ខែកត្តិក ឆ្នាំថោះបញ្ចស័ក ត្រូវនឹងថ្ងៃទី១៥



សម្ដេចសហជីវិនព្រះប្រមុខរដ្ឋកម្ពុជា ទ្រង់ទទួលផ្នូងបុប្ផាពីស្រ្តីពីររូប ជំស្រស់ ប្រិមប្រិយ ជានិមិត្តរូបនៃការថ្វាយប្រពរស្វាគមន៍ នៅឱកាសពិធីសម្ពោធគ្រឹះស្ថានព្រះនរោត្តម-សីហនុ (វិទ្យាល័យព្រះសុរាម្រិត ) នៅថ្ងៃទី ១៥-១១-៦៣

ទីន ១៦ វិច្ឆិកា ឆ្នាំ ១៩៦៣ ។

ថ្ងៃនេះជាថ្ងៃចាប់ផ្ដើមបុណ្យៈ ចាប់តាំងពីម៉ោង ៨ ព្រឹកទៅ ក្រុមពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ ជាច្រើនពាន់នាក់ បាននិមន្តនិងអញ្ជើញមកជួបជុំ ដោយគ្រងចីពរស្រុកសមតាមសមណសារូប ចំណែកឯគ្រហស្ថវិញ ស្លៀកពាក់តាមបែបជាឧបាសក ឧបាសិកា មានទាំងនាំកូនចៅទៅផង យ៉ាងគួរគឺកកង ប្រកបដោយកក្រើកក្រឹមក្រើយ ។ នៅពេលម៉ោង ៨,៣០ សម្ដេចព្រះសង្ឃនាយកទាំង ២ គណៈ ប្រធានសភាទាំង ២ នាយករដ្ឋមន្ត្រី ចាងហ្វាងតុលាការជាន់ខ្ពស់ សមាជិកកងរង្វាន់កិច្ចការ អនុរដ្ឋលេខាធិការ សមាជិកសភាទាំង ២ ព្រមទាំងមន្ត្រីអ្នករាជការគ្រប់ដំណែង និមន្ត ស្ដេចយាង និងអញ្ជើញដល់ ។

កន្លះម៉ោងក្រោយមក គឺម៉ោង ៩ គត់ សម្ដេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដោយមានឯកឧត្តម ញឹក ជូឡុង អនុប្រធានក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក និងឯកឧត្តមជាសមាជិក ព្រមទាំងព្រះរាជបរិពារដទៃទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយពុំបានកប់នាមក្នុងទីនេះ បានដង្ហែព្រះអដ្ឋិធាតុការ តាមព្រះរាជវិមានរថយន្ត ឆ្ពោះទៅកាន់ត្រីស្ថានបវរនេះ ។ នៅពេលនោះ សម្ដេចទ្រង់បានទទួលគារវកិច្ចពីទាហានក្រុមរក្សាព្រះអង្គ ដែលលើកកាំភ្លើងថ្វាយជាព្រះកិត្តិយសដ៏ខ្ពង់ខ្ពស់ ចំពោះព្រះអង្គ ។ នៅពេលដែល.ប.សម្ដេចទ្រង់យាងចុះពីព្រះវិមានរថយន្ត ទ្រង់

បានទទួលផ្គងផ្កាជានិមិត្តរូប នៃការថ្វាយព្រះពរស្វាគមន៍ ពីស្ត្រីពីររូប ប្រកបដោយរូបសម្បត្តិ និងសំលៀកបំពាក់គួរជាទីចាប់អារម្មណ៍ពន់ពេក ៗ តមក ទ្រង់ទទួលការគោរពពីនាំមុខសព្វមុខមន្ត្រី មានសម្តេចចៅហ្វាវាំង វរវៀងជ័យ ប៉ែន នុត ឯកឧត្តមសឺន.សាន ទីប្រឹក្សាផ្ទាល់ព្រះអង្គជាដើម ដែលរង់ចាំទទួលព្រះអង្គនៅទ្វារចូល ៗ ហែអមតាមផ្លូវនៃព្រះរាជដំណើរ ទៅកាន់ទីសម្ពោធ ក្រុមយុវជនរាជសង្គមនិយមខ្មែរ ស្លៀកពាក់ជាឯកសណ្ឋាន ស្រែកជយឃោសន៍ យ៉ាងកងរំពងថា !

ជយោ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភ !

ជយោ ព្រះបិតាឯករាជ្យជាតិ !

ជយោ សេដ្ឋកិច្ចជាតិ !

លុះសម្តេចឪ យាងដល់ទីនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុមតន្ត្រីព្រះរាជទ្រព្យក៏បានបន្លឺបទ នគររាជ តាមព្រះប្រពៃណីថ្វាយសម្តេចឪ ជាទីគោរពចប់ហើយ ទើបសម្តេចឪ ទ្រង់ក្រាបថ្វាយបង្គំយ៉ាងគោរពចំពោះព្រះសង្ឃ មានសម្តេចព្រះសង្ឃនាយកតាំងពីរគណៈជាប្រធាន រួចទើបព្រះសង្ឃ ចាប់សូត្រធម៌ជយន្តោ ប្រសិទ្ធិពរថ្វាយព្រះអង្គ ៗ លុះព្រះសង្ឃស្វាធ្យាយន៍ព្រះធម៌ចប់ហើយ សម្តេចព្រះប្រមុខរដ្ឋជាទីស្នេហាស្មើដោយជីវិត ទ្រង់ស្តេចប្រថាប់លើសុវណ្ណកោច្ឆៈ ប្រកបដោយព្រះភក្ត្រដ៏ប្រិមប្រិយក្រៃលែង ៗ សហជីវិន ម៉ុន-ណុំ អនុរដ្ឋលេខាធិការ ក្រសួង



សម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ទ្រង់ប្រណម្យគោរពព្រះសង្ឃដែលស្វាធ្យាយ
ព្រះពុទ្ធមន្តប្រសិទ្ធិពរថ្វាយ ក្នុងឱកាសពិធីសម្ពោធគ្រឹះស្ថានព្រះនរោត្តម–សីហនុ
(វិទ្យាល័យព្រះសុរាម្រឹត ) នៅថ្ងៃទី ១៥–១១–៦៣

ធម្មការ កំពាប់ថ្លែងសុន្ទរកថាថ្វាយព្រះពរសូាគមន៍ បន្ទាប់មកគឺជាសុន្ទរកថារបស់ព្រះពោធិវង្ស ហួត-តាត ថ្លែងអំពីប្រវត្តិសង្ខេបនៃពុទ្ធិកវិទ្យាល័យ និងអំពីការស្ថាបនា គ្រឹះស្ថានសម្ដេចព្រះនពេ្កត្តម-សីហនុ .ចូរនេះ[1] ហើយសម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ដែលជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ មានព្រះរាជបន្ទូលឆ្លើយតប ប្រកបដោយព្រះសូរសៀងយ៉ាងពិរោះគ្រោះក្សាយ និងមានសារៈសំខាន់ គួរជាទីពេញចិត្តពន់ពេក ហើយដែលយើងដកស្រង់ខ្លះមកផ្សាយជូនជួបតទៅ ៖

ជាបឋម សម្ដេចឪទ្រង់សរសើរចំពោះព្រះតេជព្រះគុណព្រះពោធិវង្ស ហួត តាត ដែលមានឧត្តមគតិដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចស្ថាបនាអាគារសំរាប់ពុទ្ធិកសិក្សាក្នុងព្រះពុទ្ធសាសនា ព្រមទាំងបានកសាងបានល្អមាំធំ ហើយអស់សោហ៊ុយយ៉ាងតិចជាអតិបរមា គួរយ៉ាងដូចជាគ្រឹះស្ថាន ព្រះនរោត្តម សីហនុ នេះ បើជារាជការធ្វើវិញ យ៉ាងតិចណាស់ក៏ត្រូវចំណាយអស់ ២ លានរៀល នេះមិនដូច្នោះ អស់មិនដល់ទាំង ១ លានរៀលផង ដែលជាព្រះរាជទ្រព្យផ្ទាល់ទ្រង់ប្រគេនមក ។ រួចទ្រង់ពោលបញ្ជាក់ជូនគូនទៅស្ដាប់ កុំឲ្យគាន់ប្រឡូំតាមពាក្យឃោសនាអកុសលនៃជនក្បត់ជាតិ ទូរ

(១) ឯសុន្ទរកថា សហជីវិនអនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនសិក្សាធិការ និងសុន្ទរកថាព្រះពោធិវង្ស ដែលថ្លែងក្នុងពេលនោះ យើងនឹងចុះផ្សាយនៅទំព័រក្រោយ ។

ការកែទម្រង់សេដ្ឋកិច្ចជាតិ ឯការធ្វើនេះ គឺដើម្បីស្រោចស្រង់ជីវិតជាតិ ដែលទើបតែជួបប្រទះនឹងទុនភាពវិការកល់ធ្ងំ បណ្តាលមកពីអំពើទុច្ចរិត នៃពួកមូលធនការតិច ដែលគិតតែស្វះស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ហើយនិងដើម្បីលើកស្ទួយជីវភាពដល់ជនជាកូនចៅទូទៅ ដែលតែងទទួលគ្រោះថ្នាក់អំពីពួកនាយទុនតែប៉ុណ្ណោះ ។ ទ្រង់បញ្ជាក់ថា ក្នុងឆ្នាំ ១៩៦៤ ព្រះអង្គនឹងប្រគេនចំពោះព្រះតេជព្រះគុណព្រះពោធិវង្ស នូវបច្ច័យចំនួន ២ លានរៀល ដើម្បីរុះរើកសាងជាថ្មី នូវពុទ្ធកវិទ្យាល័យព្រះសុរាម្រិត ដែលមានកន្លែងសិក្សាមិនគ្រប់គ្រាន់ផង ហើយមានសភាពចាស់ទ្រុឌទ្រោមផងនោះ ។ ទ្រង់បន្ថែមថា ប្រសិនបើការកែទម្រង់សេដ្ឋកិច្ចនេះរីកចំរើនក្នុងឆ្នាំ ១៩៦៥ ទ្រង់នឹងប្រគេនចំពោះ ព្រះពោធិវង្ស ហួត តាត ទៀត នូវបច្ច័យទ្វេឡើងជា ៣-៤ លាន ក្នុងកិច្ចស្ថាបនាអាគារពុទ្ធិកសិក្សា ។ នៅទីអវសាន ទ្រង់ថ្លែងបញ្ជាក់ អំពីព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជា ព្រោះជនក្បត់ជាតិថាព្រះអង្គបំបាត់ពុទ្ធសាសនា ទ្រង់ប្រកាសថា គ្មានជនណាកាន់ព្រះពុទ្ធសាសនាជាងព្រះអង្គទេ ទោះបីប្រទេសយើង មាននាមថាសង្គមរាស្ត្រនិយម គឺសង្គមរាស្ត្រនិយម ខាងព្រះពុទ្ធសាសនា ។ ដើម្បីបញ្ជាក់យ៉ាងច្បាស់អំពីទឹកព្រះទ័យព្រះអង្គ ចំពោះព្រះពុទ្ធសាសនា ទ្រង់ប្រកាសជាមហោឡារិក សូមដំឡើងឋានន្តរសមណៈសក្តិ ជាសម្តេចព្រះសង្ឃរាជ ថ្វាយចំពោះសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ



សម្តេចសហជីវិនទ្រង់បង្ហាញដល់មហាសន្និបាត នូវមីង «សាឡី» ជាមេនំបំបៅព្រះអង្គ
កាលទ្រង់នៅពីកុមារ  ក្នុងឱកាសពិធីសម្ពោធគ្រឹះស្ថាន  ព្រះនរោត្តម-សីហនុ
(វិទ្យាល័យព្រះសុរាម្រិត)នៅថ្ងៃ ទី ១៥-១១ ៦៣

ដែលគង់នៅចំពោះព្រះភក្ត្រព្រះអង្គនោះ ។

នៅពេលចប់ព្រះសូត្រសៀន ដ៏សែនពិរោះនោះមក ព្រះអង្គស្តេចយាងកាត់ខ្សែបូរ ជានិមិត្តរូបនៃការបើកគ្រឹះស្ថានថ្មីឲ្យប្រើប្រាស់ជាផ្លូវការតទៅ ស្តេចទ្រង់យាងទតគ្រឹះស្ថានថ្មីនេះ ប្រកបដោយព្រះភក្ត្រញញឹមប្រិមប្រិយ ដោយមាននាម៉ឺនមុខមន្ត្រីទាំងឡាយ តាមហែហមព្រះអង្គផង ។ បន្ទាប់ពីព្រះរាជទស្សនកិច្ចគ្រឹះស្ថានថ្មី ប្រកបដោយបរិយាកាសដ៏រីករាយនេះមក ព្រះអង្គទ្រង់ថ្វាយបង្គំលាព្រះសង្ឃទាំងពលរដ្ឋ គួរ បៅព្រះអង្គ និវត្តចូលព្រះបរមរាជវាំងវិញ នៅម៉ោង ១១.៣០ ដោយព្រះសុវត្ថិភាព ។

ពេលល្ងាច ម៉ោង ១៩.៣០ មាននិមន្តព្រះសង្ឃ ៤៣ អង្គចំរើនព្រះបរិត្ត នៅវិស្សមសាលនៃពុទ្ធិកវិទ្យាល័យ លុះដល់ម៉ោង ២០.៣០ និមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ សំដែងធម៌ទេសនា ។ បន្ទាប់មក មានបញ្ចាំងភាពយន្ត ដើម្បីកំដរបុណ្យនេះជូនដល់ទស្សនជនកំសាន្តផង ។

ថ្ងៃសៅរ៍ ១៥ កើត ខែកត្តិក ឆ្នាំថោះបញ្ចស័ក ( ១៦-១១-៦៣ )

ថ្ងៃនេះជាថ្ងៃបង្ហើយបុណ្យ បរិយាកាសព្រឹកនេះ ក៏មិនខុសពីព្រឹកថ្ងៃបុណ្យដំបូងដែរ គឺមានពុទ្ធបរិស័ទច្រើនជាអនេក ។ ម៉ោង ៩.៣០ សម្តេចព្រះសង្ឃនាយកទាំង ២ គណៈ និមន្តដល់ ពេលនោះព្រះពោធិវង្ស

ក៏ចាប់ឧទ្ទិស ព្រះរាជកុសលថ្វាយចំពោះសម្តេចព្រះមហាក្សត្រិយានី និង សម្តេចព្រះប្រមុខរដ្ឋ រួចចាប់ផ្តើមធ្វើពិធីសមាទានសីល ៥ បន្ទាប់មកព្រះសង្ឃក៏សូត្រធម៌ពាហុំទៅជូន. លុះចប់ហើយ ឧបាសក-ឧបាសិកាទាំងអស់ ក្រោកឡើងរៀបចំខ្លួន ដៃកាន់ផ្តិលបាយ ដើម្បីប្រារព្ធធ្វើពិធីដាក់បាត្រ អស់រយៈពេល ប្រហែល ៣០ នាទី ។ ក្រោយមក ព្រះសង្ឃក៏បានអនុមោទនា ជាកិច្ចបង្ហើយបុណ្យ ។

## សុន្ទរកថានៃសហជីវិន មែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ

សូមព្រះតេជៈដ៏គល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយ សម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ក្រោមល្អធូលីព្រះបាទ

ក្នុងនាមនៃសមណនិស្សិត នៃព្រះសង្ឃមានសម្តេចទាំងពីរព្រះអង្គជាប្រធាន នៃពុទ្ធបរិស័ទទាំងឡាយ និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ សូមបង្អោនកាយក្រោមល្អងធូលីព្រះបាទ ក្រាបបង្គំទូលថ្វាយ ដោយសេចក្តីគោរពដ៏ជ្រាលជ្រៅ នូវព្រះពរសាគមន៍ដ៏សក្តិសិទ្ធិ នូវបីតិសោមនស្សរីករាយ យ៉ាងក្រៃលែង និងនូវកតញ្ញូតាជាអតិបរមា ចំពោះសម្តេចព្រះបិតាឯករាជ្យជាតិ ជាព្រះឯកអគ្គពុទ្ធសាសនូបត្ថម្ភ ដែលព្រះអង្គទ្រង់សព្វព្រះហឫទ័យប្រោសប្រណី ទៀតស្តេចយាងមកជាព្រះអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដ៏មហោឡារិក នៃគ្រឹះស្ថានសម្តេចព្រះនរោត្តម



សហជីវិន ម៉ែន-ឈុំ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ ថ្លែងសុន្ទរកថា នៅឱកាស
ពិធីសម្ពោធគ្រឹះស្ថានព្រះនរោត្តម-សីហនុ នៅថ្ងៃ ទី ១៥-១១-៦៣

សីហនុ ទើបនឹងស្ដាប់ទាន់នេះ ៗ ព្រះហឫទ័យសន្ដោសរបស់ព្រះអង្គក្នុងឱកាសនេះ ធ្វើឲ្យទូលព្រះបង្គំជាខ្ញុំទាំងឡាយជាកូនចៅ ទាំងបព្វជិត ទាំងគ្រហស្ថ មានមនោសញ្ចេតនា ពោរពេញដោយសេចក្ដីត្រេកអរ នឹងអំណរព្រះមហាករុណាធិគុណរកទីបំផុតគ្មាន ព្រោះទូលព្រះបង្គំទាំងឡាយជាកូនចៅ មិនធ្លែតពាល់តែសោះ ក្នុងការចង់ឃើញព្រះភក្ត្រដ៏ប្រិមប្រិយ ប្រកបដោយសេរីសួស្ដី នឹងមេត្តាករុណានៃព្រះអង្គ ៗ

ឯគ្រឹះស្ថានសម្ដេចព្រះនរោត្ដម សីហនុដែលលេចត្រដែតឡើងនៅចំពោះព្រះភក្ត្រ ប្រកបដោយសោភណភាព នឹងសម្រស់ដ៏គួរស្នេហានេះ ចាត់ទុកជាព្រះនិមិត្តរូបដ៏ថ្លៃថ្លា នៃព្រះកាយវិការដ៏សែនសប្បុរស នៃសម្ដេចឪជាទីគោរព នឹងជាទីស្នេហាស្មើដោយជីវិត ចំពោះព្រះពុទ្ធសាសនា នឹងចំពោះសមណនិស្សិតទាំងឡាយ ដែលក្នុងពេលមុន រមែងមានការចង្អៀតចង្អល់ក្នុងការសិក្សាព្រះបរិយត្តិធម៌ នឹងវិជ្ជាដទៃផ្សេង ៗ ដ្បិតការរីកចំរើនហើយឆាប់រហ័សនៃវិជ្ជាទាំងនេះ ក៏ត្រូវតែពឹងផ្អែកយ៉ាងពេញបន្ទុកទៅលើទីសេនាសនៈ មានសភាពដ៏ទូលំទូលាយនឹងសមរម្យ ៗ កាលបើគ្រឹះស្ថានដ៏ជាទីមនោរម្យបែបនេះ ដែលជាផលនៃព្រះរាជអំណោយដ៏ថ្លៃថ្លានៃព្រះអង្គបានផុះឡើងហើយ នោះមានសង្ឃឹមយ៉ាងមាំទុកក្នុងចិត្តថា គុណសម្បត្តិខាងការចេះដឹងនៃសមណនិស្សិតទាំងឡាយ ដែលកាលពីដើម មានការរីកចំរើនដោយលំបាក មកពីមានថ្នាក់រៀនមិនសូវគ្រប់គ្រាន់

នោះ នឹងមានវឌ្ឍនភាពយ៉ាងធូ ហើយគាប់រហ័សជាពិតប្រាកដមិនខាន ។

ជាអវសាន តាមនាមនៃសមណនិស្សិតទាំងអស់ ទូលព្រះបង្គំជាខ្ញុំ សូមសំដែងថ្វាយ ចំពោះសម្ដេចឪ ជាព្រះឯកអគ្គពុទ្ធសាសនូបត្ថម្ភក៍ នូវសេចក្ដីសោមនស្សយ៉ាងធំជាអនេកប្បការ នឹងអំណរព្រះមហាករុណាធិគុណដ៏លើសលប់ជាថ្មី ព្រមទាំងសូមលើកព្រះកុសលដែលកើតមកពីការសិក្សាព្រះបរិយត្តិធម៌ ជាព្រះឱវាទនៃព្រះបរមគ្រូសម្មាសម្ពុទ្ធ ថ្វាយដោយសេចក្ដីគោរព ចំពោះព្រះអង្គ សូមព្រះអង្គទ្រង់ចម្រើនជាអតិបរមា ដោយព្រះសុខភាពដ៏បរិបូណ៌ ដោយព្រះសុភមង្គលគ្រប់ទិនទិវារាត្រី មានព្រះទីឃាយុយឺនយូរជាងរយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់នៃកូនចៅ ក្នុងព្រះកិច្ចដឹកនាំនាវាកម្ពុជា ជាទីស្នេហា ឆ្ពោះទៅកាន់ត្រើយសន្តិភាព វឌ្ឍនភាព សម្បូរសប្បាយ សូមឲ្យសត្រូវគ្រប់ទិស បាក់បប ខ្ទបខ្ទាច ព្រះបេស្កាបារមី ហើយឲ្យក្លាយមកជាមិត្រស្និទ្ធស្នេហា កុំបីឃ្លៀងឃ្លាតឡើយ ។

# សុន្ទរកថា

ថ្លែងក្នុងឱកាសនៃពិធីបុណ្យសម្ពោធគ្រឹះស្ថានសម្តេចព្រះ
នរោត្តម សីហនុ នៅថ្ងៃទី ១៤ វិច្ឆិកា ១៩៦៣ ដោយព្រះតេជ
ព្រះគុណព្រះពោធិវង្ស ហួត តាត អគ្គាធិការ នៃពុទ្ធិកសិក្សា ។

សូមថ្វាយព្រះពរ

សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃបុគ្គលិក សាស្ត្រាចារ្យ សមណនិស្សិតទាំងឡាយ និង ក្នុងនាមផ្ទាល់នៃអាត្មាភាព អាត្មាភាពមានបីតិសោមនស្សរីករាយយ៉ាងក្រៃលែង ចំពោះសម្តេចព្រះអគ្គសាសនូបត្ថម្ភកជាម្ចាស់ ដែលបានឆ្លៀតយកព្រះរាជវរោកាសស្តេចយាងមក ជាព្រះរាជាធិបតីនិងជាព្រះរាជកិត្តិយសដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសនៃពិធីសម្ពោធគ្រឹះស្ថានសម្តេចព្រះ នរោត្តម-សីហនុ ដែលទើបនឹងស្ថាបនាហើយថ្មីៗនេះ ដោយព្រះរាជអំណោយដ៏ថ្លៃថ្លានៃសម្តេចជាម្ចាស់ ។

ចំពោះសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ទ្រង់ ឯកឧត្តម និង អស់លោកទាំងឡាយ ដែលបាននិមន្ត ស្តេចយាង អញ្ជើញមកជាកិត្តិយស ដ៏ប្រសើរក្នុងពិធីសម្ពោធគ្រឹះស្ថានថ្មីនេះ ។

អម្បាញ់មិញនេះ លោកអនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសេចក្ដីថ្វាយព្រះពរស្វាគមន៍ ចំពោះសម្ដេចជាអម្ចាស់ ទាំងអំពីការស្ថាបនានៃគ្រឹះស្ថានថ្មីនេះ ដោយសង្ខេបរួចហើយ ។

ឥឡូវនេះ អាត្មាភាព សូមព្រះរាជទាន ព្រះរាជឱកាសបន្តិចថ្លែងអំពីប្រវត្តិសង្ខេបនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតនេះ ទាំងអំពីការស្ថាបនាគ្រឹះស្ថានថ្មី ដែលភ្ជាប់ដោយព្រះបរមនាមថា គ្រឹះស្ថានសម្ដេចព្រះនរោត្ដម-សីហនុ ដើម្បីទ្រង់ជ្រាប ដូចមានសេចក្ដីតទៅនេះ

សូមថ្វាយព្រះពរ ពុទ្ធិកវិទ្យាល័យនេះ កាលកើតដំបូងមានឈ្មោះថា «សាលាបាលី» ក្នុងព្រះបរមរាជូបត្ថម្ភ នៃព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ តាមអំណាចព្រះរាជប្រកាសលេខ ៨៥ ចុះថ្ងៃទី ២៤ វិច្ឆិកា ១៩១៤ ។ នៅពេលនោះ ពុំទាន់មានអាគារសម្រាប់សិក្សានៅឡើយ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានឲ្យបើកការសិក្សានៅដើមឆ្នាំ ១៩១៥ ដោយយកមន្ទីរព្រះសទ្ធម្ម ទាំងថែវភាគខ្លះ នៃវត្តព្រះកែវមរកត ធ្វើជាកន្លែងសិក្សាបណ្ដោះអាសន្ន ។

លុះដល់គ.ស. ១៩២០ រាជការបានចាប់ផ្ដើមកសាងអាគារ ១ ខ្នង មានកំពូលស្រួចសម្រាប់សាលាបាលីនៅជ្រុងឧត្ដរសួន ។

ដល់មកគ.ស. ១៩២២ បានរើសាលាបាលីពីវត្តព្រះកែវមរកតយក



ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត - តាត អគ្គាធិការនៃពុទ្ធិកសិក្សាថ្លែងសុន្ទរកថាក្នុងឱកាសពិធីសម្ពោធគ្រឹះស្ថានព្រះនរោត្តម - សីហនុ (វិទ្យាល័យព្រះសុរាម្រិត) នៅថ្ងៃទី ១៥-១១-៦៣

មករៀបចំការសិក្សាទៅអាគារថ្មី ដែលសព្វថ្ងៃបានរៀបចំធ្វើជាមន្ទីរពុទ្ធ-សាសនបណ្ឌិត្យ និងក្រសួងធម្មការ ។ នៅពេលនោះ សាលាបាលីបានប្រែឈ្មោះថា "សាលាបាលីជាន់ខ្ពស់" ដោយបានកែប្រែរបៀបការសិក្សាខ្លះ តាមអំណាចព្រះរាជប្រកាសលេខ ៧៥ ចុះថ្ងៃទី ១៣ មេសា ១៩២២ ។

ដល់មកគ.ស. ១៩២៥ រាជការបានបង្កើតព្រះរាជបណ្ណាល័យកម្ពុជា តែឥតមានទីសំណាក់ការ រាជការក៏បានសុំយកអាគារនៃសាលាបាលីជាន់ខ្ពស់ ឲ្យទៅជាទីសំណាក់ការនៃព្រះរាជបណ្ណាល័យកម្ពុជា ។ សាលាបាលីជាន់ខ្ពស់ ត្រូវលើកត្រឡប់ទៅឯវត្តព្រះកែវមរកតមួងទៀត ។

ដល់មក គ.ស. ១៩២៦ រាជការបានយកសាលាបឋមសិក្សាបារាំង-ខ្មែរ សម្រាប់កុមារកុមារី ដែលហៅថាសាលាផ្សារស្ទួន គឺសាលានេះបង្វែរឲ្យមកធ្វើជាអាគារសម្រាប់សាលាបាលីជាន់ខ្ពស់ ជាប់រហូតមកដល់សព្វថ្ងៃនេះ ។ រីឯអាគារនេះដែលស្ថាបនាតាំងពីគ.ស. ១៩១៦ ដរាបដល់មកឥឡូវនេះចំនួន ៤៧ ឆ្នាំហើយ សព្វថ្ងៃនេះពាស់ទ្រុឌទ្រោមពុកផុយស្ទើរតែគ្រប់អន្លើ ។ សាលានេះ ត្រូវមានការជួសជុលរាល់ឆ្នាំ ប៉ុន្តែទោះបីជួសជុលយ៉ាងណា ក៏ពុំបានជាប់មាំមួនឡើងវិញដែរ ព្រោះគ្រឿងឈើតាំងអស់សុទ្ធតែជាឈើពល ទោះបីជញ្ជាំងដែលធ្វើដោយឥដ្ឋដែលពុំមានស៊ីម៉ង់ត៍សោះ ក្នុងពេលនោះ ឥឡូវនេះ ទៅជាសម្បុកនៃសត្វ

កាណ្ឌស្មើរតែគ្រប់អន្ទើ ។

លុះដល់មកគ.ស. ១៩៥៥ ក្រោយពេលដែលពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជកើតឡើង សាលាបាលីជាន់ខ្ពស់ បានប្រែឈ្មោះជា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត តាមព្រះរាជក្រិតលេខ ៣៨៨ ន.ស. ចុះថ្ងៃទី៤ កក្កដា ១៩៥៥ ព្រមទាំងមានការរៀបចំជាថ្មីផង ទាំងកម្មវិធីសិក្សាក៏បានរៀបចំជាថ្មីដែរ តាមព្រះរាជក្រឹត្យ លេខ ២៦៥ ន.ស. ចុះថ្ងៃទី ១៨ ធ្នូ ១៩៥៥ ដើម្បីដឹកនាំសមណនិស្សិតឲ្យមានសមត្ថភាពអាចចូលទៅសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជបាន ។

រីឯសាលាបាលីរងដែលកើតឡើងក្នុងគ.ស ១៩៣៣ ក៏ត្រូវបានកែប្រែឈ្មោះជា « សាលាពុទ្ធិកបឋមសិក្សា » ព្រមទាំងបានកែប្រែកម្មវិធីសិក្សាផង តាមព្រះរាជក្រឹត្យលេខ ៦០៧ ន.ស. ចុះថ្ងៃទី ១៤ ធ្នូ ១៩៥៧ ដើម្បីញ៉ាំងសមណនិស្សិតទាំងឡាយ ឲ្យមានសមត្ថភាពអាចចូលមកសិក្សានៅពុទ្ធិកវិទ្យាល័យបាន ព្រោះសាលាពុទ្ធិកបឋមសិក្សាជាមូលដ្ឋាននៃមធ្យមសិក្សា និងឧត្តមសិក្សា ប៉ុន្តែការរៀបចំសាលាពុទ្ធិ-កបឋមសិក្សាក្នុងឆ្នាំ ១៩៥៧ នោះ មិនបានប្រកបដោយលក្ខណៈសព្វគ្រប់ នាំឲ្យសាលានេះជួបនឹងឧបសគ្គខ្លះ ក្នុងរឿងលំបាករកអាចារ្យទៅបង្រៀន ឬរកបានហើយ ក៏បង្រៀនពុំបានដិតដល់ ជាហេតុនាំឲ្យមូលដ្ឋាននៃពុទ្ធិកសិក្សាពុំសូវរឹងប៉ឹង ពុំសូវមានកម្លាំង ដូច្នេះ ក្នុងឆ្នាំ ១៩៦៤ ខាង

មុខនេះ ទើងសូមព្រះបរមពជានុញ្ញាត រើរៀបចំកែទម្រង់សាលាពុទ្ធិកបឋមសិក្សាក្នុងព្រះរាជាណាចក្រ ឲ្យមានទម្រង់វិសេសឡើង ដើម្បីញ៉ាំងការសិក្សាក្នុងសាលានេះឲ្យមានដំណើរល្អតលាស់ចំរើនល្អឡើងជាងមុន ល្មមឲ្យសង្ឃឹមបានថាជាមូលដ្ឋានដ៏រុងប៉ុងមាំមួននៃពុទ្ធិកសិក្សាទៅក្នុងអនាគតៗ

សូមថ្វាយព្រះពរ ចំពោះពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតនេះ បើគិតតាំងពីឆ្នាំ ១៩១៥ ដល់ឆ្នាំ ១៩៦៣ នេះ ឃើញថាមានអាយុកាល ៤៨ ឆ្នាំហើយ ប៉ុន្តែ កាលនៅក្នុងអំណាចនៃរាជការអាណាព្យាបាលបារាំងសែសនៅឡើយ សាលានោះបានរីកចំរើនឡើងយ៉ាងស្តួចស្តើងណាស់ អស់ពេលជិតយូរអង្វែង លុះដល់ពេលដែលប្រទេសកម្ពុជា បានទទួលឋានៈជាប្រទេសឯករាជ្យ ដោយសារបុណ្យបារមីនៃសម្តេចជាម្ចាស់ សាលានេះក៏បានធ្វើដំណើរដ៏លឿនទៅកាន់សេចក្តីចំរើន គឺចំរើនតាំងចំនួនសមណនិស្សិត ដោយបានពង្រីកថ្នាក់សិក្សាឲ្យមានច្រើនឡើងផង ចំរើនតាំងវិជ្ជាសិក្សា ដោយបានកែប្រែកម្មវិធីសិក្សាឲ្យសមតាមកាលៈទេសៈ ប៉ុន្តែចំពោះអាគារសិក្សាវិញ ថិតនៅដដែល នាំឲ្យមានការចង្អៀតចង្អល់ខ្លះព្រោះគ្នាច្រើន ផ្ទះតូច តែការចង្អៀតកាយក៏ចេះតែប្រព្រឹត្តទៅបានស្រួលមិនជាអ្វីប៉ុន្មាន ព្រោះមានការកែកាយដំឡូលំឡូលាយខាងផ្លូវចិត្ត ។

លុះដល់មកគ្រឹស្តសករាជ ១៩៦២ អាត្មាភាពបានផ្តើមគំនិតបម្រុងនឹងស្នើទៅក្រសួងធម្មការ សុំឲ្យជួយរកមធ្យោបាយដើម្បីនឹងពង្រីកអាគារ

នៃពុទ្ធិកវិទ្យាល័យនេះ ឲ្យបានទូលាយថន្ថិចជាងមុន ។ ការស្នើនេះពុំទាន់ទាំងបានធ្វើផង ក៏ស្រាប់តែសម្ដេចជាអម្ចាស់ ក្នុងពេលដែលស្ដេចយាងមកជាព្រះរាជាធិបតីក្នុងពិធីប្រោសព្រះរាជទានឧត្តមសក្តិបត្រ ដល់សមណនិស្សិតនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ព្រះអង្គទ្រង់បានប្រោសព្រះរាជទានបច្ច័យចំនួន ១ លានរៀល ដោយព្រះរាជសទ្ធាជ្រះថ្លាក្នុងការជួយឧបត្ថម្ភពុទ្ធិកវិទ្យាល័យនៅថ្ងៃទី ៤ មេសា ១៩៦២ ។ នៅពេលនោះ អាត្មាភាពមានសោមនស្សរីករាយជាអតិបរមា សេចក្ដីរីករាយនោះជិតជាប់នៅក្នុងចិត្តរហូតដល់ថ្ងៃនេះ ។ មិនមែនតែអាត្មាភាព ១ រូបទេ មជ្ឈដ្ឋាននៃព្រះសង្ឃទាំងអស់ មានសម្ដេចព្រះសង្ឃនាយកទាំងពីរព្រះអង្គជាដើម ក៏មានព្រះទ័យរីករាយណាស់ ទាំងពុទ្ធបរិស័ទទាំងឡាយក៏មានចិត្តត្រេកអរត្រេកគ្នា ។

សូមថ្វាយព្រះពរ ឥឡូវនេះ ព្រះរាជអំណោយ ១ លានរៀលនោះបានបញ្ចេញនូវផល គឺគ្រឹះស្ថាន ១ ខ្នង ដែលឋិតនៅចំពោះព្រះភក្ត្រនេះ ។ គ្រឹះស្ថាននេះ ក្រោយដែលបានទទួលព្រះបរមរាជានុញ្ញាត បានដាក់ព្រះបរមនាមថា « គ្រឹះស្ថានសម្ដេចព្រះនរោត្តម-សីហនុ » ដើម្បីជាអនុស្សាវរីយ៍ សម្រាប់សមណនិស្សិតទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត ឲ្យរលឹកឃើញជានិច្ច នូវព្រះបរមនាមរបស់ព្រះអង្គដែលជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក ព្រមទាំងមានឧបការគុណដ៏ខ្ពង់ខ្ពស់មិនអាចនឹងបំភ្លេចបាន ។

គ្រឹះស្ថានថ្មីនេះ មានទំហំទទឹង ១០ ម៉ែត្រ បណ្តោយ ២៤ ម៉ែត្រ មានជាន់ពីរ ចែកជាបន្ទប់មាន ៦ គឺខាងក្រោម ៣ បន្ទប់ កណ្តាលទីង ខាងលិច ធ្វើជាកន្លែងសិក្សា ។ ខាងលើ បន្ទប់ខាងកើត ធ្វើជាការិយាល័យសម្រាប់ចាត់ការ បន្ទប់កណ្តាលធ្វើជាកន្លែងសម្រាប់ប្រជុំសាស្ត្រាចារ្យ បន្ទប់ខាងលិច ធ្វើជាបណ្ណាល័យ ព្រោះថាពុទ្ធិកវិទ្យាល័យនេះ ឥតដែលមានបណ្ណាល័យសោះទេ ។ គម្ពីរឬសៀវភៅក្បួនខ្នាតរបស់ពុទ្ធិកវិទ្យាល័យសម្រាប់គ្រូនិងសិស្ស បានយកទៅផ្ញើទុកនៅពុទ្ធសាសនបណ្ឌិត្យខ្លះ ទុកនៅត្រង់នេះខ្លះ ត្រង់នោះខ្លះ ដែលជាហេតុនាំឲ្យលំបាកថែរក្សាផង លំបាកនឹងចាត់ការផង ។

សូមថ្វាយព្រះពរ ការកសាងគ្រឹះស្ថានថ្មីនេះ ដោយរួមទាំងការជួសជុលសាលាចាស់ផង ការចាក់ស៊ីម៉ងត៍នៅមុខគ្រឹះស្ថានថ្មីនេះផង ការរៀបចំខាងក្នុងបន្ទប់ ១ ធ្វើជាតិលានដ្ឋានផង ការលាបទឹកកំបោរនៅសាលាចាស់ផង អស់តម្លៃ កៅសិបប្រាំបួនម៉ឺនប្រាំមួយពាន់ ប្រាំមួយរយសាមសិបបីរៀល ( ៩៩៦.៦៣៣៛០០ ) ក្នុងបច្ច័យព្រះរាជអំណោយ ១ លានរៀលនោះ នៅសល់បីពាន់បីរយហុកសិបប្រាំពីររៀល ( ៣៣៦៧៛០០ ) បច្ច័យដែលនៅសល់នេះ បម្រុងនឹងចំណាយទៅក្នុងកិច្ចការអ្វីដែលខ្វះខាតក្នុងខាងមុខ ។

សូមថ្វាយព្រះពរ តាំងពីថ្ងៃនេះតទៅ ដោយមានគ្រឹះស្ថាន ១ ខ្នង

នេះកើតឡើង ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត មានទីកន្លែងសម្រាប់ចាត់ការ សម្រាប់ប្រជុំសាស្ត្រាចារ្យ សម្រាប់ធ្វើជាបណ្ណាល័យ នឹងសម្រាប់ធ្វើជាថ្នាក់គ្រប់គ្រាន់ៗ ប៉ុន្តែ ចំពោះកន្លែងសិក្សាដែលអាត្មាភាពបានថ្វាយពតិមានគ្រប់គ្រាន់នោះ ដោយបានពឹងផ្អែកទៅលើគ្រឹះស្ថាននៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ព្រោះសព្វថ្ងៃនេះ បានសុំខ្ចីគ្រឹះស្ថានពុទ្ធិកមហាវិទ្យាល័យ ចំនួន៩បន្ទប់ ឲ្យសមណនិស្សិតនៃពុទ្ធិកវិទ្យាល័យទៅសិក្សា ប្រសិនបើតទៅមុខ ពុទ្ធិកមហាវិទ្យាល័យរីកចំរើនឡើង ហើយត្រូវការយកបន្ទប់សិក្សាទាំងនោះទៅវិញ ពុទ្ធិកវិទ្យាល័យនេះ នឹងត្រូវទទួលការខ្វះខាត ១ លើកទៀតមិនខាន ។

ដើម្បីសម្រួលឲ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតនេះ មានកន្លែងសិក្សាគ្រប់គ្រាន់ទៅក្នុងអនាគតនោះ អាត្មាភាពមានយោបល់ថា តទៅខាងមុខ ប្រសិនបើមានសម្ភារៈគ្រប់គ្រាន់ក្នុងពេលណា ក្នុងពេលនោះ គួរតែរុះរើសាលាចាស់ដែលស្ថាបនាប្រហែល ៤០ ឆ្នាំមកហើយ ។ បិតនៅក្នុងសភាពទ្រុឌទ្រោមនេះ ហើយស្ថាបនាជាពីរជាន់ឡើង នោះនឹងអាចប្រមូលថ្នាក់រៀនពីពុទ្ធិកវិទ្យាល័យចំនួន ៩ បន្ទប់មករួមគ្នា ក្នុងពុទ្ធិកវិទ្យាល័យនេះបាន ព្រោះក្នុងទីនេះ ឥតមានទីដីល្មមនឹងសង់អាគារថ្មីបានទៀតឡើយ ។

សូមថ្វាយព្រះពរ បន្ទាប់អំពីនេះ អាត្មាភាពសូមព្រះរាជទានថ្វាយពតិ-



នេះជាគ្រឹះស្ថានព្រះនរោត្តម–សីហនុ នៅវិទ្យាល័យ ព្រះសុរាម្រិត សម្ពោធកាលពីថ្ងៃទី ១៥ - ១១–៦៣ ក្រោមព្រះអធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចសហជីវិនព្រះប្រមុខរដ្ឋកម្ពុជា

មានអំពីពិធីបុណ្យក្នុងឱកាសនេះសូមទ្រង់ជ្រាបដូចតទៅ ។

បុគ្គលិក សាស្ត្រាចារ្យ និងសមណនិស្សិតទាំងអស់នៅអគ្គាធិការដ្ឋាន នៃពុទ្ធិកសិក្សា នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ នៅពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត នៅពុទ្ធសាសនបណ្ឌិត្យ រួមទាំងក្រសួងធម្មការផង បានព្រម ព្រៀងគ្នា នឹងធ្វើពិធីបុណ្យចំរើនព្រះជន្មសម្តេចជាម្ចាស់ គឺក្នុងរាត្រីនៃថ្ងៃនេះ នឹងនិមន្តព្រះសង្ឃ ៤៣ អង្គ មានសម្តេចទាំងពីរព្រះអង្គជាប្រធាន មកចំ រើនព្រះបរិត្តនៅទីនេះ រួចនិមន្តសម្តេចប្រធានធម្មទេសនា ទុកជាធម្មទាន រួមជាមួយនឹងអាមិសទាន ថ្វាយព្រះរាជកុសល ១ លើក លុះដល់ព្រឹក ស្អែកនឹងនិមន្តព្រះសង្ឃ ៤៣ អង្គដែលចំរើនព្រះបរិត្តពីល្ងាច មកចំរើនធម៌ មង្គលសូត្រ រួចដាក់បាត្រប្រគេនទេយ្យទាន១លើកទៀត។ ពិធីបុណ្យទាំង ពីរលើកនេះ សូមលើកថ្វាយជាព្រះរាជកុសល ចំពោះសម្តេចជាម្ចាស់ដើម្បី ព្រះអង្គបានចំរើន ព្រះជន្មាយុយឺនយូរជាងរយវស្សា ប្រកបដោយសេច-ក្តីសុខសាន្ត កុំបីមានសត្រូវមកពាធាយាយីព្រះអង្គបានឡើយ ទាំងកិច្ចការ ទាំងឡាយណាដែលមានសារៈប្រយោជន៍ ដល់ប្រទេសជាតិដល់ព្រះពុទ្ធ សាសនា ដែលសម្តេចជាម្ចាស់បានផ្តើមធ្វើឡើង សូមឲ្យកិច្ចការទាំង នោះបានសម្រេចដោយប្រពៃ កុំបីមានឧបសគ្គៈអ្វីមករាំងរាបានឡើយ ។

នៅឱកាសនេះ អាត្មាភាពសូមរំលឹកចំពោះគុណព្រះរតនត្រ័យ សូមសំបូងសង្រួង អស់ពួកទេវតាក្នុងសែនកោដិចក្រវាឡ ដែលមានចិត្ត

ល្អជាសម្មាទិដ្ឋិ ជួយអភិបាលរក្សាសម្ដេចព្រះមហាក្សត្រិយានីជាម្ចាស់ជីវិត និងសម្ដេចព្រះប្រមុខរដ្ឋជាម្ចាស់ សូមព្រះអង្គបានប្រកបដោយព្រះសុភមង្គលវិបុលសុខ សិរីសួស្ដីជោគជ័យ ឈ្នះអស់មារសត្រូវគ្រប់ទិសទីអស់កាលជានិច្ច គ្រប់ទិវារាត្រី កុំបីឃ្លាត ។

សូមប្រគេន ថ្វាយជូន ចំពោះសម្ដេចសង្ឃនាយកទាំងពីរព្រះអង្គ ព្រះរាជវង្សានុវង្ស ឯកឧត្តម និងអស់លោក ព្រមទាំងពុទ្ធបរិស័ទទាំងឡាយនូវពុទ្ធពរទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ តរៀងទៅ ។